ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Feb-2017, 13:30
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤៨៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

លោក ហាសាន អាធុរេលិយ៉ា
*(Mr. Harshan ATHURELIYA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គីមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក សេង លីថេង (2-TCW-897) | ខ្មែរ |
| លោកស្រី ខៀវ នាប (2-TCCP-258) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សេង លីថេង** (2-TCW-897)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៥

សួរដោយលោក ខេល លីសាក់ ផ្តើមពី ........ ទំព័រ ៨

សួរដោយពេជ អង្គ ផ្តើមពី ........ ទំព័រ ៣០

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៣៦

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........ ទំព័រ ៤០


**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ខៀវ នាម** (2-TCCP-258)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៦០

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........ ទំព័រ ៦២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-897 ហើយនិងមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុង 2-TCCP-258។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះនៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-897។ សាក្សី បានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សី បានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សី មានមេធាវីប្រឹក្សាគឺលោក ម៉ម រិទ្ធា។ ហើយសាក្សី និងមេធាវីប្រឹក្សាមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:០៣:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណកញ្ញា ជា ស៊ីវហ័ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦។ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា ថានៅថ្ងៃនេះ ថាមានអាការឈឺចង្កេះជាប់ជាប្រចាំ ហើយកាន់តែឈឺខ្លាំងនៅពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទបញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះ អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៥:០៦]

បាទ មុននឹងអញ្ជើញសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្ម ដោយសារអង្គជំនុំជម្រះបានទទួលដំណឹងតាមរយៈអ៊ីម៉ែលថា មេធាវីការពារក្តី ខៀវ សំផន មានបំណងលើកសារណាផ្ទាល់មាត់ពាក់ព័ន្ធជាមួយដើមបណ្តឹងរដ្ឋប្បវេណី -- ជាមួយនឹងសាក្សី 2-TCW-1063 គឺពាក់ព័ន្ធនឹងឯកសារក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះនាខាងមុខ ដូច្នេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីឡើងបង្ហាញនូវ ផ្ទាល់មាត់នូវសំណើសុំរបស់ខ្លួននាពេលនេះ។

សូមអញ្ជើញ បាទ!

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ ខ្ញុំមានសេចក្តីស្នើខ្លីទេ។ នៅក្នុងសំណុំរឿងយើងនេះ គឺថាយើងមានឯកសារមួយចំនួនទាក់ទងទៅនឹងសាក្សី 1063 ដែលជា<>ជាដើមបណ្តឹងរដ្ឋប្បវេណី <-- ខ្ញុំមិនដឹងថាហេតុអ្វីបានជាវាជា W-1063 នោះ>ទេ។ <ប៉ុន្តែគាត់>គាត់ជាដើមបណ្តឹងរដ្ឋប្បវេណី<នៅក្នុងសំណុំរឿង០០២> ហើយនិងនៅក្នុងសំណុំរឿងផ្សេងទៀតផងដែរ។

អង្គជំនុំជម្រះបានទទួលសំណើរបស់ព្រះរាជអាជ្ញាដែលសុំបញ្ចូលជាភស្តុតាងនូវព័ត៌មានបន្ថែមនៃទម្រង់បែបបទចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺឯកសារ E3/10670 ប៉ុន្តែអត់មាននៅក្នុងសំណុំរឿងទេ នៃទម្រង់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ដែលបំពេញនៅសំណុំរឿងផ្សេងមួយទៀត។ នៅក្នុងសំណុំរឿង មានតែនៅក្នុង០០២ ទេ ក៏ប៉ុន្តែមិនមាននៅក្នុងសំណុំរឿងដែលកំពុងស៊ើបអង្កេតនោះទេ គឺមានតែព័ត៌មានបន្ថែមហ្នឹងទេ។ អ៊ីចឹងបើគាត់មាននៅក្នុងសំណុំរឿងដែលគេកំពុងស៊ើបអង្កេតនេះ វាគួរតែមានកំណត់ហេតុស្តាប់ចម្លើយគាត់នៅក្នុងសំណុំរឿងដែលកំពុងស៊ើបសួរហ្នឹងដែរ។ <វាគឺជាឯកសារដែលយើងចង់បាន។> អ៊ីចឹងឥឡូវនេះ យើងមិនអាចដឹងថា តើឈ្មោះឯកសារហ្នឹងមានលេខកូដអ្វីខ្លះនៅក្នុងសំណុំរឿងហ្នឹង។ អ៊ីចឹងមានតែព្រះរាជអាជ្ញា ហើយនិងចៅក្រមនៃសំណុំរឿងហ្នឹង <ឬក៏មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងផ្សេងទៀត ដែល>អាចផ្តល់មកឲ្យយើង។ <ប៉ុន្តែ>វាជា<ផ្នែកនៃ>ចម្លើយពីមុនៗមក<ដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ដូច្នេះ បើនរណាម្នាក់ផ្សេងទៀតអាចផ្តល់ឯកសារនោះមកឲ្យយើងខ្ញុំ វានឹងអាចជួយដល់យើងខ្ញុំ>។ អ៊ីចឹងយើង<នឹងនិយាយឡើងវិញ> គឺឯកសារ E3/10670 <គឺជាទម្រង់ព័ត៌មានបន្ថែម>។ <ប៉ុន្តែ>យើងអត់មានកំណត់ហេតុស្តាប់ចម្លើយគាត់នៅក្នុងសំណុំរឿង០៤ទេ។ អ៊ីចឹងខ្ញុំសុំស្នើៗ ឲ្យបញ្ចូលឯកសាររបស់គាត់ហ្នឹងដើម្បីឲ្យយើងទាំងអស់គ្នាហ្នឹងទទួលបានដែរ ទោះបីជាខាងព្រះរាជអាជ្ញាក៏ដោយ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ សុំឲ្យគាត់ធ្វើយ៉ាងណាសម្រួលផ្តល់ឯកសារនេះមកឲ្យយើង។

[០៩:០៨:២២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការតប ឬក៏កត់សម្គាល់លើសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ បុគ្គលិកនៃការិយាល័យសហព្រះរាជអាជ្ញាក៏នឹងពិនិត្យមើលចំណុចនេះផងដែរ។ ក៏ប៉ុន្តែខ្ញុំសូមជម្រាបថា ជាញឹកញាប់នោះ គឺពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំដាក់ចូល<>នៅក្នុងសំណុំរឿងដទៃទៀត <ជាទូទៅ ពួកគេប្រើប្រាស់ក្រដាសដែលមាន>ទម្រង់<>ដូចគ្នា<នឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ហើយគ្រាន់តែដាក់បញ្ចូលឡើងវិញនៅក្នុងសំណុំរឿងផ្សេងទៀត>។ <ខ្ញុំមិនដឹងថា តើនោះជាអ្វីដែលបានកើតឡើងនៅទីនេះដែរឬទេ ប៉ុន្តែ>យ៉ាងណាក៏ដោយ បុគ្គលិកនៅក្នុងការិយាល័យរបស់យើងខ្ញុំនឹងពិនិត្យមើលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងផ្សេង ដើម្បីផ្ទៀងផ្ទាត់មើលថាតើវាដូចគ្នាបេះបិទតែម្តង ឬក៏វាមានទម្រង់ខុសគ្នា។

**ប្រធានអង្គជំនុំ៖**

ចុះខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងស្ថិតនៅក្នុងស្ថានភាពដូចមេធាវី ខៀវ សំផន ដែរ។ យើងមិនអាចចូលមើលឯកសារនៅក្នុងសំណុំរឿង០០៤បានទេ។ អ៊ីចឹងខ្ញុំសុំកត់សម្គាល់ធ្វើយ៉ាងម៉េចឲ្យព្រះរាជអាជ្ញាគាត់ទៅផ្ទៀងផ្ទាត់ថា តើមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរឿងនៅក្នុងសំណុំរឿង០០២ -- ០៤ ហ្នឹងដែរឬទេ ដូចនឹងសំណុំរឿង០០២ដែរឬទេ។ អ៊ីចឹង ខ្ញុំសូមស្នើឲ្យការិយាល័យសហព្រះរាជអាជ្ញាគាត់ទៅផ្ទៀងផ្ទាត់មើល តើវាយ៉ាងម៉េចដែរ។

**ប្រធានអង្គជំនុំ៖**

ខាងក្រុមសហមេធាវីការពារក្តី នួន ជា មានមតិយោបល់ ឬក៏មានការកត់សម្គាល់យ៉ាងម៉េចដែរទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមានការកត់សម្គាល់អ្វីទេ លោកប្រធាន។ សូមអរគុណ។

[០៩:១០:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណនៅរាល់មតិយោបល់ដែលពាក់ព័ន្ធនឹងបញ្ហានេះ ហើយអង្គជំនុំជម្រះ

នឹងយកបញ្ហានេះទៅពិនិត្យ ពិចារណា សម្រេចឲ្យបានសមស្របឆាប់ៗ ដើម្បីដំណើរការឲ្យបានមុនពេលស្តាប់សក្ខីកម្មសាក្សី 2-TCW-1063។ ខ្ញុំមិនដឹងថា ឯកសារផ្សេងហ្នឹងទៅជាមាន -- ទៅជាដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP នោះទេ។ ឯកសារខ្ញុំ គឺដាក់មកហ្នឹង គឺមានកំណត់ថា នៅក្នុងរឿងក្តីនេះកោះហៅគាត់ក្នុងឋានៈជាសាក្សី។ យើងនឹងក៏ពិនិត្យមើលផងដែរ នៅបញ្ហានេះឲ្យបានច្បាស់លាស់ នៅលិខិត នៅអ៊ីម៉ែលដែលបានជូនដំណឹងទៅភាគីកន្លងមក។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១២:៤៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

**លោក សេង លីថេង៖**

**ឆ៖** ខ្ញុំឈ្មោះ សេង លីថេង។

**ស៖** បាទ អរគុណលោក សេង លីថេង។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំដែរទេ?

**ឆ៖** ឆ្នាំប៉ុន្មានទេ--

**ស៖** លោកឆ្លើយបានហើយ លោក។ ឥឡូវអ៊ីចេះ! ដោយសារដំណើរការហ្នឹងអាចមានទេ គឺថាចាំប្រតិបត្តិការ ក្បាលមីក្រូហ្វូននៅចំពោះមុខលោកហ្នឹងអាចប្រតិបត្តិការដោយសញ្ញាភ្លើងក្រហម។ អាហ្នឹងបានន័យថា វាចាប់ផ្តើមប្រតិបត្តិការ លោកអាចនិយាយបានហើយ ដើម្បីឲ្យសំឡេងលោកហ្នឹងគឺបានចែកចាយសម្រាប់អង្គជំនុំជម្រះ សម្រាប់ភាគីពាក់ព័ន្ធ ហើយជាពិសេសហ្នឹង គឺដល់អ្នកបកប្រែភាសា ដើម្បីឲ្យគេបកប្រែភាសាលោកទៅជាភាសាពីរទៀត គឺភាសាអង់គ្លេស និង ភាសាបារាំង។ ហើយកាលណាមានការសួរទៅលោក គឺសូមលោកបង្អង់បន្តិច ជាការស្តាប់នូវចម្លើយ -- សំណួរឲ្យបានច្បាស់លាស់ផង ហើយជាការសម្រួលដល់ប្រតិបត្តិការរបស់ក្បាលមីក្រូហ្វូនហ្នឹង ឲ្យដំណើរការសឹមលោកឆ្លើយ។ ដោយសារបច្ចេកទេសក្នុងការបកប្រែ ដូច្នេះទើបទាមទារពេលវេលាមួយដែល ដើម្បីឲ្យការបកប្រែហ្នឹង បានទាន់ បានច្បាស់លាស់។ តើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំដែរទេ?

ឆ៖ ថ្ងៃ១៧ ខែ៧ ១៩៤៦ – ៤៦។

ស៖ បាទ អរគុណ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណាដែរ?

ឆ៖ កន្លែងកំណើត កើតនៅភូមិព្រៃកស្បូវ ស្រុកកំពង់ស្វាយ ឃុំកំពង់ស្វាយ ខេត្តកំពង់ធំ។

[០៩:១៥:០៦]

ស៖ បាទ អរគុណ។ ហើយទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

ឆ៖ ទីលំនៅបច្ចុប្បន្ន នៅអូរតាប្រាង ស្រុកប៉ៃលិន ឃុំប៉ៃលិន ខេត្តប៉ៃលិន។

ស៖ បាទ អរគុណ ហើយលោកប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះ?

ឆ៖ របរសព្វថ្ងៃធ្វើចម្ការ។

ស៖ បាទ អរគុណ។ ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោក ឈ្មោះអី?

ឆ៖ ឪពុកឈ្មោះ សាឡុត សេង ម្ដាយឈ្មោះ លឹម ហឹប។

ស៖ ប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

ឆ៖ ប្រពន្ធឈ្មោះ ទេព ខុន។ កូនបីនាក់។

ស៖ បាទ អរគុណលោក សេង លីថេង តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ អម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍នេះ ត្រឹមត្រូវដែរឬទេ?

ឆ៖ បាទ ត្រឹមត្រូវ។

ស៖ តើលោកបានធ្វើសម្បថតាមជំនឿសាសនារបស់លោក នៅចំពោះមុខអ្នកតាដំបងដែករួចហើយឬនៅមុនចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

ឆ៖ បានធ្វើសម្បថរួចហើយ។

[០៩:១៧:១០]

ស៖ តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សី នៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក លីថេង ក្នុងឋានៈលោកជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ

អង្គជំនុំជម្រះនេះ លោកអាចបដិសេធ ក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអត្ថាធិប្បាយ រៀបរាប់ដែលនាំឲ្យចម្លើយតប ឬការរៀបរាប់របស់លោក ដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្ម ប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈជាសាក្សីត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ ហើយលើកលែងតែសំណួរណាដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយ អម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបាន ដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់ នូវព្រឹត្តហេតុ នូវហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះ សួរចំពោះលោក។ លោក លីថេង តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើប អង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា?

**ឆ៖** ធ្លាប់ធ្វើម្តងនៅប៉ៃលិន តែម្តងទេ។

**ស៖** នៅពេលណា នៅថ្ងៃខែឆ្នាំណាដែរ លោកចាំដែរទេ?

**ឆ៖** នៅខែ៤ ឆ្នាំ២០០៤។

[០៩:១៩:០០]

**ស៖** ២០០៤ ដូចជាមិនទាន់បង្កើត អ.វ.ត.ក នៅឡើយទេ លោកចងចាំទេ តើ២០០៤ តើអ្នក ដែលទៅធ្វើសម្ភាសន៍លោកហ្នឹងជា អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏ជា មន្ត្រីផ្សេងទៀត ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម។ លោកអាចស្គាល់ដែរទេ?

**ឆ៖** ខ្ញុំអត់ចាំដែរ ប៉ុន្តែធ្លាប់ទៅសម្ភាសខ្ញុំម្តងនៅប៉ៃលិន។

**ស៖** ហើយកាលបរិច្ឆេទ ប្រហែលអាចខុស។ លោករកនឹកឡើងវិញមើល កាលបរិច្ឆេទនៃការ ធ្វើហ្នឹងអាចឆ្នាំណាផ្សេងពីហ្នឹងដែរហ្នឹង ២០០៤ ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិន ទាន់ដំណើរការនៅឡើយទេ។ ចាប់ដំណើរការ២០០៦។

[០៩:២០:០៩]

**ឆ៖** រកនឹកៗមិនឃើញ ឆ្នាំណា--

**ស៖** បាទៗ មិនអីទេ ហើយគ្រាន់តែចង់ដឹងអ៊ីចេះថា មុននឹង -- ក្នុងពេលដែលនេះហ្នឹង តើ

លោកអាចពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកផ្ដល់សក្ខីកម្មកាលពីពេលមុនហ្នឹងជាមួយនឹងខាងមន្ត្រីនៃ អ.វ.ត.ក នេះដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំបានអានរួចហើយ គ្រាន់ថាឆ្នាំនេះដូចៗខុសម៉េច ខ្ញុំ--

**ស៖** មិនអីទេ យើងនឹងផ្ទៀងផ្ទាត់លើកក្រោយទៀត គ្រាន់តែឲ្យដឹងថាលោកបានធ្វើ ហើយលោកបានអាន។ ហើយឥឡូវនេះតាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេកំណត់ហេតុដែលលោកផ្ដល់សក្ខីកម្មកាលពីពេលមុនជាមួយនឹងមន្ត្រី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅប៉ៃលិននោះ តើវាត្រឹមត្រូវសមស្របស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកមន្ត្រីនៃ អ.វ.ត.ក កាលពីពេលនោះដែរឬទេ?

**ឆ៖** បាទ ចម្លើយពិតជាត្រឹមត្រូវហើយ។

[០៩:២១:៤២]

**ស៖** បាទ នាពេលនេះគឺលោកមានមេធាវីប្រឹក្សារួចហើយ ដែលអង្គជំនុំជម្រះបានផ្ដល់ជូននៅតាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញតាមសំណើសុំរបស់លោក។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រី ចៅក្រម ភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី បាទ ព្រឹកនេះតាមរយៈការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំមានសំណួរមួយចំនួនសួរទៅរូបលោក។ តើលោកអាចជម្រាបជូនតុលាការបានទេថា តើលោកមានជាប់សាច់ឈាមអីជាមួយនឹង ប៉ុល ពត ដែរឬទេ ដែលពីមុនមកនេះឈ្មោះហៅថា សាឡុត ស នោះ? ហើយប្រសិនណាជាលោកជាប់ជាសាច់ឈាមជាមួយនឹង ប៉ុល ពត តើលោកជាប់សាច់ឈាមក្នុងកម្រិតណាដែរឬ?

[០៩:២៣:០១]

**លោក សេង លីថេង៖**

**ឆ៖** បាទ ខ្ញុំជាៗក្មួយបង្កើតរបស់ ប៉ុល ពត។

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាឪពុកបង្កើតរបស់លោកនេះគឺជាបងប្រុសបង្កើតរបស់ ប៉ុល ពត ហ្នឹង?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកមានជាប់សាច់ឈាមជាមួយបុគ្គលម្នាក់ ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះនៅក្នុងសំណុំរឿងមុន គឺគាត់ឈ្មោះ សាឡុត បាន ហៅ សួរ ហុង។ តើលោកជាប់សាច់ឈាមអីជាមួយនឹងគាត់ដែរទេ?

**ឆ៖** បាទ លោក សួរ ហុង ជាបងបង្កើតរបស់ខ្ញុំ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេថា លោកហ្នឹងបានចូលក្នុងចលនាបដិវត្តន៍ខ្មែរក្រហមដំបូងបំផុតនោះនៅពេលណា? ហើយអ្នកណាដែលជាអ្នកឧទ្ទេសនាមលោកឲ្យចូលរួមក្នុងចលនាបដិវត្តន៍លើកដំបូងបំផុតនោះ?

**ឆ៖** បាទ ខ្ញុំចូលចលនាបដិវត្តន៍តាំងពីឆ្នាំ៧០ – ១៩៧០។

[០៩:២៥:០០]

**ស៖** តើលោកមានបានក្លាយជាសមាជិកបក្សដែរឬទេ? ហើយបើលោកបានក្លាយជាសមាជិកបក្ស តើលោកបានក្លាយជាសមាជិកបក្សនៅពេលណា?

**ឆ៖** ខ្ញុំមិនបានចូលជាសមាជិកបក្សទេ។

**ស៖** តើលោកធ្វើអ្វីនៅក្នុងឆ្នាំ១៩៧០នោះ នៅពេលដែលលោកចូលរួមចលនាបដិវត្តន៍ជាលើកដំបូងនោះ?

**ឆ៖** ៧០ ខ្ញុំជាកងទ័ព។

**ស៖** តើលោកជាកងទ័ពចំណុះឲ្យអង្គភាពណាមួយដែរ អាចជាកងទ័ពស្រុក កងទ័ពតំបន់ កងទ័ពភូមិភាគ ឬក៏អង្គភាពកងទ័ពណាមួយដែរ? អ៊ីចឹងតើនៅក្នុងឆ្នាំ១៩៧០នោះ លោកគឺជាកងទ័ពចំណុះឲ្យអង្គភាពណាដែរ?

**ឆ៖** ពីឆ្នាំ៧០ ខ្ញុំនៅក្នុងកងទ័ពវៀតណាម ជាៗកូនទាហាន មិនមានឋានៈអីទេ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** លោកបានឆ្លើយ<ដូចគ្នា>។ នៅក្នុងចម្លើយឆ្លើយជូនអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត<ដែលខ្ញុំចង់សុំការបញ្ជាក់ឲ្យច្បាស់។> នៅពេលលោកនិយាយថា លោកជាផ្នែកមួយនៃកងទ័ពវៀតណាម តើលោកពិតជាកងទ័ពចំណុះអង្គភាពកងទ័ពវៀតណាម ឬកង<វរសេនាតូច>ណាមួយ ឬក៏ថាលោកគឺជាកងទ័ពខ្មែរក្រហម ដែលបានប្រយុទ្ធជាមួយនឹងវៀតណាម? សូមលោកបញ្ជាក់ចំណុចនេះបន្តិចបានទេ?

**ឆ៖** វៀតណាមដែល -- ជាកងទ័ពវៀតណាមដែលតស៊ូជាមួយរបបលន់ នល់។

[០៩:២៧:៤៥]

**ស៖** តើមានពេលណាមួយលោកបានក្លាយទៅជាកងទ័ពរបស់ភូមិភាគឧត្តរ ដែលដឹកនាំបញ្ជាដោយ កែ ពក នោះដែរឬទេ?

**ឆ៖** កាលឆ្នាំ១៩៧៣ ទើបខ្ញុំត្រឡប់មកចូលក្នុងកងទ័ពខេត្តឧត្តរនេះ។

**ស៖** តើលោកនៅធ្វើជាកងទ័ពចំណុះឲ្យភូមិភាគឧត្តរហ្នឹងអស់រយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** អស់រយៈពេលប្រហែលជាង៣ឆ្នាំ។

**ស៖** នៅពេលដែលលោកធ្វើជាកងទ័ពវៀតណាមនោះ តើលោកឈរជើងនៅកន្លែងណាដែរនៅពេលនោះ?

**ឆ៖** កាលហ្នឹងឈរជើងនៅភាគច្រើនគឺនៅក្នុងខេត្តកំពង់ធំ និងក្នុងខេត្តសៀមរាប ការពារអង្គរ។

**ស៖** ឥឡូវខ្ញុំចូលសួរលោកអំពីតួនាទីដែលលោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍របស់លោក។ តើគេចាត់តាំងឲ្យលោកធ្វើជាអ្នក ធ្វើជាកងការពារ ឬក៏ធ្វើជានីរសារហ្នឹងឲ្យមេដឹកនាំខ្មែរក្រហមហ្នឹងមុនដំបូងនៅៗពេលណាដែរ?

**ឆ៖** គឺនៅពេលដែលខ្ញុំមានរបួស លែងធ្វើការជាកងទ័ពកើត គេបញ្ជូនខ្ញុំមកកន្លែងអង្គភាពការពារ។

**ស៖** តើលោកចាំទេឆ្នាំណាដែរ ដែលលោក<មានរបួស ហើយត្រូវបានគេចាត់តាំងឲ្យ>ចូលទៅខាងកងការពារហ្នឹង? គេចាត់ឲ្យលោកចូលកងការពារឆ្នាំណាដែរ?

**ឆ៖** អាចក្នុងឆ្នាំ១៩៧០ -- ៧៤ ចាំមិនច្បាស់ដែរ។

**ស៖** សូមអរគុណដែលលោកបានបញ្ជាក់។ នៅក្នុងឆ្នាំ៧៤ ឬក៏ឆ្នាំនុំង គឺគេឲ្យលោកនៅកងការពារ ហើយតើលោកឈរនៅទីតាំងណាដែរក្នុងនាមជាកងការពារ?

**ឆ៖** ក្នុងខេត្ត នៅចំការលើ មុំចំការលើខេត្តកំពង់ចាម។

[០៩:៣១:៥៥]

**ស៖** ចុះចំណែកមេដឹកហ្នឹងណា នរណាខ្លះដែរ ដែលគាត់នៅកន្លែងនោះក្នុងនាមលោកជាកងការពារ?

**ឆ៖** មេដឹកនាំនៅកន្លែងហ្នឹងមាន ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន។

**ស៖** លោកបានលើកឡើងថា នៅ -- លោកនៅចំការលើ។ តើលោកនៅចាំទីស្នាក់ការ ឬក៏មន្ទីររបស់បក្សដែលស្ថិតនៅតាមស្ទឹងជីនិតនៅតាមព្រំដែនខេត្តកំពង់ធំ<និងខេត្តកំពង់ចាម>ដែរឬទេ? <តើ>កន្លែងនោះហើយគឺជាកន្លែងដែលលោកឈរជើងធ្វើជាអ្នកយាមការពារមេដឹកនាំ បានន័យថា ជាមន្ទីរនៅតាមដឹងស្ទឹងជីនិតជាប់ ព្រំដែនខេត្តកំពង់ធំ និងកំពង់ចាម មែនដែរឬទេ?

**ឆ៖** ខ្ញុំចាំមិនៗច្បាស់ទេកន្លែងទីស្នាក់ការហ្នឹង។ ទីកន្លែងច្បាស់លាស់មែនទែនខ្ញុំមិនស្គាល់ទេ។

**ស៖** តើលោកនៅចាំទេ ទីស្នាក់ការនុ៎ង តើគេមានដាក់ឈ្មោះ លេខកូដដែរឬទេ? ហើយប្រសិនបើមាន <តើវាមានឈ្មោះអ្វីដែរ? តើ>មន្ទីរ <ឬក៏មូលដ្ឋាន> ដែលមេដឹកនាំគាត់ឈរទីតាំងនៅទីនោះក្នុងឆ្នាំ៧៤<មានឈ្មោះអ្វីដែរ>?

**ឆ៖** មិនមានលេខកូដ ឬក៏ឈ្មោះអីទេ។ ខ្ញុំក៏មិនដឹងដែរ។

**ស៖** បាទ ពាក់ព័ន្ធឆ្នាំ៧៤នេះដដែល ជាពិសេសទីតាំងដែលលោកឈរជើងក្នុងអង្គភាពកងការពារជាមួយនឹងថ្នាក់ដឹកនាំកំពូលៗ ចុះបងរបស់លោក សួរ ហុង តើគាត់នៅកន្លែងនុ៎ងជាមួយលោកដែរឬទេ បានន័យថា នៅទីស្នាក់ការរួមជាមួយលោកដែរឬទេ ក្នុងអំឡុងឆ្នាំនោះ?

**ឆ៖** គាត់នៅទីនុ៎ងដែរ។

[០៩:៣៤:៥៤]

**ស៖** លោកបានបញ្ជាក់ថា មេដឹកនាំនៅទីនោះ រួមមាន ប៉ុល ពត, នួន ជា និង ខៀវ សំផន។ តើលោកសង្កេតឃើញថា ពួកគាត់ធ្វើអីខ្លះនៅក្នុងឆ្នាំ៧៤? តើពួកគាត់រស់នៅរួមរស់ជាមួយនឹងគ្នាហើយធ្វើអ្វីដែរ? សូមលោកជម្រាបនូវការសង្កេតរបស់លោកពាក់ព័ន្ធទៅនឹង ប៉ុល ពត, នួន ជា និង ខៀវ សំផន ក្នុងអំឡុងឆ្នាំ៧៤ តើពួកគាត់ធ្វើអ្វីខ្លះ<>នៅ<>ពេលដែលលោកធ្វើការងារជាកងការពារ?

**ឆ៖** ការងារល្អិត ហើយការងារធំដុំ ខ្ញុំមិនអាចក្តាប់បានទេ ព្រោះឃើញតែគាត់ប្រជុំគ្នាញឹកញាប់តែប៉ុណ្ណឹងឯង។

**ស៖** តើនរណាខ្លះចូលរួម<ប្រជុំទាំងអស់នោះ> ពេលដែលលោកឃើញនោះ?

**ឆ៖** ប្រជុំ គឺទាំងអស់គ្នាហ្នឹង ប៉ុន្មាននាក់ បួននាក់ហ្នឹង។

**ស៖** ខ្ញុំចង់សុំសួរលោកអំពីសក្ខីកម្មនានា ដែលយើងបានលើក បានស្ដាប់នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ក្នុងពេលសវនាការទី១ ពាក់ព័ន្ធ -- សក្ខីកម្មរបស់ ភី ភួន ឯកសារ E1/98.1។ ខ្ញុំសូមអាន ចំណុចដកស្រង់ ចេញមក ម៉ោង១៤:០៤ ដល់១៤:០៦ ពេលរសៀល។ ប្រតិចារឹករបស់ ភី ភួន បាន លើកឡើងអំពីសម័យមុនឆ្នាំ១៩៧៥។ “សំណួរ៖ ពីឆ្នាំ៧១ ដល់ ៧៤ តើ ខៀវ សំផន និង ប៉ុល ពត បាន ជួបប្រជុំគ្នាជាញឹកញាប់ដែរឬទេ? ចម្លើយ៖ ចាប់ពីឆ្នាំ៧១ ដល់ឆ្នាំ៧៤ ពួកគេបានជួបគ្នាញឹកញាប់ដែរ ពេលខ្លះពួកគាត់នៅដាច់ដោយឡែកពីគ្នា ដោយសារតែមន្ទីរស្ថិតនៅកន្លែងខុសគ្នា ក៏ប៉ុន្តែក្រោយមកមន្ទីរ នេះ បានប្ដូរមកនៅជិតគ្នា។ បន្ទាប់មក ខៀវ សំផន បានមកធ្វើការងារនៅក្នុងមន្ទីរជាប់នឹងមន្ទីររបស់ ប៉ុល ពត ហើយខ្ញុំក៏បានបញ្ជាក់ថ្ងៃមុនផងដែរថា ពេលខ្លះពួកគាត់ធ្វើការរួមគ្នាតែម្ដង គឺអ្នកទាំងបីនាក់ នោះ គាត់ធ្វើការរួមគ្នា គឺបងធំទី១ បងធំទី២ និងលោក ខៀវ សំផន។”

[០៩:៣៨:០៩]

ហើយនៅក្នុងចម្លើយបន្ទាប់មកទៀត “ពួកគាត់បានជួបគ្នានៅពេលព្រឹក ពេលដែលពួកគាត់ហូប អាហារពេលព្រឹក។ ពួកគាត់ហូបបបររួមគ្នា បន្ទាប់មកជួបប្រជុំគ្នាពីម៉ោងប្រាំបីសាមសិប ដល់ម៉ោង ដប់មួយ ហើយនៅពេលអាហារថ្ងៃត្រង់ ពួកគាត់ក៏ជួបប្រជុំគ្នាផងដែរ។ បន្ទាប់មកពួកគាត់សម្រាកមួយ ភ្លែត ហើយចាប់ផ្ដើមប្រជុំនៅពេលរសៀល។ ក្រោយពេលបញ្ចប់ការងារប្រចាំថ្ងៃ ពួកគាត់ត្រឡប់ទៅ កន្លែងរៀងៗខ្លួន ហើយពួកគាត់ហូបអាហារពេលល្ងាចដាច់ដោយឡែកពីគ្នា។” បញ្ចប់ការដកស្រង់។

តើនៅពេលដែលខ្ញុំអាននេះ តើលោកនឹកឃើញដែរឬទេ? តើត្រឹមត្រូវដែរឬទេ អ្នកមេដឹកនាំទាំង បី ប៉ុល ពត, ជួន ជា និង ខៀវ សំផន នេះបានន័យថា ហូបអាហាររួម ជួបជុំគ្នា ហើយធ្វើការរួមគ្នាផង ដែរ<រៀងរាល់ថ្ងៃ> ក្នុងពេលដែលលោកធ្វើជាអ្នកយាមនៅក្នុងឆ្នាំ៧៤?

**ឆ៖** សភាពនុ៎ង ខ្ញុំគិតថាជាការត្រឹមត្រូវហើយ។

**ស៖** នៅពេលនេះ ខ្ញុំសូមសួរអំពីសម័យកាលក្រោយឆ្នាំ ថ្ងៃ១៧ មេសា ឆ្នាំ៧៥ វិញម្ដង។ តើ ប៉ុល ពត, នួន ជា និង ខៀវ សំផន នៅតែបន្តរស់នៅជាមួយគ្នា ហើយធ្វើការរួមជាមួយគ្នាដែរឬទេ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ នៅពេលដែលគេបានផ្លាស់លោកទៅទីក្រុងភ្នំពេញនោះ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ ការរស់នៅរបស់ពួកគាត់បែបណានោះ ខ្ញុំចាំមិនច្បាស់ដែរ។

[០៩:៤០:២១]

**ស៖** ខ្ញុំសូមសួរសំណួរទូទៅទៅកាន់លោកសិន។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ តើលោកទៅណាក្រោយថ្ងៃរំដោះ? ហើយតើលោកធ្វើការងារអ្វី គឺក្រោយពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញក្រោយថ្ងៃ១៧ ខែមេសា ៧៥ លោកទៅទីណាដែរ? ហើយលោកធ្វើការអ្វីខ្លះ?

**ឆ៖** នៅពេលដែលរំដោះភ្នំពេញ គឺការងាររបស់ខ្ញុំវាមិនៗកំណត់ទីកន្លែង។ ដំបូង ខ្ញុំនៅអង្គភាពក្រសួងការបរទេសមើលការខុសត្រូវខាងស្ថានទូតគ្រប់ប្រទេសទាំងអស់ ហើយនិងកម្មករចិន មើលការខុសត្រូវខាងកម្មករចិន ហើយបន្ទាប់មក ខ្ញុំក៏ទៅនៅអង្គភាពក្រសួងការបរទេសដដែល ប៉ុន្តែនៅខាងផ្នែកទទួលភ្ញៀវវិញ។ ដូច្នេះការងារខ្ញុំ វាអត់ទៀង។

**ស៖** ដំបូងនៅពេលដែលលោកនៅ<ក្រសួងការពារជាតិ ហើយបន្ទាប់មកគេបញ្ជូនទៅ>កន្លែងជិតទូតចិននោះ <> តើលោកធ្វើការងារអ្វីដែរនៅទីនោះ? <តើគេចាត់តាំងឲ្យលោកធ្វើការងារអ្វីដែរនៅអំឡុងពេលនោះ>

**ឆ៖** នៅទីនោះ ជួយកិច្ចការសម្រួលការទំនាក់ទំនងស្ថានទូតចិន និងក្រសួងការបរទេសខ្មែរ ហើយនិងជួយភាពងាយស្រួលដល់កម្មករចិនក្នុងការធ្វើដំណើរទៅមកតាមខេត្តនានា។

**ស៖** តើមានពេលណាមួយដែរឬទេ ដែលគេចាត់ឲ្យលោកជាអ្នកយាមឲ្យមេដឹកនាំនៅមន្ទីរក-១ ប្រសិនបើមានអីចឹងមែននោះ តើនៅពេលណាដែរ ដែលគេចាត់លោកឲ្យធ្វើកងការពារនៅក-១ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥។ បានន័យថាទៅគឺនៅពេលណាដែរ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ ដែលលោកត្រូវបានគេឲ្យធ្វើជាកងការពារនៅ ក-១?

**ឆ៖** ក្រោយពីខ្ញុំចេញពីក្រសួងការបរទេសមក ខ្ញុំបានមកកន្លែងក-១ហ្នឹង ជាកងការពារប្រហែលជាឆ្នាំកៅ-- ១៩៩៣, ៩៤អី។

[០៩:៤៤:១០]

**ស៖** សូមអធ្យាស្រ័យ ខ្ញុំមិនដឹងថាតើជាការបកប្រែខុស ឬក៏ច្រឡំ។ អ្នកបកប្រែថា ឆ្នាំ៩៣ និងឆ្នាំ៩៤។ យើងនិយាយអំពីសម័យខ្មែរក្រហម បានន័យថា ខ្មែរក្រហមកាន់កាប់ពី<ខែ>មេសា ៧៥ ដល់មករា ឆ្នាំ៧៩។ តើប៉ុន្មានខែក្រោយថ្ងៃរំដោះ ថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ ដែលគេចាត់តាំងលោកឲ្យធ្វើជាកងការពារនៅក-១ – មន្ទីរក-១ នោះ?

**ឆ៖** ចាំមិនច្បាស់។

01389732



**សៈ** តើលោកអាចជម្រាបតុលាការប្រហាក់ប្រហែលមើល៍ ប្រហាក់ប្រហែល<រយៈពេលប៉ុន្មានដែល>លោកធ្វើការនៅក្រសួងការបរទេស <មុនពេល>ដែលគេបញ្ជូនលោកទៅក-១ <ឲ្យធ្វើជាអ្នកយាមនោះ>?

**ឆៈ** ប្រហែលជាឆ្នាំ៧៨។

**សៈ** ខ្ញុំសូមអានជូនលោកស្តាប់លោកសាក្សី ចេញមកពីកំណត់ហេតុស្តាប់ចម្លើយដែលលោកផ្តល់ជូនចៅក្រមស៊ើបអង្កេត ឯកសារ E3/462 – E3/462, ERN ជាភាសាខ្មែរ 00204024, អង់គ្លេស 00223563 ហើយបារាំង <00491959>។ លោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយតាំងពីឆ្នាំ២០០៧ ដូចតទៅ៖ “សំណួរ៖ ពេលភ្នំពេញបែកថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោកនៅឯណា ធ្វើអ្វីខ្លះ? ឆ្លើយ៖ នៅឆ្នាំ១៩៧៥ ខ្ញុំនៅអង្គភាពមេដឹកនាំ តួនាទីជានីរសារ អ្នករត់សំបុត្រ និងជាអ្នកការពារថ្នាក់ដឹកនាំ។ សំណួរ៖ អង្គភាពដឹកនាំមានន័យយ៉ាងម៉េចដែរ? ជាមន្ទីរ ឬក៏ជាអ្វីដែរ? ឆ្លើយ៖ ជាកន្លែងអ្នកដឹកនាំ ខ្ញុំមិនចាំមន្ទីរអ្វីទេ ក៏ប៉ុន្តែខ្ញុំជាអ្នកការពារនៅក្នុងមន្ទីរនុំងទាំងមូល។ ធម្មតាក្នុងមន្ទីរ<មួយ> មានអង្គភាពការពារមន្ទីរ ការពារថ្នាក់ដឹកនាំទាំងអស់មាន ប៉ុល ពត, ខៀវ សំផន មានន្ទួន ជា ហើយ អៀង សារី ដែរ មានតែបួននាក់នេះទេ។” ហើយលោកបានបន្តលើកឡើងទៀតថា “មុនឆ្នាំ៧៥ ខ្ញុំនៅចំការលើ ក្រោយឆ្នាំ១៩៧៥ ខ្ញុំនៅអង្គភាពការពារដដែល ក៏ប៉ុន្តែទៅភ្នំពេញវិញ។ នៅម្តុំផ្ទះល្វែងទន្លេបាសាក់ ដែលអ្នកដឹកនាំគាត់នៅទីនោះតែម្តង។ អ្នកដឹកនាំនៅបន្ទប់ផ្សេងៗគ្នាក្នុងផ្ទះល្វែងតែមួយនេះ។ មន្ទីរនេះគេហៅថាមន្ទីរក-១ តួនាទីខ្ញុំពេលនោះ គឺជាកងការពារ និងជានីរសារដដែល។” បញ្ចប់ការដកស្រង់។

តើសក្ខីកម្មដែលលោកឆ្លើយនេះគឺពិតដែរឬទេ បានន័យថាវាជាអ្វីដែលត្រឹមត្រូវតាមការពិតដែលលោកប្រាប់អ្នកចៅក្រមស៊ើបអង្កេតដែរឬទេ? លោកគឺជាកងការពារថ្នាក់ដឹកនាំនៅក-១ ចាប់តាំងពីឆ្នាំ១៩៧៥មក?

[០៩:៤៦:៤៦]

**ឆៈ** កន្លែងនេះដូចខ្ញុំបានៗជម្រាបជូនអំមិញអ៊ីចឹងមុននឹងទៅក-១ហ្នឹង ខ្ញុំៗនៅធ្វើការនៅចំណុះឲ្យក្រសួងការបរទេសកន្លែងភ្ញៀវទូតចិនហ្នឹង និងអ្នកបច្ចេកទេសចិន។ ផុតពីហ្នឹងបានគេបញ្ជូនខ្ញុំទៅកន្លែងទទួលភ្ញៀវ ផុតពីកន្លែងទទួលភ្ញៀវហើយបានជូនខ្ញុំទៅៗនៅកន្លែងក-១។

**សៈ** ខ្ញុំយល់នៅក្នុងកំណត់ហេតុចៅក្រមស៊ើបអង្កេតមិនមានការលើកឡើងអំពីពេលដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកធ្វើការ<នៅ>មន្ទីរក្រសួងការបរទេសនោះទេ។ ប៉ុន្តែខ្ញុំសូមសួរលោក មុនពេលលោកទៅធ្វើនៅ ក-១ នោះគឺថាលោកធ្វើការនៅមន្ទីរក្រសួងការបរទេសនេះតែមួយរយៈពេលខ្លីទេ ឬក៏លោកធ្វើការ <នោះរយៈពេលយូរ រាប់ឆ្នាំ>?

**ឆ៖** ខ្ញុំធ្វើការនៅក្រសួងការបរទេសហ្នឹងក្នុងមួយរយៈខ្លីទេ ហើយបានគេបញ្ជូនខ្ញុំមកកន្លែង ក-១។

**ស៖** នៅពេលដែលគេបញ្ជូនលោកទៅ ក-១ ធ្វើជានីរសារនិងកងការពារនោះ តើមេដឹកនាំដែលលោកឃើញនៅទីនោះ រស់នៅទីនោះធ្វើការងារទីនោះជាប្រចាំថ្ងៃហ្នឹងជានរណាដែរ?

[០៩:៥០:៥៣]

**ឆ៖** នៅក-១មួយហ្នឹង អ្នកដឹកនាំមាន ប៉ុល ពត, អៀង សារី, ខៀវ សំផន ហើយនិង នួន ជា។

**ស៖** តើលោកអាចពិពណ៌នាជូនតុលាការបានដែរឬទេអំពីទីតាំងក-១នេះ? ស្ថិតនៅកន្លែងណាដែរក-១ហ្នឹង? មន្ទីរក-១ នៅទីក្រុងភ្នំពេញដែលលោកធ្វើការជានីរសារនិងកងការពារនោះ ស្ថិតនៅកន្លែងណា? សូមលោកជួយពិពណ៌នាជូនតុលាការ។

**ឆ៖** ល្វែង គេនៅផ្ទះល្វែងប៉ុំខិញសព្វថ្ងៃហ្នឹង គឺនៅជិតទន្លេបាសាក់។

**ស៖** តើលោកនៅចាំដែរឬទេ ក្រៅពីមន្ទីរក-១ តើលោកនៅចាំមន្ទីរមួយទៀត ដែលមេដឹកនាំដដែល គាត់ធ្លាប់ប្រើប្រាស់មន្ទីរនោះដែរ យើងហៅថាមន្ទីរ ក-៣? តើលោកនៅនឹកឃើញទេ?

**ឆ៖** អត់ដែលឮដែរ។ អត់ដឹងដែរ។

**ស៖** ខ្ញុំសូមអានជូនលោកស្តាប់<នូវអ្វីដែល> ខៀវ សំផន បានឆ្លើយនៅក្នុងកំណត់ហេតុជូនចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងប្រធានបទនេះ។ ហើយខ្ញុំសាកអានមើល នឹងអាចឱ្យលោកចាំនឹកឃើញដែរឬទេ? ឯកសារ E3/37 ខ្មែរ ERN គឺ 00156676 ដល់ 677, អង់គ្លេស 00156755, បារាំង 00156682 ដល់ 83។ ចម្លើយនេះ គឺ ខៀវ សំផន ជាអ្នកប្រាប់ចៅក្រមស៊ើបអង្កេត ឆ្លើយប្រាប់ចៅក្រមស៊ើបអង្កេត៖ "តើក-៣ និងក-១ នេះមានន័យយ៉ាងម៉េចដែរ? <ឆ្លើយ៖> វាសំដៅលើកន្លែងរស់នៅ ឬក៏កន្លែងធ្វើការរបស់សមាជិកគណៈអចិន្ត្រៃយ៍? ក-១ នៅម្តុំមាត់ទន្លេបាសាក់ ខាងត្បូងអគារ <សាលមហោស្រពជាតិ> ហើយក-៣នៅខាងក្រោយព្រះបរមរាជវាំង ដែលនៅទីនោះមានផ្ទះល្វែងដែលវានៅជាប់ព្រំប្រទល់<ផ្លូវ>ផ្លូវប៉ាស្ទ័រ និង<ផ្លូវ>កម្ពុជាក្រោម ហើយផ្លូវ<វេជ្ជ>បណ្ឌិត<ហាន> និងផ្លូវ<ស្រប>មួយទៀត។ ចំពោះខ្ញុំៗរស់នៅក-៣ ក្រោយពេលដែលខ្ញុំនៅក-១ រយៈពេលពីរឬបីខែ

ក្រោយ<ពី>យើង<បាន>ផ្លាស់ប្ដូរ<ពី>ព្រះវិហារព្រះកែវមរកតនៅ<ក្នុង>ព្រះបរមរាជវាំង។ ការពិតទៅមេដឹកនាំភាគច្រើននៅក-៣ រួមមាន អៀង សារី, សុន សេន និង នួន ជា។ ចំពោះ ប៉ុល ពត គាត់ស្នាក់នៅក-៣ម្ដងម្កាល ដោយសារតែគាត់ត្រូវមានភាពប្រយ័ត្នប្រយែង និងប្រុងប្រយ័ត្នជានិច្ចកាល។ វាជាធម្មតាសម្រាប់គាត់ដែលគាត់ផ្លាស់ប្ដូរពីផ្ទះមួយទៅផ្ទះមួយ ហើយគាត់ក៏ធ្លាប់រស់នៅក-១ផងដែរ។" បញ្ចប់ការដកស្រង់។

[០៩:៥៥:០៣]

ខ្ញុំដឹងថា ហេតុការណ៍ហ្នឹងកើតឡើងយូរមកហើយ ក៏ប៉ុន្តែលោកនៅចាំទីតាំងមួយនៅខាងលិចព្រះបរមរាជវាំងដែរឬទេ ដែលជាផ្ទះសម្រាប់មេដឹកនាំស្នាក់នៅ រួមទាំងធ្វើការងារផងដែរ តើលោកនឹកឃើញទេកន្លែងនុ៎ង?

**ឆ៖** អត់ដែលស្គាល់ទេកន្លែងហ្នឹង។

**ស៖** ខ្ញុំនឹងផ្ដោតសួរលោកអំពីមន្ទីរ -- ទីតាំងមន្ទីរក-១។ បានន័យថា នៅមុំទន្លេបាសាក់នុ៎ង។ លោកបានបញ្ជាក់ថា មេដឹកនាំដែលលោកធ្លាប់បានឃើញរស់នៅទីនោះ និង ធ្វើការនៅទីនោះ រួមមាន ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី តើក្រៅពីមេដឹកនាំទាំងបួនដែលលោកឃើញជា ុះ<>ញឹកញាប់នោះ តើមានអ្នកផ្សេងដែរឬទេ នៅក-១ ដែលលោកធ្លាប់បានឃើញក្រៅពីគាត់ទាំងបួន?

**ឆ៖** ក្រៅពីអ្នកទាំងបួនហ្នឹង គឺម្ដងម្កាល គឺមានគណៈភូមិភាគអីមកធ្វើការម្ដងម្កាលដែរ។

**ស៖** ចុះ សុន សេន តើលោកស្គាល់ទេ សុន សេន ជានរណា? លោកធ្លាប់បានឃើញគាត់នៅក-១ ដែរឬទេ?

**ឆ៖** នៅក-១ សុន សេន មិនដែលឃើញនៅ ក-១ ទេ។

[០៩:៥៧:១៧]

**ស៖** សរុបទៅមានមនុស្សប៉ុន្មាននាក់ដែលធ្វើជាកងការពារ និង នីរសារនៅមន្ទីរក-១?

**ឆ៖** ចំនួនច្បាស់លាស់មែនទែន ខ្ញុំក្ដាប់មិនសូវបានទេ ព្រោះនៅខាងក្នុងបរិវេណហ្នឹង ប្រហែលជាចំនួនប្រហែល២០នាក់ ហើយនៅខាងក្រៅមិនដឹងជាចំនួនប៉ុន្មាន ខ្ញុំមិនអាចក្ដាប់បានដែរ។

**ស៖** តើតាមខ្ញុំយល់<ត្រឹមត្រូវទេ តាមចម្លើយរបស់លោក>នោះ លោកហ្នឹងគឺជាកងការពារម្នាក់ដែលការពារផ្នែកខាងក្នុង។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ នៅៗខាងក្នុងទេ។

**ស៖** តើលោកអាចចេះអានទេ លោកសាក្សី?

**ឆ៖** ចេះអានអក្សរខ្មែរ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារមួយទៅកាន់សាក្សី គឺ E3/ ឯកសារ E3/858 ដែលជាបញ្ជីឈ្មោះអ្នកបម្រើការងារនៅមន្ទីរ“ក” រួមទាំង ក-១ និង ក-៣ ផងដែរ។ សូមអនុញ្ញាតពីលោកប្រធានផ្តល់ឯកសារនេះ ជូនទៅសាក្សី លោកប្រធាន។

[០៩:៥៩:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី<ពីរទំព័រដំបូងនៃ>ឯកសារ E3/858 នេះ គឺមានបញ្ជីអ្នកដែលធ្វើការនៅ ក-១ និងមនុស្សមួយក្រុមទៀតធ្វើការនៅ ក-៣។ ខ្ញុំចង់សួរមនុស្សចំនួន១៦នាក់ ដែលគេរៀបចំជាបញ្ជីឈ្មោះឲ្យធ្វើការនៅ ក-១។ <ខ្ញុំបានគូសពណ៌ចំណាំនៅលើ>ឈ្មោះ<មួយចំនួន ដើម្បីឲ្យលោកងាយស្រួលរកមើល ហើយ>ខ្ញុំនឹងសួរលោក<អំពីអ្នកទាំងនោះ>។ ប៉ុន្តែឈ្មោះទី១ ដែលខ្ញុំសួរនៅលើបញ្ជីអ្នកធ្វើការនៅក-១ គឺលេខរៀងទី៥ ហៅ ថេង ឬក៏ ពូល។ តើ ថេង ហៅ ពូល នេះដែលមានលេខរៀង ៥ ជាលោកឬ? តើ ពូល ជាឈ្មោះមួយផ្សេងទៀត ឈ្មោះហៅក្រៅដែលលោកប្រើនៅក្នុងរបបនោះមែនទេ?

**ឆ៖** ពេលនោះ ខ្ញុំឈ្មោះ ពូល ហ្នឹងឯង។ ឈ្មោះ ថេង នេះគឺឈ្មោះក្រោយទេ។

[១០:០១:០៣]

**ស៖** នៅក្នុងបញ្ជីអ្នកដែលធ្វើការនៅ ក-១ គឺថា លោកត្រូវបានគេរាប់ថា ជាជំនួយការមួយខាងផ្នែកសរសេរអក្សរផ្សេងៗ។ តើនេះជាមុខងាររបស់លោកឬ នៅក-១ គឺលោកជាអ្នក ជាជំនួយការដែលជួយសរសេរកិច្ចការផ្សេងៗ អីចឹងមែនទេ លោកអាចជម្រាបជូនតុលាការលម្អិតបន្តិចបានទេ?

**ឆ៖** មិនមែនជាអ្នកជំនួយការអីទេ។

**ស៖** ប្រហែលជាអាចមានបញ្ហាដោយការបកប្រែឬក៏យ៉ាងណាក៏មិនដឹង។ តើត្រឹមត្រូវដែរឬទេ

ថា នៅពេលដែលលោកធ្វើការនៅ ក-១ <លោក>មិន<មែនជួយសរសេរ>ឯកសារជាលាយលក្ខណ៍អក្សរទេ <>គឺ<ប្រហែលជាលោក>ជួយចែកចាយឯកសារចេញពីក-១? <តើត្រឹមត្រូវទេដែលថាការងាររបស់លោកនៅ ក-១ គឺជួយចែកចាយឯកសារដែលផ្ញើចេញពី ក-១>?

**ឆ៖** ដូចជាមិនមានទេ ខ្ញុំមិនមានភារកិច្ចហ្នឹងផង។

**ប្រធានអង្គជំនុំ៖**

អាចមានការភាន់ច្រឡំ ពាក្យចែកចាយហ្នឹង វាអាចមានបញ្ហា វាអាចហួសពីកម្រិតនៃការបញ្ជូនសារ បញ្ជូនឯកសារ ក្នុងនាមឋានៈជានីរសារបញ្ជូនទៅអង្គភាពផ្សេងៗ អាហ្នឹងអាចខុសគ្នា។ ចែកចាយវាធំជាង។ មានវិសាលភាព នៃមុខងារវាធំជាងការបញ្ជូនក្នុងឋានៈជានីរសារ។ សូមបញ្ជាក់បញ្ហាឲ្យច្បាស់ព្រោះអាចច្រឡំគ្នាក្នុងការប្រើពាក្យ។

**សួរដោយលោក ឌេល លីសាក់៖**

សូមទោសលោកប្រធាន ប្រហែលនេះដោយសារតែការបកប្រែជាភាសាអង់គ្លេសទៅជាភាសាខ្មែរហ្នឹង។ ឥឡូវយើង<នឹង>និយាយភារកិច្ចជាក់លាក់របស់លោកនៅពេលបន្តិចទៀតនេះ។

**ស៖** ឥឡូវខ្ញុំសូមសួរលោកអំពីឈ្មោះមនុស្សមួយចំនួននៅលើបញ្ជីដែលនេះសិន។ មនុស្សទី១ដែលធ្វើការនៅក-១ លេខរៀងទី១ ហ្នឹងគឺឈ្មោះ លីន ដែលនៅទីនេះសរសេរថា ជាប្រធានរួម គឺសម្រាប់តាំងពី ក-១ ទៅដល់ ក-៤។ ហើយគាត់បានរៀបការហើយ ប្រពន្ធរបស់គាត់ ឈ្មោះ សែម។ សែម នេះជាស្ត្រីម្នាក់ដែលបានមកផ្ដល់សក្ខីកម្មពីមុននៅចំពោះមុខតុលាការយើងនេះ។ តើលោកនៅចាំបុគ្គលម្នាក់ឈ្មោះ លីន <នេះទេ គាត់ក៏ប្រើ>ឈ្មោះ កែន <ផងដែរ> ជាអនុប្រធាន<របស់ ប៉ង់>?

[១០:០៥:១០]

**ឆ៖** ស្គាល់។ ឈ្មោះ លីន ហ្នឹងខ្ញុំស្រពេចស្រពិលដែរ តែបើ តាន – តាន ទេឈ្មោះតាន ទេ មិនមែន កាន ទេ។ តាន បានត្រូវ។ តាន ហ្នឹងស្គាល់។ លីន ខ្ញុំដូចមិនស្គាល់។

**ស៖** តាន នេះគឺមានលេខរៀងទី២ នៅលើបញ្ជីអ្នកធ្វើការនៅក-១ តើលោកអាចបញ្ជាក់ជូនតុលាការបានទេ តាន នេះធ្វើអ្វីដែរ នៅឯមន្ទីរ ក-១ នោះ?

**ឆ៖** ឈ្មោះទាំងនេះគឺសុទ្ធតែអ្នកការពារនៅខាងក្នុងទាំងអស់។ គឺតួនាទីអ្នកការពារដែរ ដូចតែខ្ញុំដែរហ្នឹង។

**ស៖** ឥឡូវនិយាយអំពីឈ្មោះ លីន ដែលមានលេខរៀងទី១ ក្រោយៗពីបង្ហាញឈ្មោះរបស់

ប្រពន្ធគាត់មក ឯកសារហ្នឹងសរសេរថា "ប៉ង់ បានរៀបផ្សំផ្គុំអ្នកទាំងពីរនេះឲ្យរៀបការជាមួយគ្នា"។ ប៉ង់ ជាអ្នកផ្សំផ្គុំ ជាអ្នកការឲ្យ។ តើលោកនៅចាំទេថា ប៉ង់ បានរៀបចំរៀបការឲ្យអ្នកទាំងពីរនេះនៅ ក-១ ឬក៏នៅ "ក" ប៉ុន្មាន?

**ឆ៖** ការរៀបចំគ្រួសារឲ្យឈ្មោះលីន ហ្នឹង ខ្ញុំៗអត់ដឹងទេ មិនដឹងគេរៀបចំពីអង្គាល់ ខ្ញុំអត់ដឹងដែរ។

[១០:០៦:២៣]

**ស៖** តើនៅក្នុងរបបខ្មែរក្រហមលោកបានរៀបការហើយឬនៅ? ហើយប្រសិនណាជាលោកបានរៀបការ តើលោកបានរៀបការដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំបានរៀបការម្តងរួចហើយតាមរបៀបការពេញចិត្តរបស់ខ្ញុំ។

**ស៖** នៅពេលដែលលោកនិយាយថាលោកបានរៀបការម្តងរួចទៅហើយ តើមានន័យថាលោកបានរៀបការមុនពេលគេបញ្ជូនលោកមកភ្នំពេញនៅឆ្នាំ១៩៧៥ ឬក៏លោកបានរៀបការហ្នឹងក្រោយពេលលោកមកភ្នំពេញក្រោយឆ្នាំ១៩៧៥ ហើយនោះទេ?

**ឆ៖** ខ្ញុំរៀបការក្នុងអំឡុងពេលដែលខ្ញុំនៅ ក-១ ហើយ មកនៅ ក-១ ហើយ។

**ស៖** តើលោករៀបការជាមួយនារីម្នាក់ណាដែរ ហើយលោកស្គាល់នារីដែលលោកបានរៀប-ការជាមួយហ្នឹងដោយរបៀបណាដែរ?

**ឆ៖** ការស្គាល់នេះគឺ គេឧទ្ទេសនាមឲ្យយើងស្គាល់គ្នា ហើយការពេញចិត្ត ពេញថ្លើមគឺរៀងៗខ្លួន គឺថាអាចយកជាគ្នាបាន គឺគេរៀបការឲ្យ។

**ស៖** តើប្រពន្ធរបស់លោកគាត់ធ្វើការនៅមន្ទីរក-១ ដែរឬ?

**ឆ៖** បាទ មិននៅមន្ទីរក-១ ទេ គាត់នៅធ្វើការនៅក្រសួងសង្គមកិច្ចសុខាភិបាល។

[១០:០៨:៥៨]

**ស៖** បើអ៊ីចឹងអ្នកណាជាអ្នកណែនាំលោកឲ្យស្គាល់គាត់?

**ឆ៖** ប្រធាន គឺនិយាយនេះទៅគឺ អៀង ធីរិទ្ធ គាត់ៗណែនាំឲ្យស្គាល់។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងការរៀបការនេះ តើក្រោយពេលដែលគេណែនាំលោកឲ្យស្គាល់ប្រពន្ធរបស់លោកហ្នឹង ចាប់តាំងពីការណែនាំលើកដំបូងរហូតមកដល់ពេលរៀបការហ្នឹងមានរយៈពេលប៉ុន្មាន? ហើយអ្នកណាជាអ្នករៀបការឲ្យលោក?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គឺខ្ញុំរៀបការបានគ្នារហូតដល់ចេញពីភ្នំពេញ។ ហើយអ្នកដែលរៀបការឲ្យខ្ញុំ គឺអង្គភាពៗការពារហ្នឹង។

**ស៖** ចុះអ្នកណាមកចូលរួមធ្វើជាអធិបតីភាពនៅក្នុងពេលរៀបការឲ្យលោកនុ៎ង?

**ឆ៖** ក្នុងពេលហ្នឹងគឺមិនមានអីធំដុំទេ គ្រាន់អ្នកការពារដែលធ្វើការជាមួយគ្នាហ្នឹងគឺចូលរួម ដឹងឮទាំងអស់គ្នាហ្នឹង។

**ស៖** តើមានកងការពារដទៃទៀតបានរៀបការនៅពេល នៅចំពេលវេលាដែលលោករៀបការនោះដែរឬទេ? ហើយបើមាន តើមានសរុបទាំងអស់ហ្នឹងប៉ុន្មានគូទៅ?

**ឆ៖** មិនមានទេ មានតែមួយគូខ្ញុំហ្នឹង។

[១០:១១:២៨]

**ស៖** ខ្ញុំមិនទាន់បានទទួលចម្លើយទៅនឹងសំណួរមួយដែលខ្ញុំបានសួរហើយ គឺខ្ញុំសួរថា ក្រោយពេលគេណែនាំឲ្យលោកស្គាល់ប្រពន្ធលោកថា "នេះ! ត្រូវរៀបការជាមួយគ្នានេះ!" ក្រោយពេលគេនាំឲ្យស្គាល់ហើយ តើរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានសប្តាហ៍ ឬក៏ប៉ុន្មានខែទើបលោករៀបការ?

**ឆ៖** ហ្នឹងក្រោយពីខ្ញុំ ហើយនិងប្រពន្ធខ្ញុំត្រូវរ៉ូវគ្នាហើយ គេប្រហែលជាមួយអាទិត្យអីគេរៀប-ការ។

**ស៖** បាទ ឥឡូវត្រឡប់ចូលទៅបញ្ជីឈ្មោះអ្នកដែលធ្វើការនៅក-១ឡើងវិញ។ លេខរៀងទី៣នៃបញ្ជីឈ្មោះអ្នកធ្វើការនៅក-១ គឺឯកសារ E3/858 គឺមនុស្សម្នាក់ឈ្មោះ ស៊ិន ថាគាត់ហ្នឹងគឺជា "ប្រធានការពារ ពេលអ៊ំចេញដំណើរ"។ <តើលោកចាំបុគ្គលម្នាក់នេះទេ> តើលោកអាចជួយបញ្ជាក់បានទេថា ឈ្មោះ ស៊ិន នេះគាត់មានមុខងារធ្វើអ្វីដែរនៅមន្ទីរក-១នោះ?

**ឆ៖** តួនាទីអ្នកការពារនៅក្នុងក-១ហ្នឹងមាន ក្នុងការគ្រប់គ្រងរបស់ឈ្មោះ ប៉ង់។ ហើយឈ្មោះ ស៊ិន នេះគ្រាន់តែមិនប្រាកដថា ជាប្រធាន ឬក៏ជាអនុប្រធានទេ ព្រោះ ប៉ង់ ជាអ្នកបញ្ជាជាទូទៅ។

[១០:១៣:៤២]

**ស៖** សូមអរគុណចំពោះការបញ្ជាក់បំភ្លឺនេះ។ លេខរៀងទី៩ នៅលើបញ្ជីអ្នកធ្វើការនៅក-១នេះ បាទបើលោកមើលលេខរៀងទី៩នេះគឺឈ្មោះ ឡាំង ដែលគេថាជា "អ្នកបើកបរ បើកឡានឲ្យអ៊ំមកពីស្រុកគូលេន <តំបន់>១០៣" អាចជាព្រះវិហារ ឬក៏សៀមរាប។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក <ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត លោក>និយាយអំពីមនុស្សម្នាក់ឈ្មោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឡាំង ដែលជាអ្នកបើកបរឲ្យ ប៉ុល ពត។ តើនេះលេខរៀងទី៩ឈ្មោះ ឡាំង នេះដែរនេះ គឺជាអ្នកដែលលោកលើកឈ្មោះមកនិយាយ ហើយអ្នកដែលបើកបរឲ្យ ប៉ុល ពត ហ្នឹងឬ?

**ឆ៖** បាទ ឈ្មោះហ្នឹងហើយ។

**ស៖** ឥឡូវខ្ញុំចូលទៅអ្នកដែលធ្វើការនៅមន្ទីរក-៣វិញម្តង។ ហើយខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរលោក។ បើលោកមើលទៅក្រុម<បន្ទាប់ទៀត ក្រោយពីមនុស្ស១៦នាក់>នៅ<ក-១>នេះ--

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!។

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ជាបឋម ខ្ញុំសូមឆ្លើយតទៅនឹងការសាកសួរពីមេធាវីការពារក្តី ខៀវ សំផន មុននឹងបន្តិច។ យើងបាន ខ្ញុំបានពិនិត្យមើលផ្ទៀងផ្ទាត់ដូចដែលខ្ញុំបានបញ្ជាក់ដូច្នោះឯង។ ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ដែលគ្រោងនឹងមកផ្តល់សក្ខីកម្មបន្តិចទៀតនេះ ក្នុងពេលឆាប់ៗនេះ គឺវាដូចទៅនឹងពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២។ ហើយនៅក្នុងនោះ គឺមានការគូសចោល គឺ D22/194 ឯកសារដែលខ្ញុំបានផ្ទៀងផ្ទាត់នោះ។ គឺលេខនេះ គឺបានគូសចោល ហើយឯកសារនេះ គឺជាឯកសារតែ

មួយនោះទេ គ្រាន់តែមានការគូសលេខហ្នឹងចោល វាមិនមែនជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថ្មីដែលមកជំនួសឯកសារនេះឡើយ។

[១០:៣៣:២១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី យើងបានមើលលើកឯកសារបញ្ជីបុគ្គលិកនៅមន្ទីរ "ក" E3/858។ ហើយខ្ញុំសូមសួរចំពោះបុគ្គលិកដែលធ្វើការនៅ ក-៣។ <នៅត្រង់ទំព័រទី១> ដូចដែលខ្ញុំបានគូស*ហាយឡាយ*ឲ្យលោកបានឃើញហើយ នៅក្រោមផ្នែក ក-៣។ ក្នុងនោះចាប់ផ្ដើមដោយក្រុមហ្នឹង មានបួននាក់ដែលការពារអ៊ំទី២ អ្នកទាំងបួននោះ មានឈ្មោះដូចតទៅ៖ ទៀង, សុទ្ធ, ដាន និង វ៉ន។ ហើយក្រោយមកមានកងការពារបីនាក់ទៀត ការពារបងវ៉ាន់ ដែលជាឈ្មោះហៅក្រៅរបស់ អៀង សារី ហើយក៏មានក្រុមកងការពារ<ចំនួនបីនាក់ ការពារ> បងហែម ដែលជាឈ្មោះ ហៅក្រៅរបស់ ខៀវ សំផន។ អ្នកទាំងបីការពារ បងហែម នោះ មាន ទន, ហឿន និង សឿន។ សំណួរដំបូងរបស់ខ្ញុំ តើលោកស្គាល់អ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងអស់នេះដែរឬទេ ដែលជាកងការពារឲ្យ នួន ជា, អៀង សារី និង ខៀវ សំផន?

[១០:៣៤:៤៨]

**លោក សេង លីថេង៖**

**ឆ៖** បាទ ឈ្មោះៗទាំងអស់នេះ ខ្ញុំស្គាល់ ប៉ុន្តែអ្នកទាំងនេះមិនៗការពារនៅក-១ ហ្នឹងទេ។

**ស៖** តើតាមលោកយល់ អ្នកទាំងនេះជាកងការពារ គាត់ស្ថិតនៅ ធ្វើការនៅកន្លែងណាដែរដែលការពារ នួន ជា, ខៀវ សំផន និង អៀង សារី នោះ?

**ឆ៖** នៅក-១ គឺអ្នកការពារហ្នឹង គឺមានឈ្មោះដូចបានគូសនេះ ដូចជា តាន, ស៊ីន, សង់ អីហ្នឹងឡាំង។ ឯឈ្មោះ នៅក-៣ នេះមិនមែនការពារនៅក-១ ទេ ខ្ញុំមិនដែលឃើញមាននៅនោះទេ។

**ស៖** សូមអរគុណ។ ឈ្មោះចុងក្រោយដែលខ្ញុំចង់សុំសួរទៅកាន់លោក ក្រោយពីក្រុមការពាររបស់ បងហែម នេះក្រោមហ្នឹងគឺថា មានក្រុមកងការពាររបស់ បងវន។ <ហើយបន្ទាប់មកមានបញ្ជីមួយ មានឈ្មោះចំនួន១៥នាក់។> ប្រសិនបើលោកមើលទំព័រទី២ ជាភាសាខ្មែរ<នៃឯកសារនេះ> បាទសូមមើលទំព័រទី២ ទី១ ដែលនៅមន្ទីរក-៣ មានឈ្មោះ សាមី ប្រធានមន្ទីរក-៣ ដែលជាជនជាតិចារ៉ាយ។ តើលោកចាំទេ ហើយលោកស្គាល់បុគ្គលហ្នឹងឈ្មោះ សាមី នេះដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ឈ្មោះនេះខ្ញុំអត់ស្គាល់ទេ។

**ស៖** លោកបានលើកឡើងកាលពីព្រឹកមិញនេះថា លោកបានឃើញលេខាភូមិភាគមកក-១។ បាទ ឯកសារទាំងអស់នោះ ខ្ញុំលែងសួរទៀតហើយ ដូច្នេះលោកអាចទុកម្ដុំបាន។ លោកព្រឹកមិញបាន បញ្ជាក់ថា លោកបានឃើញលេខាភូមិភាគមកក-១។ តើលេខាភូមិភាគណាខ្លះដែលលោកនៅចាំថា បានមក ក-១?

**ឆ៖** គឺថាគណៈភូមិភាគ មិនមែនលេខាភូមិភាគទេ គឺគណៈភូមិភាគខ្លះមកធ្វើការនៅក-១ តាម ការហៅរបស់ ប៉ុល ពត។

**ស៖** គណៈភូមិភាគ តើតាមលោកចាំជាក់លាក់នោះ ជានរណាដែរ ដែលមកធ្វើការងារនៅក-១?

**ឆ៖** គណៈភូមិភាគដែលមក ដូចជាៗ គណៈភូមិភាគ ឈ្មោះ ធុច, អ៊ំពក នៅនិរតី និង តាម៉ុក និង សោ ភឹម។

[១០:៣៩:០៧]

**ស៖** លោកបានលើកឡើងឈ្មោះ ធុច។ តើធុច ជានរណាដែរ? តើក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យមានអ្វីកើតឡើងចំពោះគាត់ដែរ?

**ឆ៖** ធុច តាមខ្ញុំដឹង គាត់ជាគណៈភូមិភាគឧត្តរ ហើយរឿងរ៉ាវម៉េច ខ្ញុំក៏អត់ដឹង។

**ស៖** តើមានឈ្មោះមួយទៀតទេ សម្រាប់ ធុច នេះ ដែលគេស្គាល់ថា គាត់ឈ្មោះ កុយ ធួន នោះ?

**ឆ៖** ខ្ញុំអត់ដឹងទេ ឈ្មោះផ្សេងទៀត ខ្ញុំអត់ដឹងទេ។

**ស៖** ហើយចុះតើលោកចាំថា គេមានចាប់ឃុំខ្លួន ធុច <ទុកនៅក្នុងផ្ទះ>ដែរឬទេ នៅក-១ នៅក្នុងអំឡុងឆ្នាំ<១៩៧៦>?

**ឆ៖** ខ្ញុំអត់ដឹងដែរ។

**ស៖** លោកបានរៀបរាប់ឈ្មោះ សោ ភឹម, តាម៉ុក ដែលជាមនុស្សពីរនាក់ មកពីគណៈភូមិភាគ មក ក-១ ផងដែរ។ តើលោកធ្វើម្ដេចបានជាស្គាល់ថា ពួកគាត់ជា សោ ភឹម និង តាម៉ុក?

**ឆ៖** ជាៗទូទៅ គេៗស្គាល់ហើយ គណៈភូមិភាគ ដែលៗមកធ្វើការនៅទីនោះ អាចស្គាល់។

**ស៖** ខ្ញុំសូមសួរឈ្មោះរបស់មេដឹកនាំគណៈភូមិភាគមួយចំនួន ហើយខ្ញុំសាកសួរមើល តើលោក នៅនឹកឃើញដែរឬទេ។ តើលោកស្គាល់ រស់ ញឹម <លេខា>គណៈភូមិភាគពាយ័ព្យ<ដែរឬទេ>? តើ

លោកធ្លាប់ដែលឃើញ ញឹម នៅ ក-១ ដែរឬទេ?

[១០:៤២:០៧]

**ឆ៖** ខ្ញុំអត់ដែលឃើញដែរ។

**ស៖** តើលោកស្គាល់ឈ្មោះ យ៉ា ទេ ដែលជាលេខា ឬគណៈភូមិភាគឦសាននោះ តើលោកធ្លាប់ឃើញគាត់នៅ ក-១ ដែរឬទេ?

**ឆ៖** អត់ដែលស្គាល់ទេ។

**ស៖** ខ្ញុំសូមត្រឡប់សួរលោក ដែលខ្ញុំបានចាប់ផ្ដើមសួរលោកកាលមុននេះបន្តិច។ តើការទទួលខុសត្រូវរបស់លោកនៅ ក-១ រួមមានជា នីរសារដែលរត់សំបុត្រពី ក-១ ទៅតាមភូមិភាគដែរឬទេ?

**ឆ៖** កាលរត់សំបុត្រនោះ គឺមានមិនៗញឹកញាប់ទេ។ ខ្ញុំរត់សំបុត្រជូនទៅ សោ ភឹម ហ្នឹង ចំនួនជាបីដងតែប៉ុណ្ណោះ ឯភូមិភាគផ្សេង ខ្ញុំមិនដែលទៅទេ។

**ស៖** តើនរណាដែរ តាមដែលលោកដឹង ដែលជាអ្នករត់សំបុត្រជាប្រចាំ ឬញឹកញាប់ពី ក-១ ទៅតាមភូមិភាគ? ជានីរសារនៅក្នុងមន្ទីរក-១ហ្នឹង ឬក៏ជានីរសារដែលប្រចាំនៅទីក្រុងភ្នំពេញ? តើលោកដឹងទេ នរណាជាអ្នកកាន់ការងាររត់សំបុត្រអចិន្ត្រៃយ៍ជាញឹកញាប់ពីក-១ ទៅតាមភូមិភាគ?

[១០:៤៤:១៦]

**ឆ៖** ខ្ញុំអត់ដឹងច្បាស់ទេ នូវ -- ខ្ញុំក៏មិនដឹងច្បាស់ដែររឿងរត់សំបុត្រ រត់អី ទៅតាមភូមិភាគ ប៉ុន្តែចំពោះរូបខ្ញុំដែលរត់សំបុត្រទៅឱ្យ សោ ភឹម ហ្នឹង គឺប្រហែលជាក្នុងលក្ខណៈចាំបាច់អីមួយទេ ព្រោះការរាប់អានរបស់ ប៉ុល ពត និង សោ ភឹម ហ្នឹង គាត់ជិតស្និទ្ធណាស់។ ដូច្នេះគាត់អាចទុកចិត្តខ្ញុំ ក្នុងការប្រើរត់សំបុត្រទៅឱ្យ សោ ភឹម។

**ស៖** តើនរណាជាអ្នកប្រគល់លិខិតឱ្យលោកយកទៅប្រគល់ឱ្យ សោ ភឹម? តើលិខិតនេះអ្នកណាជាអ្នកសរសេរដែរ? ហើយនរណាជាអ្នកបញ្ជូនមកលោក?

**ឆ៖** លិខិតជាអ្នកសរសេរខ្ញុំមិនដឹងអ្នកណាសរសេរទេ គ្រាន់ថាសំបុត្រគឺបិទ គឺ ប៉ុល ពត ប្រគល់ឱ្យខ្ញុំផ្ទាល់ ហើយឱ្យយកទៅឱ្យផ្ទាល់។

**ស៖** នៅពេលដែលលោកដែល ប៉ុល ពត ប្រគល់ឱ្យលោកផ្ទាល់ ឱ្យរត់សំបុត្រទៅហ្នឹងនោះ តើគាត់ប្រាប់ឱ្យយកប្រគល់ផ្ទាល់ទៅឱ្យ សោ ភឹម នៅខាងភូមិភាគបូព៌ា មែនដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដណាស់។

**ស៖** ខ្ញុំសូមសួរលោក ចំណុចមួយទៀតពាក់ព័ន្ធនឹងការរត់សំបុត្រ ឯកសារ E3/462 កំណត់ហេតុ<ស្តាប់ចម្លើយលោកជាមួយនឹងការិយាល័យ>ចៅក្រមស៊ើបអង្កេត។ ខ្មែរ 00204025, អង់គ្លេស 00223564, បារាំង 00491960។ លោកបានពិពណ៌នាការងាររបស់លោកដែលយកសំបុត្រពីក-១ ទៅតាមភូមិភាគ។ លោកបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ “ប៉ុល ពត ផ្តល់ប្រគល់សំបុត្រឲ្យខ្ញុំយកទៅតាមភូមិភាគទៅឲ្យ កែ ពក និង ធុច”។ ហើយលោកអម្បាញ់មិញក៏បានបញ្ជាក់ផងដែរថា លោកធ្លាប់យកសំបុត្រយកទៅឲ្យ សោ ភឹម។ ដូច្នេះ ខ្ញុំសូមសួរបញ្ជាក់លោក តើលោកនឹកឃើញទេក្រៅពី សោ ភឹម មានពេលខ្លះទៀតនោះ គឺលោកក៏បានយកសំបុត្រទៅឲ្យ ធុច ឬក៏ កែ ពក ផងដែរ?

[១០:៤៧:៣២]

**ឆ៖** ខ្ញុំអត់ -- យកទៅឲ្យតែ សោ ភឹម ទេ ថ្នាក់ភូមិភាគបូព៌ា។ ឯ ធុច ហើយនិង អ៊ំពក ខ្ញុំអត់ដែលយកទៅឲ្យគាត់ទេ។

**ស៖** ពាក់ព័ន្ធទៅនឹងការដែលលោកប្រគល់សំបុត្រទៅឲ្យ សោ ភឹម។ តើលោកយកសំបុត្រទៅឲ្យ<>គាត់នេះបានន័យថា នៅដើមឆ្នាំនៃរបបនោះ <គឺក្នុង>ឆ្នាំ៧៦ ឬក៏នៅ<ពាក់កណ្តាលរបប គឺក្នុង>ឆ្នាំ៧៧ ឬក៏នៅចុងនៃរបបនោះឆ្នាំ៧៨ តើលោកនឹកឃើញទេក្នុងអំឡុងឆ្នាំណាដែរ ដែលលោកទទួលភារៈក្នុងការបញ្ជូនលិខិតនេះទៅឲ្យ សោ ភឹម?

**ឆ៖** ខ្ញុំចាំក៏មិនច្បាស់ដែរ ប្រហែលជា៧៨ – ប្រហែលជា៨៧។

**ស៖** ចំណុចមួយទៀត ខ្ញុំសូមសួរបញ្ជាក់ជាមួយនឹងលោក តើគេធ្លាប់ចាត់តាំងលោកឲ្យការពារមេដឹកនាំក្នុងអំឡុងពេលដែលពួកគាត់ធ្វើដំណើរទៅកាន់ភូមិភាគដែរឬទេ? តើប្រសិនបើលោកទទួលធ្លាប់ទទួលការងារហ្នឹងនោះ ការពារមេដឹកនាំទៅតាមភូមិភាគនោះ តើគេចាត់តាំងឲ្យលោកឲ្យធ្វើការងារហ្នឹងក្នុងឱកាសអ្វីដែរ?

**ឆ៖** ខ្ញុំជូនអ្នកដឹកនាំទៅតាមភូមិភាគតែៗ ប៉ុល ពត ទេ ក្នុង -- គាត់ទៅជួបគណៈភូមិភាគ ឬក៏ទៅមើលសំណង់ទំនប់ទឹក។

[១០:៥០:១០]

**ស៖** តើលោកចាំទេតំបន់ណា ឬក៏ទំនប់ណាមួយដែរ ដែលលោកទៅអមដំណើរជាមួយនឹង ប៉ុល ពត នៅក្នុងពេលដែលគាត់ទៅចុះទស្សនកិច្ចទំនប់ហ្នឹង ជាតំបន់ ឬទំនប់ឈ្មោះអ្វីដែរ?

**ឆ៖** ទំនប់៧មករា នៅខេត្តកំពង់ធំ ហើយនិងទំនប់នៅស្ទោង ខេត្តកំពង់ធំហ្នឹង។

01389744



**ស៖** តើលោកធ្លាប់អមដំណើរជាមួយនឹង ប៉ុល ពត ទៅទំនប់៦មករា ដែរឬទេ ដែលជាទំនប់នៅតាមដងស្ទឹងជីនិត ជាប់ព្រំប្រទល់រវាងខេត្តកំពង់ចាម និងកំពង់ធំ? តើលោកនៅចាំទេថា លោកធ្លាប់បានអមដំណើរទៅការដ្ឋានទំនប់៦មករា នេះជាមួយនឹង ប៉ុល ពត ដែរឬទេ?

**ឆ៖** ធ្លាប់ជូនគាត់ទៅទំនប់ ៦មករា ឬ ៧មករា ទេទំនប់ហ្នឹង ទំនប់នៅៗកំពង់ធំឯនេះ។

**ស៖** តើលោកអាចជម្រាបយើងទាំងអស់គ្នាដែរឬទេ តើ ប៉ុល ពត ទៅធ្វើអ្វីដែរ នៅពេលដែលគាត់ទៅទស្សនកិច្ចទំនប់នៅខេត្តកំពង់ធំនោះ?

**ឆ៖** មែនទែនទៅ ភាគច្រើនគាត់ទៅស្និទ្ធស្នាលជាមួយបងប្អូនដែលធ្វើការនៅនុ៎ង។ មិនដឹងគាត់ពិភាក្សារឿងអី ខ្ញុំក៏មិនដឹងដែរ ខ្ញុំគ្រាន់តែជាអ្នកការពារ។

**ស៖** តើ ប៉ុល ពត មានទៅចុះ<ជួប>ផ្ទាល់ និងជជែកជាមួយនឹងកម្មករនៅទំនប់នោះដែរឬទេ នៅពេលដែលគាត់ធ្វើទស្សនកិច្ចពេលនោះ?

**ឆ៖** ផ្ទាល់ គាត់ចុះទៅជួបផ្ទាល់ៗ។

**ស៖** តើកម្មករនៅតាមទំនប់ហ្នឹង រួមមានកុមារដែរឬទេ?

**ឆ៖** ខ្ញុំឃើញមានៗខ្លះដែរ ប៉ុន្តែដូចជាមិនឃើញច្រើនទេ។

[១០:៥៣:៤៥]

**ស៖** ចុះមានកងឈ្លបតាមដានការងាររបស់កម្មករនៅទំនប់ដែរឬទេ? ហើយប្រសិនបើមានឈ្លបនោះ តើមានអាវុធកាន់នឹងជាប់ខ្លួនទេ?

**ឆ៖** ឃើញមានកងឈ្លបដែរតើ។ មានអាវុធអា.កា អីកាន់ស្ពាយជាប់ខ្លួន។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ តាមអ្វីដែលលោកឃើញ ស្ថានភាពលក្ខខណ្ឌការងារ ឬក៏រូបរាងកាយរបស់កម្មករនោះយ៉ាងម៉េចដែរ? ពួកគាត់ស្គមស្គាំងដែរឬទេ? តើស្ថានភាពរាងកាយរបស់គាត់ហ្នឹងយ៉ាងម៉េចដែរ នៅតាមទីតាំង ទីកន្លែងការងារទាំងអស់នុ៎ង?

**ឆ៖** នៅពេលនោះ ខ្ញុំមិនបានពិនិត្យអីល្អិតល្អន់ណាស់ណាទេ ព្រោះការងារការពារហ្នឹងគឺជាបញ្ហាសំខាន់របស់ខ្ញុំហើយ។ ប៉ុន្តែគ្រាន់តែឃើញថា បងប្អូនប្រជាជន គេធ្វើការសស្រាក់សស្រាំ ដូចមិនមានបញ្ហាអីដែរ។

**ស៖** តើលោកទៅជាមួយនឹងប៉ុល ពត ហ្នឹងតែម្តង ឬក៏លោកធ្លាប់ទៅច្រើនលើកច្រើនសាដែរ?

**ឆ៖** ខ្ញុំអ្នកការពារគាត់ គាត់ជាញឹកញាប់ ខ្ញុំតែងតែទៅតាមគាត់រហូតហ្នឹង។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ចុះពេលខ្លះលោកធ្លាប់អមដំណើរការពារ ប៉ុល ពត រួមជាមួយនឹង នួន ជា ដែរឬទេ នៅពេលដែលពួកគាត់នោះ ធ្វើដំណើរទៅធ្វើជា ចូលរួមក្នុងពិធីថ្លែងសុន្ទរកថា <នៅមីទ្ទិង ឬវគ្គរៀនសូត្រ> នៅតាមភូមិភាគអ្វីដែរនោះ?

**ឆ៖** ថ្លែងសុន្ទរកថាដូចមិនដែលៗ មានកម្មវិធីហ្នឹងទេ។

[១០:៥៦:៥៧]

**ស៖** ខ្ញុំសាកព្យាយាម សាកល្បងមើល តើអាចឲ្យលោកនឹកឃើញដែរឬទេ គឺកិច្ចសម្ភាសន៍ដែលលោកបានឆ្លើយជូនចៅក្រមស៊ើបអង្កេត ឯកសារ E3/462 ខ្មែរ គឺមានលេខ 00204025 ហើយអាចនៅតទៅទំព័រ 26, បារាំង 00491960 ចូល បន្តចូលទៅដល់ទំព័រ 61, អង់គ្លេស 00223564។ លោកបានជម្រាបចៅក្រមស៊ើបអង្កេតនៅក្នុងកិច្ចសម្ភាសន៍ឆ្នាំ២០០៧ ដូចតទៅ ខ្ញុំសូមដកស្រង់៖ "ខ្ញុំដើរតាម ប៉ុល ពត ទៅបើក<វគ្គរៀនសូត្រ នៅ>តាមភូមិ<ភាគនានា និងចុះ>ទៅមើលការដ្ឋាន។ ប៉ុល ពត ចុះទៅផ្ទាល់។<>ប៉ុល ពត និង នួន ជា <បានចុះទៅវគ្គរៀនសូត្រ>។ ខៀវ សំផន និង អៀង សារី ខ្ញុំមិនដែលឃើញចុះទៅទេ។ វគ្គរៀនសូត្រ<> និយាយពីផែនការធ្វើស្រែចម្ការប៉ុន្មានហិកតាជាដើម។ ផែនការភូមិភាគ ជីវភាពប្រជាជននៅតាមភូមិភាគ ផែនការចារកម្មក្នុងភូមិភាគ ជាដើម"។ ហើយនៅក្នុងចំណុចពីរទៀតនៃកិច្ចសម្ភាសន៍ដែលលោកបានឆ្លើយ លោកបាន ក៏លើកឡើងអំពី នួន ជា ចុះទៅតាមភូមិភាគបើកវគ្គរៀនសូត្រផងដែរ។ តើលោកនឹកឃើញទេ លោកសាក្សី លោកនៅពេលនេះ នឹកឃើញហើយឬនៅថា ប៉ុល ពត និង នួន ជា បានធ្វើដំណើរទៅតាមភូមិភាគ ដើម្បីចូលរួមបើកវគ្គ<> រៀនសូត្រនៅទីនោះ?

**ឆ៖** កម្មវិធីបើកវគ្គសាលា ឬតាមភូមិភាគហ្នឹង ប៉ុល ពត មិនសូវជាចេញទេ មានតែ នួន ជា ដែលគាត់ទៅបើកសាលាតាមភូមិភាគ តាមតំបន់អីផ្សេងៗ។ ឯប៉ុល ពត គាត់បើកសាលា តែនៅបុរីកីឡាកន្លែងអប់រំ។

[១០:៥៩:៤៥]

**ស៖** តើ នួន ជា ទៅតាមភូមិភាគណាដែរ ដែលទៅធ្វើការបើកវគ្គរៀនសូត្រ<>នោះ?

**ឆ៖** ខ្ញុំភ្លាប់មិនបានទេ រឿងគាត់នៅខាងណា ខាងណី គាត់ -- ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកធ្លាប់អមដំណើរ នួន ជា នៅពេលដែលគាត់ទៅបើកវគ្គរៀនសូត្រនោះដែរឬទេ ឬក៏លោកមិនដែលអមដំណើរគាត់ទៅទេ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** មិនដែលទៅជាមួយ នួន ជា ទេ។

**ស៖** អ៊ីចឹង តើធ្វើម៉េចបានជាលោកដឹងថា នួន ជា ហ្នឹងចុះទៅបើកវគ្គរៀនសូត្រជាញឹកញាប់នៅតាមភូមិភាគនានា? លោកដឹងដោយរបៀបណា?

**ឆ៖** ជាធម្មតា គឺឲ្យតែគាត់ចាកចេញទៅរយៈពេលយូរ គឺលទ្ធភាពភាគច្រើនគឺទៅបើកសិក្ខាសាលានៅក្រៅ នៅខាងក្រៅហើយ តែទៅទីណាអី ខ្ញុំអត់ដឹងដែរ។

**ស៖** លោកសាក្សី ខ្ញុំសូមសួរលោកអំពីសម្រង់ដែលខ្ញុំដកស្រង់សម្ដីរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។ លោកបានផ្ដល់ព័ត៌មានលម្អិតអំពីប្រធានបទដែលគេបានយកមកពិភាក្សានៅក្នុងវគ្គរៀនសូត្រ។ ឥឡូវខ្ញុំសូមអានផ្នែកមួយនៃចម្លើយរបស់លោកឆ្លើយជូនអ្នកស៊ើបអង្កេត សូមដកស្រង់៖ "វគ្គរៀនសូត្រនិយាយអំពីផែនការធ្វើស្រែចម្ការ ឧទាហរណ៍ថាប៉ុន្មានហិកតា ផែនការភូមិភាគ ជីវភាពរស់នៅរបស់ប្រជាជននៅតាមភូមិភាគនានា និង<ផែនការចារកម្ម>នៅតាមភូមិភាគ ខ្ញុំមិនអាចចាំលម្អិតអំពីផែនការទាំងនោះ ទាំងអស់នោះបានទេ ប៉ុន្តែ<ពេលខ្លះ> គេលើកឡើងពីចំណុចនេះ។ <សំណួរ៖>តើលោកអាចនិយាយលម្អិតអំពីផែនការទាំងនេះ បានទេ? ឆ្លើយ៖ គេបាននិយាយអំពីខ្មាំង ហើយគេមានផែនការដើម្បីដោះស្រាយជាមួយនឹងខ្មាំង។" បញ្ចប់ការដកស្រង់ ហើយលោកបន្តឆ្លើយវែងឆ្ងាយទៅទៀត។ តើធ្វើដូចម្ដេចបានជាលោកដឹងអំពីប្រធានបទដែលគេបានយកមកពិភាក្សានៅក្នុងវគ្គរៀនសូត្រ? តើធ្វើម៉េចបានលោកដឹងថា នួន ជា <ឬ> ប៉ុល ពត បាននិយាយអំពីការធ្វើស្រែចម្ការ និងនិយាយអំពីខ្មាំង ក៏ដូចជាប្រធានបទមួយចំនួនផងទៀតនោះ ធ្វើម៉េចបានជាលោកដឹង?

**ឆ៖** ក្នុងកម្មវិធីរៀនសូត្រធម្មតា វាតែងតែឮហើយ វាមានមីក្រូ មានអីរបស់គេ។ ដូច្នេះ ខ្ញុំអាចឮខ្លឹមសារនោះខ្លះ ព្រោះខ្ញុំនៅការពារខាងក្រៅ អាចឮបានខ្លះដែរ។

[១១:០៣:៣២]

**ស៖** តើលោកឈរយាមនៅខាងក្រៅ ហើយដែលលោកអាចស្ដាប់បានផ្នែកខ្លះនៃប្រធានបទដែលយកនិយាយនៅក្នុងវគ្គរៀនសូត្រ តាមរយៈមីក្រូ លោកឈរហ្នឹង ឈរនៅកន្លែងណាដែរ?

**ឆ៖** ជារួមមិនមែនតែ នៅមួយកន្លែងទេ យើងដើរចុះដើរឡើង ច្រើនកន្លែង។

**ស៖** តើលោកកំពុងនិយាយអំពីទីតាំងនៅភ្នំពេញ ឬក៏ទីតាំងដែលលោកកំពុងនិយាយហ្នឹង គឺវានៅតាមបណ្ដាខេត្តនានា?

**ឆ៖** គឺទីតាំងក្នុងការអប់រំនេះគឺនៅបុរីកីឡាសព្វថ្ងៃហ្នឹង។ អាហ្នឹងជាកន្លែងអប់រំ ជាសាលា

អប់រំហើយ។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ នៅពេលដែលវគ្គរៀនសូត្រធ្វើនៅបុរីកីឡានោះ លោកគឺត្រូវឈរយាមនៅខាងក្រៅ ហើយលោកអាចស្ដាប់ឮពីប្រធានបទមួយចំនួនដែលគេលើកយកមកនិយាយនៅតាមមីក្រូនោះ អ៊ីចឹងមែនទេលោក?

**ឆ៖** បាទ គ្រាន់តែស្ដាប់បានមួយចំនួន ពុំមែនជាទូទៅទាំងស្រុងទេ។

**ស៖** ក្រៅពី នួន ជា តើមានមេដឹកនាំណាទៀតដែរ ដែលឡើងនិយាយនៅក្នុងវគ្គរៀនសូត្រនៅឯបុរីកីឡានោះ?

**ឆ៖** ជារួម គឺមានតែ ប៉ុល ពត និង នួន ជា ទេ ដែលជាអ្នកអប់រំនយោបាយនោះ។

[១១:០៦:២០]

**ស៖** នៅតាមដំណើរដែលលោកចុះទៅតាមខេត្តនានា តើលោកធ្លាប់ទៅភូមិភាគបស្ចិមដែរឬទេ? ជាពិសេស តើលោកធ្លាប់ទៅចូលរួមអង្គប្រជុំដែលគេធ្វើនៅក្នុងចម្ការដូង នៅស្រុកច្បារមន ខេត្តកំពង់ស្ពឺដែរឬទេ? តើលោកស្គាល់ នឹកឃើញ ឬក៏ស្គាល់ទីកន្លែងនេះទេ?

**ឆ៖** ខ្ញុំអត់ដែលទៅកន្លែងនោះទេ ហើយអត់ ក៏ៗមិនស្គាល់កន្លែងហ្នឹងដែរ។

**ស៖** បាទ ប្រធានបទ<ចុងក្រោយ ខ្ញុំចង់សួរលោក>ពីរបី<សំណួរ> តើលោកធ្លាប់ចូលក្នុងមហាសន្និបាតធំៗ ដូចជា ទិវាខួបជ័យជម្នះថ្ងៃ១៧មេសា ទិវាបង្កើតបក្ស ឬក៏មហាសន្និបាតធំៗ ធ្វើឡើងនៅស្ដាតអូឡាំពិក ដែលមេដឹកនាំឡើងនិយាយនោះ។ តើលោកធ្លាប់បានចូលរួមក្នុងព្រឹត្តិការណ៍ធំៗបែបនេះទេ ក្នុងឋានៈលោកអាចជាអ្នក ជាកងការពារ ឬក៏ជាអ្នក<ចូលទៅអង្គុយស្ដាប់បទបង្ហាញ>នោះ?

**ឆ៖** បាទ តាមពិតទៅ កាលចូលរួមនោះ ខ្ញុំមិនដែលចូលរួមក្នុងកម្មវិធីធំៗហ្នឹង គ្រាន់តែ ចុះនៅៗការពារអ្នកដឹកនាំ ម៉េចនឹងបានទៅចូលរួមកម្មវិធីហ្នឹងកើត យើងនៅការពារហ្នឹង។

**ស៖** នៅពេលដែល ប៉ុល ពត ឬក៏ នួន ជា ឬក៏ ខៀវ សំផន ត្រូវទៅឡើងថ្លែងនៅក្នុងព្រឹត្តិ-ការណ៍ខួបជ័យជម្នះបែបហ្នឹងនេះ តើលោក<ទៅ>ក្នុងនាមជាកងការពារ<សម្រាប់មេដឹកនាំ>ឬ<>?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាល់ទាន់ឆ្លើយ!

**លោក សេង លីថេង៖**

**ឆ៖** ខ្ញុំអត់ដែលបានចូលរួមទេ កម្មវិធីហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:០៩:០៧]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** តើលោកដឹងថា អ្នកយាមដទៃទៀតទៅពីក-១ហ្នឹង ត្រូវបានចាត់តាំងឲ្យទៅការពារដែរឬទេ នៅពេលដែល ប៉ុល ពត, នួន ជា ឬក៏ ខៀវ សំផន ទៅថ្លែងនៅក្នុងខួបទាំងនេះនៅស្តាតអូឡាំពិក? ឬក៏ខ្ញុំសួរម្យ៉ាងទៀតថា បើពួកគាត់ទាំងហ្នឹងទៅចូលរួមថ្លែងក្នុងព្រឹត្តិការណ៍បែបនេះ គេចាត់តាំងឲ្យអ្នកណាទៅយាមកាមពួកគាត់?

**ឆ៖** ក្នុងកម្មវិធីហ្នឹង ខ្ញុំៗមិនដឹងជាអ្នកណាជាអ្នកចាត់តាំងទេ ប៉ុន្តែជារួម គឺមានតែឈ្មោះ ប៉ង់ទេ ដែលៗជាអ្នកចាត់តាំង អ្នកការពារផ្សេងៗទៅតាមអ្នកដឹកនាំ។

**លោក ខេល លីសាក់៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេ-ណីដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

[១១:១០:២៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម អង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនតូចទេដើម្បីសួរបញ្ជាក់បន្ថែមទៅលោកសាក្សី។ ជាបឋមចង់សុំសួរពាក់ព័ន្ធទៅនឹងអាងទឹកដែលនៅ -- ទំនប់ទឹកដែលនៅខេត្តកំពង់ធំ លោកអាចបញ្ជាក់បានទេ ទំនប់ទឹកនោះដែលលោកមានប្រសាសន៍ថា ៧មករា នោះថា តើវានៅកន្លែង -- វាកាត់ មានស្ទឹងណាដែលហូរកាត់តាមទីនោះ? ព្រោះអាចស្ទឹងៗជីនិត ឬក៏ជាស្ទឹងតាំងក្រសាំង លោកអាចបញ្ជាក់បានទេ?

[១១:១១:១២]

**លោក សេង លីថេង៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខួបកប្រែ និងខួបកប្រែបន្ត។*

**ឆ៖** ស្ទឹងជីនិត។ មិនដឹង ៦មករា ឬ ៧មករា អាហ្នឹងខ្ញុំភ្លេច ប៉ុននៅស្ទឹងជីនីត។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញៗ លោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ តាមខ្ញុំចាំអង្គហេតុខាងដើមគាត់ឆ្លើយថា ទំនប់៦មករា ទេ មិនមែន ៧មករា ទេ។ សូមអរគុណ។

**សួរដោយលោក ពេជ អង្គ៖**

បាទ អរគុណ។ លោកសាក្សីគាត់បានឆ្លើយស្ទឹងជីនិតរួចហើយ។

**ស៖** អ៊ីចឹងលោកធ្លាប់ឮស្ទឹង -- ទំនប់ ១មករា ទេ? លោកធ្លាប់ឮឈ្មោះទំនប់១មករា ទេ?

**លោក សេង លីថេង៖**

**ឆ៖** អត់ដែលឮដែរ។

**ស៖** ខ្ញុំឮអត់សូវច្បាស់ សូមលោកជួយបញ្ជាក់បន្ថែមតិច។ លោកធ្លាប់ឮទំនប់ហ្នឹងទេ ១មករា?

**ឆ៖** ទំនប់១មករា ខ្ញុំៗអត់ដែលឮផង មិនដឹងនៅណា។

**ស៖** បាទ អរគុណ។ ចង់សូមសួរបញ្ជាក់បន្តិចទៀតពីបញ្ហាហ្នឹង។ ទំនប់ដែលលោកមានប្រសាសន៍ហ្នឹង ជាៗអាង -- ជាកន្លែង ការដ្ឋានដែលគេធ្វើហ្នឹងវាជាៗការដ្ឋានធំតែម្តង ឬក៏វាជា -- គ្រាន់តែជាប្រឡាយទឹក?

[១១:១២:៥៣]

**ឆ៖** ជាទំនប់ធំហ្នង ជាទំនប់ធំ កាត់ៗស្ទឹងជីនិតហ្នឹង។

**ស៖** អ៊ីចឹងវាជាអាង ជាកន្លែងដែលគេធ្វើសម្រាប់ជាអាងស្តុកទឹកមែនទេលោក?

**ឆ៖** អាហ្នឹងជាៗអាងក៏ប្រើបាន ហើយពេលទឹក តែនេះគេបង្ហូរមកក្រោមតាមស្ទឹង។

**ស៖** បាទ អរគុណ។ ខ្ញុំចង់សុំសួរបញ្ជាក់បន្ថែមទៅលើការរៀបការរបស់លោក។ ខាងសហព្រះរាជអាជ្ញាបានសួរលោកប៉ុន្មានសំណួរពាក់ព័ន្ធនឹងបញ្ហានេះហើយ ខ្ញុំនឹងសួរបញ្ជាក់លោកបន្ថែមតិចអំពីបញ្ហាហ្នឹង។ គ្រួសាររបស់លោកដែលគាត់ធ្វើការនៅក្រសួងសង្គមកិច្ចជាមួយលោកស្រី អៀង ធីរិទ្ធ ហ្នឹង តើលោកអាចបញ្ជាក់បានទេកាលនោះគាត់ធ្វើការងារអីមុនពេលរៀបការជាមួយលោកហ្នឹង? ឬក៏ថាពេលរៀបការជាមួយលោកហ្នឹង?

**ឆ៖** គាត់ជាអ្នកដាំស្លឲ្យៗ អៀង ធីរិទ្ធ។

**ស៖** បាទ សូមអរគុណ។ ចំពោះលោកវិញ ពេលដែលសម័យនោះ ថាតើលោកមានភាពជិតស្និទ្ធជាមួយលោកស្រី អៀង ធីរិទ្ធ ប៉ុនណាដែរ?

**ឆ៖** មិនមានការជិតស្និទ្ធអីទេ ព្រោះពួកគាត់នៅៗអង្គភាពសង្គមកិច្ចហ្នឹងវានៅឆ្ងាយគ្នាដែរ។

**ស៖** មុននេះលោកបានមានប្រសាសន៍ថា លោកស្រី អៀង ធីរិទ្ធ បានណែនាំប្រពន្ធលោកដើម្បីឲ្យមករៀបការជាមួយលោក។ ហើយលោកអាចបញ្ជាក់បានទេ គាត់ណែនាំដើម្បីឲ្យមកស្គាល់គ្នារៀបការជាមួយគ្នាហ្នឹង ថាតើគាត់ណែនាំដោយសារ គាត់ជាសាច់ញាតិរបស់លោក ឬក៏ថាដោយសារជា គាត់ធ្វើការនៅទីនោះ ហើយតួនាទីរបស់គាត់ៗត្រូវតែ គាត់ៗណែនាំ គាត់រៀប ស្នើឲ្យមានការរៀបការអ៊ីចឹងតែម្តង? អាចបញ្ជាក់បានទេ?

[១១:១៥:៤៥]

**ឆ៖** បញ្ហាហ្នឹងគឺ ពេលណាដែលយើងចង់បានគ្រួសារ គឺស្នើទៅអង្គភាព ដូចជាអង្គភាពការពារអ៊ីចឹង ហើយអង្គភាពការពារនឹងស្នើទៅអង្គភាពណាមួយ ដើម្បីមើលនារីណាដែលអាចជ្រើសរើសបាននោះ។

**ស៖** ហើយនៅពេលដែលលោកស្នើរៀបការ -- ករណីលោកៗស្នើរៀបការតែម្តង ឬក៏ថាគេណែនាំមកលោកតែម្តងថា លោកដល់ពេលរៀបត្រូវការហើយ គេត្រូវផ្គូផ្គងជូនលោក? ដូច្នេះតើករណីហ្នឹង មួយណា ករណីលោកហ្នឹង?

**ឆ៖** នេះជាការចំណង់របស់ខ្ញុំក៏ម្យ៉ាង ប៉ុន្តែពេលខ្លះអង្គភាពជំរុញ ថាគួរគិតគូរយកគ្រួសារហ្នឹងហើយ។ អាហ្នឹងបានគេសួរយើង ចិត្តយើងសម្រេចយ៉ាងម៉េច បើយើងឯកភាព អាហ្នឹងគេគិតគូរតាមហ្នឹង។

**ស៖** អម្បាញ់មិញ លោកមានប្រសាសន៍អំពីថា អង្គភាពជំរុញឲ្យគិតគូរពីរឿងគ្រួសារ។ ថាតើការជំរុញហ្នឹង វាជាការជំរុញដែលមានការណែនាំពីថ្នាក់លើកថា ឲ្យត្រូវតែមានគ្រួសារដល់ពេលអាយុណាមួយអ៊ីចឹងតែម្តង ឬយ៉ាងម៉េច?

**ឆ៖** តាមគំនិតក្នុងអង្គភាព ដែលបែបគេមើលថាយើងវាល្មមយកគ្រួសារហើយ គេសាកសួរចិត្តយើងថា ចង់បានគ្រួសារហើយឬនៅអី ម៉េចៗអ៊ីចឹងទៅ បានគេគិតគូរតាមហ្នឹងទៅ។

[១១:១៨:២៧]

**ស៖** អរគុណច្រើន។ ពីដំបូងលោកមានប្រសាសន៍ថា លោកស្រី អៀង ធីរិទ្ធ បានណែនាំឲ្យស្គាល់លោក ហើយនិងប្រពន្ធលោក ណែនាំឲ្យស្គាល់គ្នា។ លោកអាចបញ្ជាក់បានទេ ហេតុអ្វីបានលោកថា លោកស្រី អៀង ធីរិទ្ធ ជាអ្នកណែនាំ?

**ឆ៖** ដូចខ្ញុំបាននិយាយអំមិញអ៊ីចឹងគឺ អង្គភាពឃើញថាយើងល្មមយកគ្រួសារហើយ គឺគេស្នើទៅថ្នាក់លើទៅ វាមើលទៅវាសាកសមរម្យ ហើយគេជម្រើសរើសកន្លែងណាមួយដើម្បីពិនិត្យមើលនារីណាមួយដែលសមរម្យហ្នឹង បានអង្គភាពហ្នឹងគេយកយើងទៅសួរណែនាំទៅ បើយើងពេញចិត្ត ឬមិនពេញចិត្ត បើយើងពេញចិត្ត គេរៀបចំទៅតាមហ្នឹង។

**ស៖** ខ្ញុំនៅតែអត់ទាន់ច្បាស់នៅឡើយ។ អម្បាញ់មិញលោកមានប្រសាសន៍ថា ទាល់តែ -- អង្គ-ភាពជាអ្នកណែនាំ ហើយតែលោកបានភ្ជាប់ទៅឈ្មោះរបស់លោកស្រី អៀង ធីរិទ្ធ ថា លោកស្រី អៀង ធីរិទ្ធ ជាអ្នកណែនាំលោកឲ្យស្គាល់នារីម្នាក់ហ្នឹង។ តើលោកអាចបញ្ជាក់បានទេ ហេតុអីបានជាលោកនិយាយថា គឺលោកស្រី អៀង ធីរិទ្ធ ជាអ្នកណែនាំ គឺដោយសារថាមានលិខិតមានអីចេញពីលោកស្រី អៀង ធីរិទ្ធ ឬក៏ថាលោកបានឮលោកស្រី អៀង ធីរិទ្ធ និយាយប្រាប់លោក ឬក៏ណែនាំយ៉ាងម៉េចដោយផ្ទាល់មាត់ ឬក៏យ៉ាងម៉េច?

[១១:២០:២៥]

**ឆ៖** បញ្ហានេះគឺ បើអង្គភាព ហើយនិងអង្គភាពការពារហ្នឹង ហើយនិងអង្គភាពសង្គមកិច្ចគេមាន តម្រូវជ្រើសរើសនារីណាមួយហើយ ដូច្នេះ ប្រធានអង្គភាពហ្នឹង គឺត្រូវហៅសាមីខ្លួនទៅជួបណែនាំ ព្រោះនារីៗទាំង គឺការគ្រប់គ្រងរបស់ៗ អៀង ធីរិទ្ធ ហ្នឹង ជាចុងភៅរបស់គាត់។

**ស៖** អ៊ីចឹងចង់សួរបញ្ជាក់ថា តើមានបែបបទអនុវត្តជាទូទៅទេ ដែលប្រធានអង្គភាពត្រូវតែរៀបចំ ឬក៏ស្នើឲ្យមានការរៀបការបែបនេះកើតឡើងនៅក្នុងសម័យនោះ ថាតើវាជាការអនុវត្តជាទូទៅ ឬក៏ថាមានគោលនយោបាយស្អីដែលលោកដឹងអំពីរឿងហ្នឹងដែរឬទេ ដែលថាប្រធានអង្គភាពត្រូវតែរៀបចំអំពីការរៀបការ -- អំពីការផ្គូផ្គងហ្នឹង?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក សេង លីថេង៖**

**ឆ៖** ការផ្គូផ្គងមាន ដូចថាយើង អង្គភាពគេមើលថា គួរឲ្យមានគ្រួសារ អ្នកណាត្រូវគួរឲ្យមាន

អ្នកណាមិនទាន់មាន ទៅតាមកម្រិតគេដែរ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមអធ្យាស្រ័យ ខ្ញុំហាក់ដូចជា មិនទាន់បានចម្លើយច្បាស់លាស់ ថាតើជាការអនុវត្តទូទៅនៅរបបនោះតែម្តង ដែលថាប្រធានអង្គភាពជាអ្នកត្រូវផ្គូផ្គង? ឬក៏ថាលោកមានធ្លាប់ឮអំពីគោលនយោបាយណាមួយថា ប្រធានអង្គភាពត្រូវតែជាអ្នកត្រូវផ្គូផ្គងសម្រាប់អ្នកដែលមានអាយុប៉ុនណា អាយុប៉ុន្នានៗអ៊ីចឹងទៅ ថាតើគ្មានគោលនយោបាយ ឬជាគោលនយោបាយ ឬក៏ជាការអនុវត្តជាទូទៅ?

[១១:២៣:១១]

**ឆ៖** ខ្ញុំដូចមិនដែលឮមានគោលនយោបាយ អាយុប៉ុណ្ណោះត្រូវរៀបការ អាយុប៉ុណ្ណោះត្រូវរៀបការទេ។ បើទៅតាមខ្ញុំពិនិត្យមើលទៅ ប្រហែលជាគេសម្លឹងមើលយើង សមត្ថភាពត្រូវមានគ្រួសារដែរអីហ្នឹង គឺគេអនុវត្តអ៊ីចឹងតែម្តង។

**ស៖** អរគុណច្រើន។ ខ្ញុំនៅសល់ពីរបីសំណួរទៀតសម្រាប់សួរ តែនៅលើបញ្ហារៀបការដដែល។ នៅមុនពេលដែលលោកស្រី អៀង ធីរិទ្ធ ណែនាំឲ្យលោកស្គាល់នារីម្នាក់ហ្នឹង ថាតើលោកមានបានធ្លាប់ឃើញគ្នាពីមុនទេ?

**ឆ៖** មិនដែលធ្លាប់ឃើញទេ។

**ស៖** បាទ ហើយក្នុងពេលដែលលោករៀបការហ្នឹង មាន លោកមាន បានមានប្រសាសន៍ថា គឺមានអ្នកដែលនៅក្នុងអង្គភាពរបស់លោកហ្នឹងបានចូលរួម ហើយដោយសារថាជាការរៀបការរវាងលោកនៅក្នុងអង្គភាពមួយ ហើយនិងភរិយារបស់លោកចេញពីអង្គភាពផ្សេងមួយទៀត។ ថាតើមានថ្នាក់ដឹកនាំរបស់អង្គភាពទាំងពីរហ្នឹងគេមកចូលរួមដែរទេ ពេលនោះ?

**ឆ៖** មិនមានអង្គភាពផ្សេងមកចូលរួមទេ ពេលៗដែលសាមីខ្លួន ហើយនិងអង្គភាពទាំងពីរឯកភាពគ្នា គឺគេប្រគល់នារីហ្នឹងមកឲ្យខាងអង្គភាពខ្ញុំនេះហើយ។ ដូច្នេះ មិនមានអង្គភាពខាងសង្គមកិច្ចមកចូលរួមទេ។

[១១:២៥:១៨]

**ស៖** ពេលនោះមានពិធី -- ការរៀបចំជាពិធីអ្វីទេលោក?

**ឆ៖** ពិធីមានតែហូបចុកអីបន្តិចបន្តួច ហើយមានការណែនាំ ផ្តាំផ្ញើអី ឲ្យចេះស្រឡាញ់គ្នាយូរអង្វែងអីដូចជាយើងអ៊ីចឹងដែរហ្នឹង។

**ស៖** បាទ អរគុណ។ លោកមានប្រសាសន៍អម្បាញ់មិញពីការណែនាំផ្តាំផ្ញើហ្នឹង លោកអាចនៅចងចាំទេ គេណែនាំយើងយ៉ាងដូចម្តេចខ្លះ ហើយគេមានបាននិយាយថា ហេតុអ្វីបានឲ្យយើងរៀបការ អីជាមួយគ្នាអ៊ីចឹងទេ? លោករៀបការជាមួយគ្នា ហើយមាន -- គេមាននិយាយថាហេតុអ្វីបានឲ្យរៀបការជាមួយគ្នាអ៊ីចឹងទេ?

**ឆ៖** ការណែនាំ មិនមានអីធំដុំ ឲ្យចាប់ដៃគ្នាទៅ ខំកសាងជីវិតជាប្តីប្រពន្ធទៅ ហើយខំធ្វើការងារជូនជាតិ ជូនប្រជាជនតែប៉ុណ្ណឹង។

**ស៖** សំណួរមួយចុងក្រោយរបស់ខ្ញុំ ថាតើពេលនោះ គេមានណែនាំអំពីការដែលថា គូស្វាមីភរិយាហ្នឹង ត្រូវរស់នៅជាមួយគ្នា ហើយខំបង្កើតកូនដើម្បីបម្រើបដិវត្តន៍អីដែរទេ?

**ឆ៖** គេអត់មានណែនាំអ៊ីចឹងផង។

**លោក ពេជ អង្គ៖**

បាទ អរគុណច្រើន លោកសាក្សីដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក ថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងមេធាវី ប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

01389754



*(សវនាការសម្រាកពីម៉ោង ១១:២៨ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុនផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីមានបំណងក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះពីរបីសំណួរ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមិនសូវយល់ លោកប្រធាន។ គួរផ្តល់វេទិកានេះ ជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬក៏យ៉ាងម៉េច លោកប្រធាន? <ប៉ុន្តែខ្ញុំយល់ថា គេបានបញ្ចប់ការសួររួចហើយ។ តើខ្ញុំយល់ត្រឹមត្រូវទេ?>

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំបានជម្រាបមុនថា ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

[១៣:៣២:៤៣]

**ប្រធានអង្គជំនុំ៖**

អស់ទាំងសំណួរ អស់ទាំងពេលវេលា។ សុំក៏មិនឲ្យដែរ។ ច្បាស់លាស់ហើយ ផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដូចជាច្បាស់ហើយ ព្រោះលោកសុំខ្ញុំ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរលោក។ ខ្ញុំចង់សួរលោក ពាក់ព័ន្ធនឹងសកម្មភាពរបស់លោក ក្នុងដើមរបបកម្ពុជាប្រជាធិបតេយ្យ។ លោកថា មុនពេលលោកទៅធ្វើការនៅ ក-១ លោកធ្វើការនៅស្ថានទូត ឬនៅជិតស្ថានទូតចិន។ ហើយលោកទទួលបន្ទុកក្នុងការសម្របសម្រួលទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យនិងចិន។ ខ្ញុំយល់ចម្លើយហ្នឹង ត្រឹមត្រូវទេ អ្វីដែលលោកឆ្លើយ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កាលពីព្រឹកមិញហ្នឹង?

[១៣:៣៣:៤៦]

**លោក សេង លីថេង៖**

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** លោកធ្វើការនៅជាមួយនឹងស្ថានទូតចិនហ្នឹង អស់រយៈពេលប៉ុន្មានដែរ? មួយខែ ច្រើនខែ ឬក៏ប៉ុន្មានខែ? ឬក៏មួយឆ្នាំ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ ប្រហែលជិតមួយឆ្នាំៗដែរ។

**ស៖** តាមរយៈចម្លើយរបស់លោកកាលពីព្រឹកមិញ ខ្ញុំយល់ថា លោកទទួលបន្ទុកផងដែរ ក្នុងការទទួលភ្ញៀវ ជាពិសេសនុំង គឺភ្ញៀវចិន។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ អ្នកបច្ចេកទេសចិន។

**ស៖** ចុះឥស្សរជនជាន់ខ្ពស់ចិន លោកមានធ្លាប់បានទទួលទេ? ក្រៅពីអ្នកបច្ចេកទេស <តើមាន>មេដឹកនាំធំៗ ឬក៏ឥស្សរជនជាន់ខ្ពស់សំខាន់ៗ<ពីប្រទេសចិន> ដែលមកទស្សនកិច្ចនៅកម្ពុជានុំង លោកធ្លាប់ទទួលពួកគាត់ទេ?

[១៣:៣៥:០៨]

**ឆ៖** នៅ -- ទទួលទេ។

**ស៖** ខ្ញុំនឹងប្រាប់ឈ្មោះមួយចំនួន ហើយលោកប្រាប់ខ្ញុំថាលោកស្គាល់ឈ្មោះឬក៏អត់។ យ៉ុង ជុង គីវ លោកធ្លាប់ឮឈ្មោះហ្នឹងទេ?

**ឆ៖** ខ្ញុំមិនអាចចាំបានទេ ឈ្មោះស្ថានទូតចិនអី។

**ស៖** អឹង យឹងគួយ លោកធ្លាប់ស្គាល់ឈ្មោះហ្នឹងទេ ឬក៏ ឆេង យ៉ុងគី ជាអ្នកទទួលបន្ទុកសហករណ៍*ហ្សាតហ្សាយ*នៅចិន ហើយពេលដែលគាត់មកស្រុកខ្មែរហ្នឹងគេហៅគាត់ថា តាចាយ លោកធ្លាប់ឮឈ្មោះគាត់ទេ?

**ឆ៖** ឈ្មោះៗ តាចាយ ធ្លាប់ឮ។

**ស៖** លោកនឹកឃើញថា តាចាយ មកទស្សនកិច្ច<រយៈពេលពីរបី>សប្តាហ៍នៅកម្ពុជាប្រជាធិបតេយ្យ ទេ ហើយពេលដែលគាត់មកទស្សនកិច្ចហ្នឹងគឺ ប៉ុល ពត ជាអ្នកអមដំណើរគាត់។ លោកមាននឹកឃើញទេ?

**ឆ៖** ពេលនោះខ្ញុំមិនបានទៅជិតដិតនឹងការទស្សនកិច្ចរបស់ តាចាយ ហ្នឹងផ្ទាល់ទេ។ ដូច្នេះ ខ្ញុំមិនអាចក្ដាប់បានទាំងស្រុង។

[១៣:៣៧:១៦]

**ស៖** បាទ ឈ្មោះចុងក្រោយ កង ឆេង។ លោកធ្លាប់ឮឈ្មោះហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ចាំដែរ។

**ស៖** បាទ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកគឺ E3/462 លោកបានឆ្លើយថា លោកបានជូនដំណើរ ប៉ុល ពត ពេលដែលគាត់ទៅទស្សនកិច្ចនៅចិន និងកូរ៉េខាងជើង។ គឺនៅចម្លើយទី១៣ និង១៨ នៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោក។ លោកចាំថាលោកពិតជាបានជូនដំណើរ ប៉ុល ពត ពេលដែលគាត់ទៅទស្សនកិច្ចនៅចិន និងនៅកូរ៉េខាងជើងហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំបានជូនដំណើរគាត់ទៅទាំងពីរប្រទេសហ្នឹងមែន។

**ស៖** ពេលលោកទៅចិន លោកទៅតែម្ដង ឬក៏ទៅច្រើនដង? ហើយលោកចាំទេលោកទៅកន្លែងណាខ្លះ ហើយលោកបានជួបអ្នកណាខ្លះនៅចិនហ្នឹង?

**ឆ៖** ខ្ញុំទៅប្រហែលជាពីរដងដែរ ជូន ប៉ុល ពត ទៅ។ ហើយសមាសភាពចិន ខ្ញុំៗមិនស្គាល់ទេ។ សមាសភាពស្អីខ្លះអត់ចាំបានទេ។

[១៣:៣៩:៣៤]

**ស៖** លោកទៅមើល លោកទៅតែទីក្រុងប៉េកាំង លោកឬក៏លោកទៅទីក្រុងណាផ្សេង ឬក៏លោកទៅមើលនៅការដ្ឋានឬក៏សហករណ៍ណាផ្សេង?

**ឆ៖** ជាៗរួមគឺ ការទស្សនកិច្ចគឺ ជួបអ្នកដឹកនាំផ្សេងៗហ្នឹងហើយ ទៅទស្សនកិច្ចតាមរោងចក្ររោងអីហ្នឹង ដូចមិនមានទេ។

**ស៖** ពេលដែល ប៉ុល ពត គាត់ជួបសន្ទនាគ្នាជាមួយមេដឹកនាំជាន់ខ្ពស់ចិននោះ លោកមានបានចូលរួមទេ?

**ឆ៖** ខ្ញុំអត់បានចូលរួមទេ។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកគឺ E3/462 លោកបានឆ្លើយថាលោកបានជូន អៀង សារី ទៅវៀតណាម។ លោកចាំទេ ហើយត្រឹមត្រូវទេ លោកពិតជាបានជូនលោក អៀង សារី ទៅវៀតណាមមែនដែរឬទេ? ហើយបើជូនទៅហ្នឹង ជូនទៅនៅឆ្នាំណា?

**ឆ៖** បាទ ខ្ញុំបាន១ជូនតា អៀង សារី ទៅវៀតណាម ហើយនៅឆ្នាំ៧៨ -- ឆ្នាំ៧៤អ៊ីចឹង ខ្ញុំទៅៗតាមទៅតាមកប៉ាល់នៅស្ទឹងត្រែង។

**ស៖** បាទ ដើម្បីបញ្ជាក់ចំណុចនេះឲ្យច្បាស់ លោកទៅ<វៀតណាម>ជាមួយ អៀង សារី ហ្នឹងមុនពេលវាយយកទីក្រុងភ្នំពេញបាន ឬក្រោយពេលវាយយកទីក្រុងភ្នំពេញបាន?

[១៣:៤២:១៨]

**ឆ៖** មុនវាយយកក្រុងភ្នំពេញ ទៅមុន។

**ស៖** លោកដឹងទេថា តើក្រោយមកទៀតនោះមានគណៈប្រតិភូវៀតណាម និងកម្ពុជាគេធ្វើដំណើរទស្សនកិច្ចទៅវិញទៅមកទេ? លោកមានដឹងទេថា មានគណៈប្រតិភូយើងទៅវៀតណាម ហើយមានខាងវៀតណាមគេមកស្រុកខ្មែរវិញ?

**ឆ៖** ខ្ញុំអត់ដឹងដែររឿងហ្នឹង។

**ស៖** តើលោកធ្លាប់ទទួលភ្ញៀវមកពីមស្ឋិមប្រទេសទេ? ហើយបើធ្លាប់ទទួលហ្នឹងលោកចាំឈ្មោះពួកបស្ចិមប្រទេសដែលមកទស្សនកិច្ចនៅកម្ពុជាទេ?

**ឆ៖** ខ្ញុំអត់ដែលបានទទួលភ្ញៀវមកពីមស្ឋិបប្រទេសទេ។

**ស៖** ខ្ញុំមានសំណួរចុងក្រោយ។ ពាក់ព័ន្ធនឹងចម្លើយដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុរបស់លោកពាក់ព័ន្ធនឹងការងារលោកជានីរសារ។ គឺចម្លើយទី៥ នៃឯកសារ E3/462 គឺចម្លើយទី៥ លោកបានឆ្លើយ -- "សួរសំណួរ៖ លោកមានដែលឃើញអ្នកទាំងបួន (អ្នកទាំងបួនគឺ ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា) លោកមានដែលឃើញអ្នកទាំងបួននេះប្រជុំគ្នានៅផ្ទះនេះទេ គឺនៅ ក-១? ឆ្លើយ៖ ធ្លាប់ឃើញមានប្រជុំគ្រប់គណៈភូមិភាគនៅមន្ទីរក-១ នេះ។ ខ្ញុំមិនដែលឃើញការប្រជុំរបស់ថ្នាក់ដឹកនាំនេះទេ។ ខ្ញុំឃើញ<> សោ ភឹម <មកពីបូព៌ា>មកប្រជុំជាញឹកញាប់។ ខ្ញុំក៏ឃើញ កែ ពក និង ធុច មកប្រជុំផងដែរ។ ខ្ញុំឧស្សាហ៍យកសំបុត្រពីក-១ ទៅភូមិភាគ<នានា>។ ខ្ញុំស្គាល់ សោ ភឹម ច្បាស់។ សំបុត្រផ្ញើនោះ ខ្ញុំមិនដឹងខ្លឹមសារទេ ពីព្រោះថាគេបិទជិតមើលមិនឃើញទេ។ ប៉ុល ពត អ្នកឲ្យខ្ញុំផ្ទាល់ឲ្យយកសំបុត្រទៅភូមិភាគ ដូចជាទៅឲ្យ កែ ពក និង ធុច។ ខ្ញុំមិនដែលទទួលទូរលេខទេ មានតែអីវ៉ាន់ដូចជា ស្រា ជាដើម។" ដូច្នេះ លោកទទួលបន្ទុកក្នុងការចែកចាយស្រាទៅតាមភូមិភាគមែនទេ?

**ឆ៖** មិនមែនចែកស្រាទៅតាមភូមិភាគទេ គឺជា -- មែនទែនទៅ គឺជាជំនួនរបស់ ប៉ុល ពត ឲ្យថ្នាក់ភូមិភាគតែប៉ុណ្ណោះឯង។

**ស៖** ជំនូនរបស់ ប៉ុល ពត ហ្នឹងគាត់ឲ្យយកទៅជូនទៅអ្នកណាដែរ?

**ឆ៖** ជូនទៅឲ្យនែនេះ ភូមិភាគបូព៌ា។

**ស៖** ដូច្នេះមានន័យថា ប៉ុល ពត ជូនអំណោយទៅឲ្យ សោ ភឹម មែនទេ?

**ឆ៖** ជូនទៅឲ្យ សោ ភឹម។

**ស៖** លោកអាចជម្រាបអំពីទំនាក់ទំនងរវាង ប៉ុល ពត និង សោ ភឹម បានទេ ពួកគាត់មានទំនាក់ទំនងជិតស្និទ្ធដូចជា មិត្តភក្តិអ៊ីចឹងមែនទេ?

**ឆ៖** ជាការពិតណាស់ គាត់ជិតស្និទ្ធ។ អ្នកទាំងពីមានការជិតស្និទ្ធគ្នា ព្រោះ សោ ភឹម គាត់មានជំងឺ សើស្បែកនេះ សើស្បែកដែលគាត់ចេះតែរមាស់ ហ្នឹងគាត់យកចិត្តទុកដាក់ណាស់។ បាទ គាត់ជិតស្និទ្ធ។

[១៣:៤៧:៤០]

**ស៖** លោកធ្លាប់មានឃើញថា ទំនាក់ទំនងអ្នកទាំងពីរហ្នឹងកាន់តែមានសភាពយ៉ាប់យឺនទៅទេ?

**ឆ៖** រឿងនេះ ខ្ញុំមិនដឹងទេ កិច្ចការផ្ទៃក្នុងរបស់គាត់ ខ្ញុំអត់ដឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកសាក្សី ដែលបានឆ្លើយបញ្ជាក់ទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សួស្តីលោកសាក្សី ខ្ញុំជាសហមេធាវីការពារក្តីលោក នួន ជា ខ្ញុំសូមសួរសំណួរលោកមួយចំនួននៅក្នុងថ្ងៃនេះ។

[១៣:៤៨:៣៧]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរបន្តនៅសំណួរដែលបានសួរលោកកាលពីព្រឹកមិញ ពីខាងសហព្រះរាជអាជ្ញា គឺពាក់ព័ន្ធទៅនឹងពេលដែលលោកចូលបដិវត្តន៍។ លោកបានឆ្លើយថាលោកចូលបដិវត្តន៍ឆ្នាំ១៩៧០។ តើវា

អាចទេ ដែលថាលោកអាចចូលបដិវត្តន៍ហ្នឹង <>តាំងពី<មុន>ឆ្នាំ១៩៧០ ទៅទៀត?

**លោក សេង លីថេង៖**

**ឆ៖** មែនទែន ខ្ញុំចូលកងទ័ពវៀតណាមនៅឆ្នាំ១៩៧០។

**ស៖** ខ្ញុំយល់ ក៏ប៉ុន្តែតើអាចទេដែលថា លោក<បាន>ចូល<បដិវត្តន៍>មុនពេលដែលចូលទៅជាមួយនឹងទ័ពវៀតណាមទៅទៀត?

**ឆ៖** ពីមុនៗធ្វើរដ្ឋប្រហារ ខ្ញុំក៏ជាអ្នក គេហៅថាអ្នកតស៊ូសម្ងាត់ពីជំនាន់នោះផងដែរ។ ដល់ឆ្នាំ៧០ ខ្ញុំចូលក្នុងកងទ័ពវៀតណាម។

**ស៖** តើគេធ្លាប់ចាប់លោក ឬក៏គេធ្លាប់កាត់ទោសលោកដាក់ចូល ដាក់ឃុំក្នុងគុកដែរឬទេ មុនឆ្នាំ១៩៧០? បានន័យថា នៅមុនឆ្នាំ១៩៧០ មានដែលខាងនគរបាលរបប សីហនុ ចាប់លោកដាក់គុកទេ?

[១៣:៥០:៣៧]

**ឆ៖** បាទ ធ្លាប់ៗចាប់ខ្ញុំដាក់គុក ហើយកាត់ទោសខ្ញុំដាក់គុក ២០ឆ្នាំឯណោះ។

**ស៖** តើលោកអនុវត្តទោសបានប៉ុន្មានឆ្នាំ? បានន័យថា លោកនៅក្នុងគុកបានប៉ុន្មានឆ្នាំ? តើមុនឆ្នាំ៧០ ទៅលោកជាប់គុកហ្នឹង គេដាក់លោកហ្នឹង លោកនៅក្នុងគុកហ្នឹងរយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** ខ្ញុំនៅក្នុងគុកប្រហែលជាពីរឆ្នាំ ត្រូវអនុគ្រោះពីសម្តេចឪដោះលែងខ្ញុំមកវិញ។

**ស៖** តើពាក់ព័ន្ធទៅនឹងទំនាក់ទំនងបុគ្គល តើលោកជាមួយនឹងបងប្រុសរបស់លោកនេះ ជិតស្និទ្ធជាមួយនឹង ប៉ុល ពត ដែរឬទេនៅមុនឆ្នាំ១៩៧០?

**ឆ៖** មិន -- ការទាក់ទងជាមួយខ្ញុំនឹង ប៉ុល ពត ជំនាន់ ៧០ គឺមិនៗមានការទាក់ទងគ្នាទេ។

**ស៖** តើ ប៉ុល ពត មាននៅក្នុងពេលណាមួយនោះ បានស្នើសុំលោកនេះ ឲ្យធ្វើជាជាងថតរូបដែរឬទេ?

**ឆ៖** បាទ។ -- រូបម្នាក់ដែលបានរៀន ទៅរៀនកាលថតរូបនៅ តាំងពីនៅក្នុងព្រៃ។

**ស៖** តើ ប៉ុល ពត គាត់ស្នើសុំឲ្យលោកធ្វើជាជាងថតរូបនោះនៅក្នុងឆ្នាំណាដែរ? បានន័យថា នៅក្នុងទសវត្សរ៍ឆ្នាំ៧០ ហ្នឹងក្រោយពេលដែលលោកចេញពីជួរកងទ័ពវៀតណាម ឬក៏នៅពេលណាដែរ?

**ឆ៖** ខ្ញុំបានចេញពីកងទ័ពវៀតណាមហើយ បានទៅនៅព្រៃហ្នឹង បានឆ្លៀតរៀនថតរូបហ្នឹងនៅក្នុងព្រៃ ក្នុងព្រៃតែម្តង។

**ស៖** តើលោកទទួលការរៀនសូត្រដើម្បីឲ្យអាចចេះជាជាងថតរូបនេះរយៈពេលប៉ុន្មានដែរ <រៀននៅក្នុងព្រៃហ្នឹង>?

**ឆ៖** ខ្ញុំរៀននៅព្រៃនោះប្រហែលជាមួយខែទេ ខ្ញុំ វាមិនមានសម្ភារៈអីធំដុំនឹងរៀន គ្រាន់តែរៀនឲ្យតែចេះៗ។

[១៣:៥៤:១៣]

**ស៖** តើលោកមានដែលធ្លាប់ទៅប្រទេសចិនដែរឬទេ? មានពេលមួយនោះ ដើម្បីទៅរៀនសិក្សាបច្ចេកទេសក្នុងការផ្តិតរូបថត និងផ្តិតជាខ្សែភាពយន្តផងដែរនោះ?

**ឆ៖** ទៅរៀននៅប្រទេសចិនមួយរយៈដែរ។

**ស៖** ហើយនៅពេលណាដែរ ដែលលោកទៅរៀនខាងផ្នែកថតរូប ខាងផ្នែកវីដេអូនោះ នៅប្រទេសចិននោះ?

**ឆ៖** ទៅរៀនពេលនោះ ប្រហែលក្នុង៧៧អី ប្រហែលជាឆ្នាំ៧៧។

**ស៖** តើនៅ -- លោកទៅរៀននៅចិនផ្នែកថតរូបហ្នឹង ក្នុងពេលដែលលោកធ្វើការនៅ ក-១ ឬក៏ <នៅមុនពេលដែលលោកធ្វើការនៅ ក-១>?

**ឆ៖** រៀន ពេលហ្នឹង ដូចខ្ញុំនៅៗក្នុងអង្គភាព ក-១ហើយ បាទ។

**ស៖** តើ ប៉ុល ពត មានបានស្នើសុំលោកឲ្យថត ឬក៏ផ្តិតរូបគាត់ ឬក៏រូបថតគណៈប្រតិភូបរទេស ដូចជាចិន ដែលបានមកធ្វើទស្សនកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ភាគច្រើន ការថតរូបនេះ គឺថតនៅពេលដែលគណៈប្រតិភូចិន ឬក៏ភ្ញៀវដទៃដែលធ្វើការជាមួយ ប៉ុល ពត។ ថ្ងៃនោះ ខ្ញុំត្រូវថតផ្ទាល់ខ្លួនឯង។

[១៣:៥៦:៤៥]

**ស៖** ប្រហែលជា <> ខ្ញុំមិនប្រាកដ<>១០០ភាគរយនោះទេ <ប៉ុន្តែប្រហែល គឺខ្ញុំមាន>រូបថត<មួយសន្លឹកដែលលោកបានថត នៅ>ក្នុងពេលទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់របស់ប្រទេសចិន។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញនូវរូបថតមួយសន្លឹក ជូនសាក្សី ហើយសុំអនុញ្ញាតពីលោកប្រធាន ឲ្យបញ្ចាំងនៅលើអេក្រង់ផងដែរ E3/3258 មាន ERN តែមួយទំព័រទេ គឺ P រូបថត <00416558>។

**ប្រធានអង្គជំនុំ៖**

ហើយខាងផ្នែកសោតទស្សន៍ចាក់បង្ហាញរូបថតនិងឯកសាររូបថតហ្នឹងនៅលើអេក្រង់ទូរទស្សន៍។

*(ការបង្ហាញឯកសារជារូបភាព)*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូចដែលខ្ញុំជម្រាបលោកអ៊ីចឹង លោកសាក្សី ខ្ញុំមិនប្រាកដថា ជារូបថតលោកនោះទេ។ នៅកណ្ដាលនោះ មានបុរសម្នាក់កំពុងតែកាន់ម៉ាស៊ីនថត។ តើពិតជារូបលោកដែរឬទេ?

**លោក សេង លីថេង៖**

**ឆ៖** មិនមែនរូបខ្ញុំទេ។

**ស៖** តើជានរណាដែរអ៊ីចឹង?

**ឆ៖** ខ្ញុំៗអត់ស្គាល់ដែរ។

[១៣:៥៨:៣៧]

**ស៖** នៅពេលនេះ ខ្ញុំសូមចូលទៅដល់<មនុស្សពីរនាក់>ដែលមាននៅក្នុងរូបថតនេះ។ តើនៅខាងស្ដាំនោះ ជារូបអ្នកណាដែរ?

**ឆ៖** រូប ប៉ុល ពត។

**ស៖** ចុះខាងឆ្វេងវិញ ដែលគាត់ចាប់រលាក់ដៃជាមួយនោះ តើជានរណាដែរ?

**ឆ៖** ខាងឆ្វេង តាម៉ុក។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់ គឺខាងឆ្វេង ទៅជា តាម៉ុក ឬក៏យ៉ាងម៉េច តាមរយៈការបកប្រែ? តើអ្នកដែលកំពុងរលាក់ដៃនោះ ជាមួយ ប៉ុល ពត នោះ គឺជា តាម៉ុក លោកឆ្លើយអ៊ីចឹងមែនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ខាងផ្នែកសោតទស្សន៍ ចាក់ផ្សាយរូបថតនៅលើអេក្រង់ទូរទស្សន៍សាជាថ្មីម្ដងទៀត។

*(ការបង្ហាញឯកសារជារូបភាព)*

[១៤:០០:១៥]

**លោក សេង លីថេង៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** មុខប្រហាក់ប្រហែលនឹង តាម៉ុក ខ្ញុំមិនប្រាកដទេ ដល់ៗអ៊ីចឹង ខ្ញុំមិនប្រាកដវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មុនពេលដែលខ្ញុំសួរលើបុគ្គលរូបហ្នឹង អាចជារូបថតដែលលោកជាអ្នកថតមែនដែរឬទេ?

**ឆ៖** មិនមែនៗ រូបថតខ្ញុំថតទេ។

**ស៖** អ៊ីចឹងខ្ញុំសាកល្បងព្យាយាមជួយឲ្យលោកនឹកឃើញមើលថាតើនរណាគេនៅខាងឆ្វេង។ គាត់មើលទៅស្រដៀងទៅនឹងសមាជិកគណៈអចិន្ត្រៃយ៍ជាន់ខ្ពស់<ចិន> ឈ្មោះ ហ្គេង បៀវ តើលោកនឹកឃើញទេ ហ្គេង បៀវ ជាគណៈប្រតិភូជាន់ខ្ពស់មកពីខាងចិនហ្នឹង?

**ឆ៖** ខ្ញុំអត់ស្គាល់ដែរ មិនដឹងអ្នកណាពិតប្រាកដ។

**ស៖** មិនអ្វីជាថ្វីនោះទេលោកសាក្សី។

លោកប្រធាននៅពេលនេះខ្ញុំសូមអនុញ្ញាតបង្ហាញរូបថតមួយចំនួនផ្សេងទៀត ដែលអាចទំនងថាសាក្សីជាអ្នកថតរូបថត ឯកសារ E3/3250, ERN គឺ P00416551។

**ប្រធានអង្គជំនុំ៖**

ហើយផ្នែកខាងអាយវីចាក់ផ្សាយនូវរូបថតនេះលើអេក្រង់ទូរទស្សន៍ផង!

*(ការបង្ហាញឯកសារជារូបភាព)*

[១៤:០២:៤៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី អាចដែលថារូបថតនេះលោកជាអ្នកថតដែរឬទេ?

**លោក សេង លីថេង៖**

**ឆ៖** មិនមែនៗរូបថតខ្ញុំថតផង។

**ស៖** តើលោកស្គាល់អ្នកទាំងអស់ដែលមាននៅក្នុងរូបថតហ្នឹងដែរឬទេ?

**ឆ៖** ស្គាល់រូប ប៉ុល ពត, តានួន ជា, អៀង សារី។ អ្នកផ្សេងទៀតខ្ញុំអត់ស្គាល់ដែរ។

**ស៖** ចុះមើលអ្នកដែលឈរនៅចន្លោះ នួន ជា និង អៀង សារី តើអាចដែលថាជា សោ ភឹម ទេ?

**ឆ៖** បាទ អាចៗជា សោ ភឹម។

**ស៖** ហើយខាងឆ្វេង? ខាងឆ្វេង អៀង សារី អាច វន វ៉េត ទេ? ហើយនៅជាប់ហ្នឹងគឺ កុយ ធួន

ហើយអ្នកដែលមានរាងតូចបន្តិចនៅខាងឆ្វេងនោះ គឺ ភួង មកពីខាង<ចម្ការ>កៅស៊ូ <ភូមិភាគបូព៌ា គឺ ជាបុគ្គលទី២ នៅក្នុងភូមិភាគបូព៌ា>?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកសួរឈ្មោះបីនាក់ អ៊ីចឹងអត់ទាន់បានចម្លើយមួយផង! សូមទៅសួរមួយៗ។

[១៤:០៤:៤៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីខ្ញុំសួរមួយៗម្តង។ <ខាងឆ្វេង>ជាប់ អៀង សារី តើជា វន វ៉េត មែនឬមិនមែន?

**លោក សេង លីផេង៖**

**ឆ៖** អ្នកៗទាំងបីហ្នឹង ខ្ញុំអត់ៗសូវស្គាល់ទេ មិនអាចចាំមុខបាន។

**ស៖** ខ្ញុំគិតថា ខ្ញុំមានរូបថតច្បាស់ជាងហ្នឹងមកបង្ហាញរូបភាព សោ ភឹម។

នៅពេលនេះសូមអនុញ្ញាតពីលោកប្រធានតែម្តង បង្ហាញនាពេលនេះជូនសាក្សី E3/3259, ERN គឺ P00416559។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយផ្នែកសោតទស្សន៍ចាក់បង្ហាញឯកសារហ្នឹងលើអេក្រង់ទូរទស្សន៍ ហើយកុំអាលដកចេញអី ទុកដេញដោលឲ្យចប់សិនចាំដកចេញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី គឺ ហ្គេង បៀវ ដែលខ្ញុំបញ្ជាក់អំមិញហ្នឹង គឺយើងមើលរូបថតមុនហ្នឹង នេះយើងថតពីក្រោយ។ ហើយអ្នកនៅកណ្តាល តើជា សោ ភឹម ទេ?

[១៤:០៦:៤៣]

**លោក សេង លីផេង៖**

**ឆ៖** ខ្ញុំៗដូចមិនប្រាកដទេនេះ។

**ស៖** ចុះអ្នកនៅខាងឆ្វេងវិញ? នៅខាងឆ្វេងអ្នកដែលយើងសន្និដ្ឋានថាជា សោ ភឹម នេះ ជានរណាដែរ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នៅពេលនេះលោកគួរតែបញ្ជាក់ផង ថាតើនៅឈរខាងណា?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺដើម្បីជាប្រតិចារឹកអ្នកដែលសើចញញឹម <បង់ក>ក្រមា ហើយហាក់ដូចជាមើលទៅសម្លឹងទៅកាន់ ហ្កេង បៀវ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរជាលក្ខណៈទូទៅតែម្តងលោកសាក្សី។ តើលោកមានស្គាល់អ្នកណាទេ ខ្លះទេនៅក្នុងរូបថតនេះ?

[១៤:០៧:៣២]

**ឆ៖** ក្នុងរូបនេះ ខ្ញុំអត់ស្គាល់ផង សោ ភឹម ក៏មិនៗប្រាកដថា សោ ភឹម ដែរហ្នឹងមុខនេះ មិនដូចម៉េច។ អត់ស្គាល់ក្នុងរូបថតនេះ។

**ស៖** នៅមានរូបថតពីរទៀតដែលខ្ញុំសូមបង្ហាញលោក ហើយសំណួរដែលខ្ញុំចង់សួរលោកនោះគឺថាតើលោកជាអ្នកថត ឬក៏មិនមែន? លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារ E3--

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យមេធាវីបញ្ជាក់នៅក្នុងប្រតិចារឹក មូលដ្ឋាន ដែលគាត់ថាមានមូលដ្ឋានអ្វីដែលបញ្ជាក់ថា បុគ្គលហ្នឹងជា ហ្កេង បៀវ? បើមិនអ៊ីចឹងទេ គឺគាត់ជាអ្នកផ្តល់សក្ខីកម្មបញ្ជាក់អតីតសញ្ញាណលើបុគ្គលនេះខ្លួនឯង។ តើគាត់មានមូលដ្ឋានអ្វីដែលអាចបញ្ជាក់ថាគាត់ជា ហ្កេង បៀវ?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺមាននៅក្នុងសំណុំរឿង ឯកសារ E3/3479, ភាសាអង់គ្លេស 00442826, លេខ ERN ជាភាសាអង់គ្លេស ហើយនៅក្នុងនោះមានការពិពណ៌នាអំពីបុគ្គលមួយរូបដែលខ្ញុំដូចជាខ្ញុំបង្ហាញអ៊ីចឹង ចាប់ដៃជាមួយនឹង ប៉ុល ពត។<ហើយគេសរសេរថា> “ប៉ុល ពត ស្វាគមន៍រដ្ឋមន្ត្រីក្រសួងការពារជាតិរបស់សាធារណរដ្ឋ<ប្រជាមានិត>ចិន <ហ្កេង បៀវ> នៅអាកាសយានដ្ឋានពោធិ៍ចិនតុង។ <អៀង សារី និងអ្នកថតរូបខ្មែរក្រហមមើលហេតុការណ៍នេះ”។ ដូច្នេះ នោះជាប្រភពដំបូងនៃព័ត៌មានរបស់យើង>

ហើយឯកសារ ទី២ គឺជាឯកសារដែលបង្ហាញជាសាធារណៈ <ប៉ុន្តែខ្ញុំអាចនិយាយឡើងវិញនៅពេលនេះ។ គាត់>មើល<ទៅ>ស្រដៀងទៅនឹងរូបថត<នៅលើ*ហ្គូហ្គល*>។ បានន័យថា យើងជឿជាក់ថាគាត់ហ្នឹងគឺជា ហ្គេង បៀវ ដែលមកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យនៅចន្លោះឆ្នាំ៧៥ ដល់ ឆ្នាំ៧៩។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញរូបថត<មួយ ឬ>ពីរទៀតជូនសាក្សី។

[១៤:១០:00]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ លោកមេធាវី លោកអាចបញ្ជាក់បានទេ អ្នកណាជាអ្នកសរសេរអក្សរ<អមជាមួយនឹងរូបថត> ដែល<>លោកបង្ហាញអម្បាញ់មិញហ្នឹង? ដែលអក្សរនៅក្រោមរូបថតហ្នឹង។ ខ្ញុំចង់ដឹងថា គាត់អ្នកសរសេរហ្នឹង គាត់បានប្រភពហ្នឹងមកពីណា?

**លោក វិុចទ័រ កូប៉េ៖**

អត់មានបញ្ជាក់ថាអ្នកណាជាអ្នកសរសេរការពិពណ៌នានេះទេ។ <>មានរូបថតផ្សេងទៀតបង្ហាញអត្តសញ្ញាណឥស្សរជនចិនមកទស្សនកិច្ច ហើយខ្ញុំទោះបីយ៉ាងនេះក៏ដោយមិនអាចបញ្ជាក់ថា តើនរណាជាអ្នកសរសេររៀបរាប់ការពិពណ៌នានៅក្នុងរូបថតនិងឯកសារនេះទេ។

ដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង លោកប្រធាន ខ្ញុំសូម<បង្ហាញឯកសារ E3/3269។>

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដើម្បីជាប្រតិចារឹក ខ្ញុំសូមបញ្ជាក់ថា រូបថតនេះ មិនមែនជារូបថតចុះនៅក្នុងសារព័ត៌មានទេ។ <>ចំណារ<នោះមិនមាននៅក្នុងសារព័ត៌មាន>ទេ។

**លោក វិុចទ័រ កូប៉េ៖**

ប្រហែលជាមានការបកប្រែច្រឡំ។ ខ្ញុំមិនមែនថាចេញមកពីកាសែតទេ។ អ្វីដែលខ្ញុំ<មាន>នៅក្នុងឯកសារនេះ <គឺ>ការពិពណ៌នា <ហើយបន្ទាប់មក គឺអ្វីដែលខ្ញុំទើបតែបាននិយាយ គឺថា> "ប៉ុល

ពត ស្វាគមន៍រដ្ឋមន្ត្រីក្រសួងការពារជាតិរបស់សាធារណរដ្ឋប្រជាមានិតចិន ហ្គេង បៀវ នៅអាកាសយានដ្ឋានពោធិ៍ចិនតុង។" <នេះជាអ្វីដែលខ្ញុំមាន។> ខ្ញុំមិនដឹងថាអ្នកណាជាអ្នក<សរសេរ>ចំណុចពិពណ៌នានេះទេ។ <ដូច្នេះខ្ញុំមិនបាននិយាយថា វាចេញមកពីកាសែតនោះទេ។>

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឯកសា រE3/3269, ERN P00416570 គឺរូបថត ថតនៅអង្គរវត្ត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! ហើយផ្នែកសោតទស្សន៍ចាក់ផ្សាយបង្ហាញឯកសាររូបថតនោះនៅលើអេក្រង់ទូរទស្សន៍!

[១៤:១៣:១៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោករូបថតនេះ លោកជាអ្នកថតឬ?

**ឆ៖** ខ្ញុំដូចមិនៗប្រាកដទេ ជារូបៗទាំងអស់នេះ មិនប្រាកដថាខ្ញុំថតទេ ឬមួយក៏ខ្ញុំភ្លេច ឬយ៉ាងម៉េច ប៉ុន្តែខ្ញុំដូចមិនបានថតរូបនេះទេមើលទៅ។ ខ្ញុំមិនច្បាស់ដែរ។ ប៉ុន្តែភាគច្រើន ខ្ញុំថតរូបច្រើនតែនៅភ្នំពេញ កន្លែងដែលជួបគណៈប្រតិភូអង្គុយចរចាគ្នាអី ខ្ញុំភាគច្រើន គឺច្រើនថតនៅចំណុចនេះ។ ឯរូបខាងក្រៅនេះ ដូចខ្ញុំមិនប្រាកដថាខ្ញុំថត ឬអ្នកណាថត ខ្ញុំមិនអាចនិយាយបាន។

**ស៖** លោកសាក្សី ខ្ញុំមានរូបថតស្តីអំពីកិច្ចប្រជុំមួយរបស់ -- កិច្ចប្រជុំជាមួយនឹងប្រតិភូជាន់ខ្ពស់ចិន។ បាទ លោកប្រធាន សូមការអនុញ្ញាតបង្ហាញរូបថតនេះទៅឲ្យសាក្សីពិនិត្យមើលផង។ ប្រហែលជារូបថតនេះ គាត់ជាអ្នកថតហើយ គឺ E3/3260, ERN <P00416560>។

[១៤:១៥:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយផ្នែកខាងសោតទស្សន៍ចាក់ផ្សាយបង្ហាញរូបថតហ្នឹងនៅលើអេក្រង់ទូរទស្សន៍។

ខាងផ្នែកសោតទស្សន៍ចាក់ផ្សាយឯកសារអំមិញលើអេក្រង់ទូរទស្សន៍ ប្រសិនបើមាន ហើយបើមិនមាន មានបញ្ហាអី? រាយការណ៍មកវិញ ខាងមេធាវីអត់ផ្តល់ទៅឲ្យ ឬក៏យ៉ាងម៉េច?

ឃើញហើយៗ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើរូបនេះអាចជារូបថតដែលលោកបានថតដោយផ្ទាល់ដែរឬទេ?

**លោក សេង លីថេង៖**

**ឆ៖** មិនមែនរូបថតខ្ញុំថតទេ។

**ស៖** ខ្ញុំសូមសួរបញ្ចប់ពាក់ព័ន្ធទៅនឹងរូបថតទាំងអស់នេះ។ ហើយបើលោកបានថត ឬក៏លោកបានដឹងថាអ្នកណាជាថតរូបនេះ សូមជួយឆ្លើយប្រាប់ផង។

លោកប្រធាន រូបថត ថតចម្លងនេះ អត់ល្អ គឺ E3/3236, ERN P00407223។

បាទ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

ហើយខាងផ្នែកអេ.វី ដាក់ផ្សាយបង្ហាញលើអេក្រង់ទូរទស្សន៍ ដូចគ្នា។

[១៤:១៧:៥៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកជាអ្នកថតរូបនេះឬ ឬក៏បើមិនមែនទេ លោកដឹងថាអ្នកណាជាអ្នកថតរូបនេះ?

**លោក សេង លីថេង៖**

**ឆ៖** រូបនេះក៏មិនមែនជារូបខ្ញុំថតដែរ។ អ្នកណា-- ព្រោះអ្នកថតរូបដែលគេមានជំនាញជាងខ្ញុំក៏មានដែរ ជំនាន់នោះ មិនមែនមានតែខ្ញុំទេ។ ហើយគេ -- រូបថតបែបនេះ អាចថតយូរហើយ តាំងពីមុនខ្ញុំទៀតនោះ។ ដូច្នេះ រូបនេះមិនមែនខ្ញុំថតទេ។

**ស៖** លោកសាក្សី ខ្ញុំសូមបង្ហាញរូបថតឲ្យលោកមើល ដែលសាក្សីម្នាក់បានអះអាងថា គាត់ជាអ្នកថតរូប ប៉ុល ពត និងមេដឹកនាំដទៃទៀតបានជាច្រើនសន្លឹក។ ហើយជាពិសេសក្នុងពេលដែលទៅធ្វើទស្សនកិច្ចពិនិត្យមើលការដ្ឋានលើកទំនប់នានា។

បាទលោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឲ្យសាក្សី<>មើល<>រូបថត<មនុស្សម្នាក់ដែលបានមកផ្តល់សក្ខីកម្មនៅទីនេះ គឺរូបថត> ញ៉ែម អេន <>ហើយខ្ញុំសួរទៅសាក្សីមើល ថាតើគាត់ស្គាល់<បុគ្គលនេះដែរឬទេ>។ គឺឯកសារនេះ ខ្ញុំយល់ឃើញថា មាន E3 ក៏ប៉ុន្តែខ្ញុំសូមផ្តល់ ERNសិន 00162874 មានឯកសារ D18/3/15.1។

[១៤:២០:០០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នៅចន្លោះពីឆ្នាំ១៩៧៥ ទៅដល់១៩៧៩ <តើ>លោក<ធ្លាប់>បានជួបបុគ្គល <>នេះទេ?

**លោក សេង លីថេង៖**

**ឆ៖** មើលអត់ច្បាស់អ៊ីចឹង ខ្ញុំ មិនដឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមរំខានបន្តិច។ <ខ្ញុំមិនច្បាស់ទាំងស្រុងទេ ប៉ុន្តែវាហាក់ដូចជាថា បុគ្គលនេះគឺត្រូវបានការពារ ដូច្នេះសូម>កុំបញ្ជាក់បញ្ចេញឈ្មោះរបស់គាត់។ <ប៉ុន្តែសូមរកមធ្យោបាយផ្សេងទៀតដើម្បីកំណត់អត្តសញ្ញាណគាត់តាមដែលលោកអាចធ្វើបាន។> ឬក៏ខ្ញុំយល់ច្រឡំទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

តាមការពិត គឺលោកស្រីខុសហើយ អាចបញ្ចេញឈ្មោះគាត់បានហើយ ព្រោះបុគ្គលរូបនេះនោះ ព្រោះគាត់ គឺគាត់ ញ៉ែម អេន ហ្នឹងឯង។

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<ខ្ញុំដឹងថាជាគាត់ហើយ។>

**<លោក វ៉ិចទ័រ កូប៉េ៖>**

<ទេ គាត់មិនត្រូវបានដាក់ក្នុងការការពារទេ។>

**<ចៅក្រម ក្លូឌា ហ្វេនស៍៖>**

<អូ៎! សូមទោស។>

[១៤:២១:១៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកស្គាល់គាត់ទេ ឬក៏ដឹងថាគាត់ហ្នឹងគឺជាអ្នកណាអីដែរទេ?

**លោក សេង លីថេង៖**

**ឆ៖** ខ្ញុំដូចមិនៗស្គាល់ទេ។

**សៈ** តើលោកធ្លាប់ដែលបានជួបគាត់ ដូចជានៅជុំវិញពេលវេលានៃការធ្វើដំណើរអមគណៈប្រតិភូចិន ឬក៏<អមដំណើរប៉ុល ពត? ព្រោះថា បើលោកមិនស្គាល់គាត់ទេ> លោកៗមិនអាចឆ្លើយនឹងសំណួរនេះបានទេ។ ឲ្យខ្ញុំសូមសួរតាមរបៀបផ្សេងវិញ ដើម្បីបានច្បាស់លាស់១០០ភាគរយ។ នេះគឺឯកសារ<E3/419> ជាប្រតិចារឹកចុះថ្ងៃទី២០ មេសា ២០១៦ ដែល ញ៉ែម អេន នេះ បានផ្តល់សក្ខីកម្ម និងបានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញានៅម៉ោង១០:០២ព្រឹក គាត់និយាយថា៖ "នៅពេលខ្ញុំធ្វើការនៅទួលស្លែង ខ្ញុំក៏ចូលរួមថតរូបដែរ ឧទាហរណ៍ ថតរូបនៅអង្គរវត្ត ថតអ៊ំ ប៉ុល ពត ឬក៏ថតគណៈប្រតិភូចិន ឬគណៈប្រតិភូមកពីប្រទេសកុម្មុយនីស្តជាមិត្តដទៃទៀត។ <ជាទូទៅគេចាត់តាំងឲ្យ> ខ្ញុំថតរូប ថត ប៉ុល ពត និង សុន សេន។ ហើយខ្ញុំកម្រនឹងបានឃើញ ខៀវ សំផន ណាស់ នៅពេលនោះ។" បញ្ចប់ការដកស្រង់។

លោកសាក្សី តើបុគ្គលម្នាក់នេះ ពិតជាមានការមមាញឹកចូលរួមមមាញឹកថតរូបរបស់ ប៉ុល ពត នោះដែរមែនទេ?

**ឆៈ** បុគ្គលណាមួយ ក្នុងរូបនេះ?

[១៤:២៣:២១]

**សៈ** លោកទើបតែនិយាយថាលោកអត់ស្គាល់មនុស្សនេះទេ ក៏ប៉ុន្តែខ្ញុំសួរឲ្យៗជាក់លាក់តែម្តងនេះថា តើលោកមានដឹងថា ស្គាល់បុគ្គលណាម្នាក់ដែលប្រគល់ភារកិច្ចឲ្យទៅថតរូប ដូចជាថតរូប ប៉ុល ពត ចុះទៅពិនិត្យមើលការដ្ឋានអាងទំនប់ទឹកនានាអីជាដើមនោះ។ លោកស្គាល់អ្នកណាដែលគេចាត់តាំងការងារនេះទេ <ឬក៏លោកមិនដឹងទេ>?

**ឆៈ** គេមានអង្គភាពគេផ្សេង ប៉ុនខ្ញុំមិនៗនៅក្នុងចំណោមអង្គភាពនោះទេ។ មានអង្គភាពមួយផ្សេងទៀត ជាអ្នកដើរថតរូប តាមអាង តាមអីហ្នឹង បាទ។

**សៈ** បាទ សូមអរគុណចំពោះការបញ្ជាក់បំភ្លឺនេះ។ សំណួរមួយផ្សេងទៀត តើលោកមានចូលរួមពាក់ព័ន្ធថត<ខ្សែភាពយន្តមួយអំពី>អ្នកទោសវៀតណាមដែរឬទេ?

[១៤:២៤:៣៣]

**ឆៈ** ចូលរួម បាទ ធ្លាប់ចូលរួមថត។

**សៈ** តើលោកនៅចងចាំអ្វីខ្លះ អំពីការថតរូបជនជាតិវៀតណាមនេះ?

**ឆៈ** គ្រាន់តែថតៗរូបជាៗភាពយន្តខ្លី នៅវៀតណាមម្នាក់ តែខ្ញុំមិនៗចាំទីកន្លែងទេ ព្រោះគេឲ្យ

ខ្ញុំទៅៗថតផ្ទាល់ ហើយម៉ាស៊ីនថតនេះ គឺៗខាងចិនគេឲ្យទេ គេឲ្យខ្ញុំទៅថតបាទ នៅវៀតណាម ឈ្លើយវៀតណាមម្នាក់។

**សៈ** តើលោកនៅចាំទេ <តើលោក>ថត<>ខ្សែភាពយន្ត<ខ្លីនោះនៅឯណា? តើ>ថតនៅភ្នំពេញឬ? <បើថតនៅភ្នំពេញ តើថត>នៅ<កន្លែង>ណា?

**ផះ** ថតនៅភ្នំពេញ តែខ្ញុំមិនដឹងកន្លែងណាទេ ព្រោះៗគេយកៗខ្ញុំទៅហ្នឹងមិនដឹង ប៉ុនដឹងថានៅភ្នំពេញ។

**សៈ** បាទ ខ្ញុំព្យាយាមសាក គឺជួយរំឭកដល់ការចងចាំរបស់លោកបន្តិចដោយយកសក្ខីកម្មអ្នកដែលបានផ្តល់សក្ខីកម្មនៅចំពោះតុលាការយើងនេះ។ លោកប្រធាន ខ្ញុំយោងទៅប្រតិចារឹកចុះថ្ងៃទី១៦ មិថុនា ២០១៦ នៅមុនម៉ោង១១:០៧ព្រឹក គឺថាសាក្សីបានផ្តល់សក្ខីកម្មថា <>"ខ្សែភាពយន្ត<ថតដោយឈ្មោះ> ថេង ដែលជាក្មួយរបស់ ប៉ុល ពត <មានពីរវគ្គ។> មួយថតនៅជិត<ស្រះ និងគុម្ពោត>ព្រៃនោះ នៅភាគខាងជើង -- សូមកែតម្រូវ នៅភាគខាងកើត<>ផ្លូវ១៦៣ និង<ខាងជើង>ផ្លូវម៉ៅសេងទុង។ ហើយផ្នែកទី២ ថតនៅផ្ទះរបស់ខ្ញុំនៅផ្លូវលេខ៩៥។ លោកសាក្សី ផ្លូវ១៦៣ និងផ្លូវម៉ៅសេងទុង តើវាជាកន្លែងដែលលោកថតខ្សែភាពយន្តនេះឬ?

[១៤:២៧:៤៥]

**ផះ** មិនៗដឹងជាខ្សែភាពយន្តឯកសារ ឬក៏ឯកសារពីរឿងអី ខ្ញុំមិនទាន់បានមើល មិនអាចឆ្លើយបានទេ។

**សៈ** ខ្ញុំយល់ហើយ ក៏ប៉ុន្តែលោកនៅចាំទេ ថាលោកបានទាក់ទងជាមួយអ្នកណាដើម្បីថតខ្សែភាពយន្តឯកសារនេះ? ហើយតើមានកម្មាភិបាលណាដែលបានជួយរៀបចំចាត់ចែងទីតាំងឲ្យលោកថតរូបនេះ លោកចាំទេ?

**ផះ** គឺនែ៎ ប៉ង់ ជាអ្នកចាត់ចែងឲ្យខ្ញុំទៅ។ ឈ្មោះ ប៉ង់។

**សៈ** ចុះលោកមាននៅចាំឈ្មោះអ្នកដែលលោកបានទាក់ទង នៅពេលដែលលោកទៅដល់កន្លែងថតនោះតែម្តង?

**ផះ** បាទ ទៅដល់កន្លែងហ្នឹងគឺ ប៉ង់ គេរៀបៗចំហើយ គេរៀបចំស្រេចសម្រាប់ខ្ញុំទៅថតតែក្តែតហ្នឹងទេ។ ថតជាភាពយន្តបន្តិចហ្នឹង គេឲ្យខ្ញុំមកវិញហើយ ប៉ុណ្ណឹងឯង។

**សៈ** តើលោកដឹងថា ខ្សែភាពយន្តឯកសារដែលលោកបានថតនេះ មានបានយកទៅចាក់បញ្ចាំង

នៅក្នុងសន្និសីទទីក្រុងហ្សាកាតាដែរឬទេ?

[១៤:៣០:០៩]

**ឆ៖** ខ្ញុំមិនដឹងដែរ ព្រោះថតហើយហ្នឹងខ្ញុំប្រគល់ម៉ាស៊ីនថតឲ្យទៅគេទៅ ចិនគេយកទៅៗ រួច មិនដឹងគេយកទៅធ្វើម៉េច ខ្ញុំៗមិនដឹងដែរ។

**ស៖** ឥឡូវយើងនិយាយគ្នាបន្តិចអំពី ប៉ង់។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកៗ និយាយអំពី ប៉ង់ បានច្រើនដែរ។ តើលោកចាំអ្វីខ្លះអំពីឈ្មោះ ប៉ង់ នេះ?

**ឆ៖** ឈ្មោះ ប៉ង់ នេះគឺខ្ញុំក្ដាប់ការងាររបស់គាត់ស៊ីជម្រៅមិនដឹងយ៉ាងម៉េចទេ ប៉ុន្តែគាត់អ្វីៗភាគច្រើនគឺ ប៉ង់ នេះជាអ្នកចាត់ចែង ក្រោមពីៗ ប៉ុល ពត មកនោះ។ បាទ ព្រោះ ប៉ង់ ហើយនិង ប៉ុល ពត ច្រើនទាក់ទងគ្នាការងារអី គឺ ប៉ង់ គេអ្នកបញ្ជា ខ្ញុំអ្នកចាត់ចែង។

**ស៖** តើ ប៉ង់ គាត់ជាប្រធានមន្ទីរក-១ ឬ?

**ឆ៖** ថាគាត់ជាប្រធាន ក-១ ក៏បានដែរ ព្រោះគាត់ចាត់ចែងលើការងារនៅអង្គភាពការពារហ្នឹងទាំងស្រុងហើយ។ ហើយការងារគាត់ក្រៅទៀតមិនដឹងយ៉ាងម៉េច ខ្ញុំក៏ក្ដាប់មិនបានដែរ។ ព្រោះអ្វីៗវាឆ្លងពី ប៉ុល ពត មកគឺ ប៉ង់ អ្នកទទួលបញ្ជាពី ប៉ុល ពត។ ចាត់ចែងការងារអីលើ ប៉ង់ ទាំងអស់។

[១៤:៣២:៣៩]

**ស៖** តើលោកធ្លាប់ដែលឃើញ ប៉ង់ ទាក់ទងជាមួយនឹង ឌុច ឬហៅ កុយ ធួន ដែលជាលេខាភូមិភាគឧត្តរ លោកទើបតែបានលើកឈ្មោះមកនិយាយដែរនោះ។ បាទ អ៊ីចឹងតើលោកធ្លាប់ឃើញគាត់ទាក់ទងជាមួយនឹង ឌុច ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលឃើញគាត់ទាក់ទងគ្នាផងហ្នឹង។

**ស៖** លោកសាក្សី ព្រឹកមិញ សហព្រះរាជអាជ្ញារងបានបង្ហាញឈ្មោះកម្មាភិបាលដែលធ្វើការនៅក-១ និង ក-៣ លោកក៏បានបង្ហាញខ្លួនរបស់លោកថា ក្នុងបញ្ជីហ្នឹងលោកមានលេខរៀងទី៥ ថេង ហៅ ពូល។ តើលោកធ្លាប់ដែលបានឃើញបញ្ជីឈ្មោះបែបនេះដែលធ្វើការនៅឯ ក-១ និង ក-៣ ដែរឬទេនៅពេលដែលលោកធ្វើនៅក-១ នោះ? តើលោកដែលបានជួបប្រទះឃើញបញ្ជីឈ្មោះ<អ្នក>ដែល<>ធ្វើការ<ដូចលោកនៅ>ក-១ និង ក-៣ នោះ<ដែរឬទេ>?

**ឆ៖** ឃើញបញ្ជីឈ្មោះដែរ -- អត់ដែលឃើញបញ្ជីឈ្មោះនេះទេ។

**ស៖** ចុះលោកស្គាល់ថាអ្នកណាជាអ្នកសរសេរអក្សរនេះដែរឬទេ ដែលនៅលើបញ្ជីមួយនេះ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អក្សរអី? -- ខ្ញុំមិនទាន់យល់ពីរឿងបញ្ជីឈ្មោះ ឬក៏ចង់សួរថា ស្គាល់ឈ្មោះក្នុងបញ្ជីនេះ?

[១៣:៣៥:០៦]

**ស៖** <មិនមែនអំពីឈ្មោះទេ ប៉ុន្តែ>ខ្ញុំសួរអក្សរដែលសរសេរដោយដៃនេះណា។ តាមរយៈឯកសារដែលយកមកបង្ហាញឲ្យលោកមើលនេះ <តើលោកបញ្ជាក់ថាវាមកពី ក-១ ដែរឬទេ?> តើលោកដែលស្គាល់អក្សររបស់អ្នកណា ថាអ្នកណាជាអ្នកសរសេរអក្សរនៅលើបញ្ជីនេះដែរឬទេ អក្សរដែលសរសេរដោយដៃនេះតែម្តង?

**ឆ៖** ខ្ញុំអត់ អត់ស្គាល់ទេ។

**ស៖** លោកសាក្សី ខ្ញុំសួរសំណួរផ្សេង។ នៅពេលដែលលោកនិយាយជាមួយ ប៉ុល ពត ឬក៏ នួន ជា បាទពេលលោកទាក់ទងដោយផ្ទាល់តែម្តងនោះ តើលោកហៅពូរបស់លោកថាម៉េចដែរ? លោកប្រើពាក្យពេចន៍វាក្យសព្ទបែបណានៅពេលដែលលោកជួបពូរបស់លោក ដោយផ្ទាល់ ឬក៏ជួប នួន ជា នោះ <តើលោកចាំទេ>? បាទ លោកថា ប៉ុល ពត។ ខ្ញុំសួរអ៊ីចេះ ឧទាហរណ៍ថា តើលោកហៅគាត់ថា អ៊ំប៉ុល បងប៉ុល អ៊ំប៉ុលពត ពេញតែម្តង ឬក៏ខ្លីហៅ លោកហៅដោយរបៀបណា ពេលជួបគាត់ដោយផ្ទាល់?

**ឆ៖** ជាទូទៅ គឺហៅ បងប៉ុលៗ។

**ស៖** ចុះចំពោះ នួន ជា វិញជាទូទៅ លោកហៅ នួន ជា ថាដូចម្តេចដែរ?

**ឆ៖** ជាទូទៅ ហៅ "បង" ទាំងអស់។

**ប្រធានអង្គជំនុំ៖**

បង ប៉ុន្តែបងម៉េច ឥឡូវហៅឲ្យច្បាស់មើល កាលពីកាលនោះ លោកហៅគាត់ ហៅថាម៉េច?

**លោក សេង លីថេង៖**

**ឆ៖** បងប៉ុល, បងនួន ជា, បង ខៀវ សំផន អ៊ីចឹង បាទ។

[១៤:៣៧:៤៣]

**សួរដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** ចុះពេលលោកជួប សុន សេន លោកហៅ សុន សេន ថាម៉េច?

**ឆ៖** កម្មាភិបាលទាំងអស់ភាគច្រើនគឺ ហៅ "បង" អ៊ីចឹងតែម្តង។ សុន សេន អីក៏ហៅ "បង" ជាទូទៅអ៊ីចឹងតែម្តង អ្នកដឹកនាំ។

**ស៖** តើសមមិត្តរបស់លោកដែលធ្វើការជាមួយលោកនោះ គេហៅពួកគាត់ថា បងប៉ុល ឬក៏

បង នួន ឬក៏គេហៅថា អ៊ំប៉ុល អ៊ំនួន ទៅវិញទេ?

**ឆ៖** វាតាមចំណូលចិត្តរបស់បុគ្គល អ្នកណាគេចង់ហៅម៉េចក៏បានដែរ ប៉ុន្តែជាទូទៅគេហៅតែ "បងៗ"។ ប៉ុន្តែក្មេងៗខ្លះគេហៅ អ៊ំ ហៅ តា ក៏មានអ៊ីចឹងដែរ បាទ។

[១៤:៣៨:៥៥]

**ស៖** តើវាមានលក្ខណៈខុសគ្នាឬ នៅពេលដែលគេទាក់ទងពួកគាត់ដោយផ្ទាល់ ហើយនិងការទាក់ទងទៅ ប៉ុល ពត និង នួន ជា តាមរយៈសារទូរលេខ <ឬក៏សំបុត្រ តើ>លោកដឹងទេ<>?

**ឆ៖** សារទូរលេខ ខ្ញុំអត់ដឹងទេ មិនដឹងគេទាក់ទងតាមវិធីណា ឬក៏លេខកូដ លេខអី ខ្ញុំក្តាប់អត់បានទេ។

**ស៖** សូមអរគុណលោកសាក្សី។

បាទ ដើម្បីប្រតិចារឹក លោកប្រធាន ឯកសារហ្នឹងត្រូវបានសហព្រះរាជអាជ្ញាយកមកប្រើប្រាស់សាកសួរសាក្សីនូវសំណួរមួយចំនួនហើយ ខ្ញុំក៏បានសួរសំណួរមួយចំនួនដែរ។ ខ្ញុំមិនបានជំទាស់ទេ មិនមានបញ្ហាអ្វីទេ ប៉ុន្តែយើងជឿជាក់ថាឯកសារនេះ គឺអាចរៀបចំឡើងនៅឯស-២១ ដោយ ឌុច ឬក៏ដោយ ប៉ុន។ មិនមែនដោយសារតែខ្លឹមសារនៃឯកសារពាក់ព័ន្ធទៅនឹងការនិយាយទៅកាន់ ប៉ុល ពត, នួន ជា ហៅថា អ៊ំទី១ អ៊ំទី២ នោះទេ។ ប៉ុន្តែតាមរយៈសក្ខីកម្មរបស់ ឌុច នៅពេលសួរតទល់គ្នាក្នុងសំណុំរឿង ០០១នោះ នេះគឺឯកសារ E3/82, ERN ជាភាសាអង់គ្លេស 00398187, បារាំង 00398193, ខ្មែរ 00398179។ សហចៅក្រមស៊ើបអង្កេតបានសួរ ឌុច នូវសំណួរដូចតទៅនេះ: {យើងកំពុងតែបង្ហាញលោកនូវឯកសារមួយ ដែលមានចំណងជើងថា "បញ្ជីអ្នកដែលធ្វើការនៅមន្ទីរ ក-១ និង មន្ទីរ ក-៣" តើពីមុនមកលោកធ្លាប់ដែលឃើញឯកសារនេះទេ? លោកដឹងទេ អ្នកណាជាអ្នករៀបចំសរសេរឯកសារនេះ ហើយសរសេរនៅក្រោមកាលៈទេសៈណាដែរ? ហើយ ឌុច ក៏បានឆ្លើយថា៖ ខ្ញុំមិនដែលបានឃើញឯក-សារនេះពីមុនមកទេ។ ខ្ញុំអាចនិយាយបានថា អក្សរដៃនេះ អាចជាអក្សររបស់ ប៉ុន ប៉ុន្តែមិនច្បាស់១០០ភាគរយអីទេថា ជាអក្សរគាត់ទេ។ ខ្ញុំមិនដឹងថា បញ្ជីនេះគេរៀបចំឡើងនៅស-២១ ឬក៏យ៉ាងណានោះទេ។ ខ្ញុំកត់សម្គាល់ថា <មានការបញ្ជាក់ឈ្មោះ>អ៊ំទី<២> យើងមិនដែលហៅឈ្មោះគាត់ថាជា នួន ជា ឲ្យចំឈ្មោះទាំងអ៊ីចឹងទេ<នៅស-២១ នោះ> គឺយើងហៅគាត់ថា "អ៊ំទី២"។} គឺថានៅក្នុងឯកសារនេះ គឺមានការយោងច្រើនណាស់ តាមរយៈ ប៉ង់ នេះ គឺហាក់បីដូចជាថា ឯកសារនេះ គឺត្រូវបានរៀបចំឡើង <រយៈពេលខ្លី>ក្រោយពីការចាប់ខ្លួន ប៉ង់ <>គឺនៅខែ <ឧសភា ឬ> មិថុនា ៧៨។ ប្រហែលជាដល់

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ពេលសមល្មមនឹងឈប់សម្រាកសិនហើយ លោកប្រធាន។

ខ្ញុំមិនទាន់ចប់ទេ គ្រាន់តែថាប្រហែលជាអាចដល់ពេលត្រូវឈប់សម្រាកសិនតែប៉ុននេះ មិនទាន់ ខ្ញុំមិនទាន់អស់សំណួរទេ ប៉ុន្តែបើលោកប្រធានអនុញ្ញាតឲ្យសួរបន្ត ខ្ញុំសួរបន្តទៅទៀត។

លោកសាក្សី តើលោកនៅនឹកឃើញថា លោកធ្លាប់និយាយទៅកាន់អ្នកកាសែតមកពីកាសែត ឌី ខេមបូឌាដេលីម្នាក់ គឺអ្នកកាសែតហ្នឹង ឈ្មោះ ថេត សម្បត្តិ។ លោកធ្លាប់ដែលនិយាយជាមួយនឹងគាត់ទេ?

[១៤:៤៣:១២]

**ឆ៖** ដូចជានឹកៗមិនឃើញទេ ដឹងពេលណាផង ប៉ុន្តែអ្នកកាសែតដែលទៅសាកសួរហ្នឹងច្រើនៗណាស់ មិនមែនតែមួយទេ បាទ។

**ស៖** តើលោកធ្លាប់ដែលនិយាយជាមួយអ្នកកាសែតម្នាក់ អំពីអត្តចរិតរបស់ ប៉ុល ពត នោះដែរទេ? គឺគេបានសួរសំណួរមួយឲ្យលោករៀបរាប់ អំពីអត្តចរិត អាកប្បកិរិយារបស់ ប៉ុល ពត។ លោកនឹកឃើញទេ?

**ឆ៖** បាទ ខ្ញុំៗនឹកឃើញៗខ្លះដែរ។

**ស៖** ឥឡូវខ្ញុំសុំសួរសំណួរប្រហាក់ប្រហែលគ្នានេះដែរ។ តើលោក<អាចរៀបរាប់ពីអត្តចរិតរបស់លោកបានទេ គឺអត្តចរិតរបស់ប៉ុល ពត ព្រោះថាលោក>ស្គាល់ពូរបស់លោកយ៉ាងច្បាស់។ លោកធ្វើការផ្ទាល់ជាមួយនឹងគាត់។ តើលោកអាចរៀបរាប់អាកប្បកិរិយា អត្តចរិតរបស់ ប៉ុល ពត នេះថា ជាមនុស្សរបៀបណាដែរ?

**ឆ៖** បាទ ពិនិត្យទៅការរស់នៅតាមសម្គាល់របស់ខ្ញុំធ្លាប់រស់នៅជាមួយគាត់ គាត់មិនមែនជាមនុស្សកាចសាហាវ ឬក៏ឃោរឃៅអីទេ គាត់ស្លូតបូត សុភាពរាបសា មានការទំនាក់ទំនងជាមួយមិត្តភក្តិជុំវិញខ្លួនបាន មិនដែលមានឃើញថា ចរិតគាត់មិនដែលច្រងេងច្រងាងអី ឬក៏ប្រើពាក្យសម្តីអីដែលមិនគួរសមទៅលើអ្នកដទៃទេ។ ហើយការអប់រំរបស់គាត់ក៏ជាន័យក្នុងការអប់រំល្អចំពោះអ្នកដទៃដែរ។ ដូច្នេះ ខ្ញុំមិនឃើញគាត់ជាមនុស្សឃោរឃៅ ដែលឲ្យសញ្ញាថាជាមនុស្សឃោរឃៅម្នាក់ទេ។

[១៤:៤៦:០០]

**ស៖** តើលោកនៅជាមួយនឹង ប៉ុល ពត រហូតដល់គាត់ស្លាប់នៅក្នុងឆ្នាំ១៩៩៨ នោះឬ?

**ឆ៖** នៅជាមួយគាត់រហូត រហូតដល់គាត់ស្លាប់។

**ស៖** លោកប្រធានបើៗអនុញ្ញាតសូមបន្តទៅមុខទៀត។ លោកសាក្សីលោកជិតស្និទ្ធនឹង ប៉ុល ពត ណាស់ តើលោកធ្លាប់ដែលឮថា<>មានចេតនា ឬក៏គោលបំណងណាមួយនៅដើមនៅទសវត្សរ៍ឆ្នាំ ៧០ ឬក៏ក្រោយមកទៀតក៏ដោយ ធ្លាប់ដែលឮទេ ធ្លាប់ដែលឮថាគេមានការប៉ុនប៉ងបំពុលចំណីអាហារ ប៉ុល ពត?

**ឆ៖** ករណីនេះខ្ញុំៗមិនច្បាស់ទេ ដែលក្នុងពេលដែលរស់នៅជាមួយគាត់នោះ ប៉ុន្តែបញ្ហានេះខ្ញុំឮ ក្រោយពីខ្ញុំចេញពីភ្នំពេញ គឺថា ឮករណីដែលមានជនចង់បំពុលថ្នាំ បំពុលអីចំពោះគាត់។

**ស៖** ចុះលោកដឹងថាអ្នកដែលចង់បំពុលគាត់ហ្នឹងជាអ្នកណាដែរទេ?

**ឆ៖** មិនដឹងច្បាស់ទេ តែដឹងៗៗថាគឺអ្នកនៅជិត គឺជាអ្នកឲ្យថ្នាំដល់គាត់ប្រចាំថ្ងៃហ្នឹង បើប្រាកដៗ ខ្ញុំៗមិនដឹងទេ។

**ស៖** តើលោកនៅជិតស្និទ្ធជាមួយគាត់<ទេនៅចុង>ឆ្នាំ១៩៧៨ ហ្នឹងនៅពេលដែលអ្នកកាសែតបរទេសពីរនាក់ទៅជួបគាត់ ហើយបាននិយាយជាមួយគាត់ ហើយនិងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់មួយ ដែលបានអមដំណើរអ្នកកាសែតពីរនាក់ដែរ ហើយត្រូវបានសម្លាប់នៅក្នុងបន្ទប់មួយក្នុងផ្ទះសំណាក់មួយនៅ<ខែធ្នូ> ឆ្នាំ១៩៧៨។ លោកដឹងអំពីរឿងនេះទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ សភាពការណ៍ខ្ញុំអត់ដឹងទេ។ ព្រោះខ្ញុំអត់នៅជាមួយគាត់អីទៀតទេពេលនោះ។

[១៤:៥៩:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានសូមឈប់សម្រាកសិន ដោយសារថាខ្ញុំត្រូវរកឯកសារមួយ។ អ៊ីចឹងខ្ញុំត្រូវការពេលវេលាដើម្បីរកឯកសារនេះយកមកសួរសាក្សី សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី និងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ព្រមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី និងប្រាំនាទី។

សម្រាកចុះ!

01389776



*(សវនាការសម្រាកពីម៉ោង ១៤:៤៩ នាទី ដល់ម៉ោង ១៥:០៧ នាទី)*

[១៥:០៧:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី លោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ចំណុចមួយខ្ញុំសូមបន្ថែមពាក់ព័ន្ធទៅនឹងរូបថតខ្លះ ដែលបានបង្ហាញនាពេលមុនទៅកាន់សាក្សី។ ប្រព័ន្ធ*ហ្សាយឡេប* បានបង្ហាញរូបថត ហ្គេង បៀវ ដែលវាដកស្រង់ចេញមកពីកាសែតភ្នំពេញប៉ុស្តិ៍។ គឺមានរូបថត ខេ.អ៊័រ ប្រភេទកម្រងចេញមកពីខ្មែរក្រហម ១១៦សន្លឹក ហើយឯកសារហ្នឹងនេះ គឺខ្ញុំមិនដឹងថាបានដាក់ ឬក៏មិនទាន់បានដាក់នៅឡើយទេនៅក្នុងសំណុំរឿង។ លោកសាក្សី យើងខ្ញុំនឹងបង្ហាញនូវខ្សែវីដេអូមួយរយៈពេល២នាទី។ សូមអនុញ្ញាតពីលោកប្រធាន ដែលយើងបានបញ្ជូនជាដំណឹងទៅដល់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះរួចហើយកាលពីរសៀល។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមបញ្ជាក់អត្តសញ្ញាណផង លោកមេធាវីដើម្បីជាកំណត់ត្រាប្រតិចារឹក។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងបញ្ជាក់នាពេលឆាប់បន្តិចទៀតនេះ លោកស្រីចៅក្រម។

*(សម្រាករយៈពេលខ្លី)*

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ E3/3015R គឺចាប់ផ្តើមពីដំបូង រហូតទៅដល់ពីនាទីទី០២:១៩។

សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ផ្នែកខាងសោតទស្សន៍ចាក់បង្ហាញនូវខ្សែវីដេអូលើអេក្រង់ទូរទស្សន៍។

*(ការចាក់បង្ហាញឯកសារ)*

[១៥:១១:៥៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី រូបថតខ្សែភាពយន្តនេះ អាចពាក់ព័ន្ធទៅនឹងទស្សនកិច្ចរបស់ ប៉ុល ពត ទៅភូមិភាគបូព៌ានៅចម្ការកៅស៊ូនៅដើមឆ្នាំ៧៨។ តើលោកខ្លួនឯងផ្ទាល់ មានបានចូលរួមនៅក្នុងទស្សនកិច្ចនោះដែរឬទេ ជាពិសេស នៅក្នុងការងារថតរូបភាពខ្សែវីដេអូនេះ? តើលោកជាអ្នកចូលរួមថតដែរឬទេ?

**លោក សេង លីថេង៖**

**ឆ៖** រូបថតវីដេអូ ហ្នឹងខ្ញុំមិនបានថតទេ។

**ស៖** តើលោកនឹកឃើញថា មានបានទៅអមដំណើរលោក ប៉ុល ពត ទៅភូមិភាគបូព៌ាដែរឬទេនៅ<>ក្នុងពេលណាមួយក៏ដោយនៅដើមឆ្នាំ៧៨?

**ឆ៖** ពេលហ្នឹង ខ្ញុំដូចមិនដែលបានចូលរួមក្នុងកម្មវិធីអ៊ីចឹងទេ មិនដែល។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនជាថ្វីនោះទេ ខ្ញុំគ្រាន់តែចង់សួរសំណួរនេះទៅកាន់លោកតែប៉ុណ្ណោះ។ សូមអរគុណលោកច្រើនលោកប្រធាន ខ្ញុំអស់ហើយ មិនមានសំណួរសួរទៀតទេ។

[១៥:១៣:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សម្រាប់មេធាវីការពាររបស់លោក ខៀវ សំផន មិនមានសំណួរសម្រាប់សាក្សីនេះទេបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោក សេង លីថេង សវនាការស្តាប់សក្ខីកម្មលោកក្នុងឋានៈជាសាក្សី នាពេលនេះដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទាន ក្នុងការស្វែងរកក្នុងរឿងក្តីនេះ។ អវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាច

វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។ ហើយអង្គជំនុំជម្រះ ក៏សូមអរគុណផងដែរ លោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី លោកអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក សេង លីថេង វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

សូមអញ្ជើញចាកចេញទៅចុះ លោក លីថេង ហើយនិងលោក ម៉ម រិទ្ធា។

*(សាក្សីនិងមេធាវីប្រឹក្សាចាកចេញពីបន្ទប់សវនាការ)*

[១៥:១៤:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-258។ មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-258 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៥:១៩:១៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ស្ួស្ដី លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកស្រីឈ្មោះអី?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស នាងខ្ញុំឈ្មោះ ខៀវ នាប។

**ស៖** ឈ្មោះអីចេះសូមបញ្ជាក់ម្ដងទៀតមើល ឈ្មោះអី?

**ឆ៖** នាងខ្ញុំឈ្មោះ ខៀវ នាប។

**ស៖** បាទអរគុណលោកស្រី ខៀវ នាប។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា លោកស្រីចាំដែរទេ?

**ឆ៖** ខ្ញុំ កំណើតខ្ញុំនៅឆ្នាំ១៩៥២។

**ស៖** បាទ អរគុណ។ ហើយទីកន្លែងរបស់លោកស្រីនៅទីកន្លែងណា?

**ផ៖** ទីកំណើតរបស់ខ្ញុំនៅភូមិដំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

**ស៖** អរគុណ។ ចុះទីលំនៅបច្ចុប្បន្ននេះ តើលោកស្រីរស់នៅទីកន្លែងណា?

**ផ៖** បច្ចុប្បន្ននេះ នៅភូមិវល្លិយាវ ឃុំដំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំដដែល។

**ស៖** អរគុណ។ ហើយលោកស្រីប្រកបមុខរបបអ្វីដែរ? ហើយឪពុកលោកស្រីឈ្មោះអី? ម្តាយលោកស្រីឈ្មោះអី?

**ផ៖** របប -- ឪពុកខ្ញុំឈ្មោះ ធុន ខៀវ ម្តាយខ្ញុំឈ្មោះ ឈុន សៀក។ របបរកស៊ីធ្វើស្រែចម្ការ។

**ស៖** បាទ អរគុណ។ ហើយចុះប្តីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ផ៖** ខ្ញុំកូនទី គ្រួសារទី១ កូនពីរ ស្រីមួយ ប្រុសមួយ។ គ្រួសារទី២ កូនបួន ប្រុសមួយ ស្រីបី ថ្ងៃ -- នៅសព្វថ្ងៃ។

**ស៖** គាត់ឈ្មោះអីទៅ?

**ផ៖** គ្រួសារក្រោយឈ្មោះ ថូ បៀន។

**ស៖** បាទ អរគុណហើយលោកស្រី ខៀវ នាប។ យើងជម្រាបដល់ស្រីថា ជាចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីអាចមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពអន្តរាយដែលកើតមានចំពោះលោកស្រីក្នុងរបបកម្ពុជាប្រជាធិតេយ្យពីថ្ងៃទី១៧ ខែមេសា ១៩៧៥ រហូតដល់ថ្ងៃទី០៦ មករា ៧៩ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ ហើយហើយលោកស្រី ខៀវ នាប ធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះដែរឬទេ ក្នុងរយៈពេលកន្លងមក?

**ផ៖** ចាស កិច្ចសម្ភាសន៍ដែលកន្លងមក ខ្ញុំធ្លាប់បានសម្ភាសដែរ ម្តងពីរដងដែរហើយ។

**ស៖** លោកស្រីផ្តល់កិច្ចសម្ភាសន៍ហ្នឹងនៅទីកន្លែងណា? នៅពេលវេលាណាដែរ? លោកស្រីចាំដែរទេ?

[១៥:២២:៤៣]

**ផ៖** ខ្ញុំចាំមិនបានពេលវេលា ព្រោះខ្ញុំមិនបានកត់ ប៉ុនមកផ្តល់កិច្ចសម្ភាសន៍នៅទីកន្លែងនេះដែរនៅកន្លែងខាងក្រោមនេះឯង។ មេធាវីសម្ភាសខ្ញុំ។

**ស៖** អ៊ីចឹងមិនមែនជាអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតទេ មែនទេ? គឺសម្ភាសជាមួយហ្នឹងខាងមេធាវីទេ មែនទេ?

**ឆ៖** កិច្ចសម្ភាសន៍ដូចថា មេធាវីហៅមក គឺសម្ភាសខ្ញុំ ក៏ ចាស។

**ស៖** បាទ អរគុណ។ ហើយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលសាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហមេធាវីមុខដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងសហតំណាងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម និងភាគីទាំងអស់គ្នា។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំនឹងសួរសំណួរបន្តិចបន្តួចរសៀលនេះគឺរហូតដល់ពេលចប់សវនាការនៅម៉ោងដប់ប្រាំមួយ គឺម៉ោងបួនរសៀល។ ជាបឋម ខ្ញុំនឹងចោទសំណួរទូទៅពាក់ព័ន្ធទៅនឹងប្រវត្តិរបស់លោកស្រីក្នុងអំឡុងរបបកម្ពុជា ប្រជាធិបតេយ្យ ដើម្បីអង្គជំនុំជម្រះអាចយល់ពីជីវិតរបស់លោកស្រី ហើយបន្ទាប់មកទៀត ខ្ញុំនឹង<>និយាយអំពីហេតុការណ៍នៅភ្នំពេញ ហើយនិងអំពី<ការបាត់ខ្លួន>ប្តីរបស់លោកស្រី។ ជាបឋមខ្ញុំចង់ដឹងថា តើមុនពេលថ្ងៃ១៧ មេសា ១៩៧៥ លោកស្រីរស់នៅឯណាដែរ?

[១៥:២៥:០៧]

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស នៅឆ្នាំ១៩៧៥ នាងខ្ញុំនៅនឹងភូមិឃុំកំណើតរបស់ខ្ញុំ។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការឈ្មោះ ភូមិឃុំស្រុកកំណើតរបស់លោកស្រី បានដែរឬទេ?

**ឆ៖** ចាស ភូមិរបស់ខ្ញុំគឺ ភូមិដំរីស្លាប់ ឃុំដំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

**ស៖** នៅឆ្នាំ១៩៧៥ តើលោកស្រីរៀបការហើយឬនៅ?

**ធ៖** ខ្ញុំរៀបការតាំងពី៧៣ គ្រួសារទី១។

**ស៖** ហើយប្ដីរបស់លោកស្រីឈ្មោះអីដែរ ហើយគាត់មានមុខរបរអ្វីដែរ ពេលដែលលោកស្រីរៀបការជាមួយគាត់ហ្នឹង?

**ធ៖** ប្ដីខ្ញុំឈ្មោះ ខេង ជឺ ឈ្មោះកំណើត។ ហើយរៀបការនឹងខ្ញុំ ធ្វើស្រែចម្ការនៅតាមភូមិឃុំហ្នឹងឯង។

**ស៖** សូមអរគុណ។ បន្ទាប់ពីធ្វើស្រែនៅភូមិនោះ តើគាត់ត្រូវបានគេចាត់តាំងឲ្យទៅធ្វើការនៅណាដែរ?

**ធ៖** ធ្វើការនៅភូមិ តែក៏មិនទៅឆ្ងាយពីភូមិទេ គ្រាន់ថា នៅជិតៗស្រែចម្ការជាក្រុមសហករណ៍នៅតាមភូមិនេះទេ។

**ស៖** ក្រោយពីធ្វើការឲ្យសហករណ៍ហ្នឹងហើយ តើគេបញ្ជូនប្ដីរបស់លោកស្រីទៅណាដែរ?

**ធ៖** ចាស ក្រោយពីធ្វើការ ធ្វើតាមសហករណ៍ ចូល៧៤ គេបញ្ជូនប្ដីខ្ញុំមកសមរភូមិ។

**ស៖** តើប្ដីរបស់លោកស្រីមានចូលរួមក្នុងការរំដោះទីក្រុងភ្នំពេញដែរឬទេ?

**ធ៖** ចាស ប្ដីនាងខ្ញុំ គឺអំឡុង៧៤ មកសមរភូមិបាត់ ៧៥ ដឹងដំណឹងរំដោះទីក្រុងភ្នំពេញ។

**ស៖** ហើយកាលនោះ ក្រោយពេលរំដោះទីក្រុងភ្នំពេញបាន នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយតើគេចាត់តាំងគាត់ឲ្យទៅធ្វើការនៅឯណាដែរ?

**ធ៖** ចាស រំដោះ ៧៥ ហើយប្ដីខ្ញុំចូលធ្វើការផ្សាររដ្ឋនៅហ្នឹងទីក្រុងភ្នំពេញនេះឯង។ គេហៅថាផ្សារថ្មី។

[១៥:២៩:២៥]

**ស៖** ចាប់ពីពេលដែលគេចាត់តាំងឲ្យគាត់ធ្វើការនៅផ្សារថ្មីហើយនោះ តើគាត់មានតួនាទីដដែលហ្នឹងរហូតដល់ពេលគេចាប់ -- ពេលដែលគាត់បាត់ខ្លួន ឬក៏គេឲ្យគាត់ធ្វើការអីផ្សេងខុសពីមុន?

**ធ៖** ចាស ការងារនៅកន្លែងនោះ គឺគ្មានការងារអីខុសប្លែកពីថាផ្សាររដ្ឋហើយ គេដូចជាប្រមូលសេដ្ឋកិច្ច ដូចជាអង្ករ បន្លែ នៅក្នុងផ្សារថ្មីធំនោះឯងតែម្ដងទេ អត់មានធ្វើអីប្លែកទេ។

**ស៖** សូមអរគុណ។ នៅពេលដែលគេចាត់តាំងឲ្យគាត់ធ្វើការនៅផ្សារថ្មីនោះ តើរូបលោកស្រីផ្ទាល់ហ្នឹង លោកស្រីនៅភ្នំពេញដែរឬទេ កាលនុំង?

**ធ៖** នាងខ្ញុំ ពី៧៥ ខ្ញុំអត់ទាន់បានមកនៅទេ ទាល់តែ៧៨ បានគេទៅយកខ្ញុំមកនៅជាមួយគ្នា។

**ស៖** ចាប់ពីពេលដែលគេបញ្ជូនលោកស្រីមកភ្នំពេញហើយហ្នឹង តើលោកស្រីធ្វើការដែរឬទេ? ហើយបើធ្វើការ ខ្ញុំចង់ដឹងថាតើលោកស្រីធ្វើការនៅកន្លែងណា ហើយមានឋានៈជាអ្វីដែរ?

**ឆ៖** ចាស នាងខ្ញុំមកនៅនឹងផ្សារថ្មីនេះ គឺឋានៈខ្ញុំ មានធ្វើអ្វីទេ គេឱ្យដាំបាយ ធ្វើម្ហូប សម្រាប់ចែកគ្នាហូបនៅកន្លែងនោះឯងតែម្តង។

**ស៖** លោកស្រីបានជម្រាបជូនតុលាការថា លោកស្រីបានមកដល់ទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៨។ អ៊ីចឹងខ្ញុំចង់ដឹងថា ឱ្យលោកស្រីបញ្ជាក់ថា តើលោកស្រីមកដល់ដើមឆ្នាំ៧៨ ឬក៏ចុងឆ្នាំ៧៨ ឬក៏រដូវណាដែរ លោកស្រីអាចបញ្ជាក់ជូនតុលាការបានដែរឬទេ?

[១៥:៣២:២៧]

**ឆ៖** ចាស នាងខ្ញុំឆ្នាំ៧៨នេះ គឺរដូវដែលគេចូលឆ្នាំ មុនតែមួយថ្ងៃពីរថ្ងៃ គេទៅយកខ្ញុំមក ថាមកចូលឆ្នាំលេងនៅឆ្នាំ៧៨ ក្នុងខែ៤ ខ្ញុំស្គាល់តែខែ៤ហ្នឹង ខែប៉ុន្មាន។

**ស៖** នៅពេលដែលគេទៅយកអ្នកស្រីឱ្យមកទីក្រុងភ្នំពេញនេះ កាលនោះ លោកស្រីមានកូនដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំកូនមួយ កូនរាមច្បងកើតនៅឆ្នាំ៧៤ ខ្ញុំការ៧៣ គឺ៧៤ ត្រូវ ដើមឆ្នាំ៧៤ ខ្ញុំបានកូនប្រុសមួយ។ កូនមួយនេះមកតាមជាមួយ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមត្រឡប់មកៗនិយាយអំពីមុខរបររបស់ប្តីរបស់លោកស្រី ពេលដែលគាត់ធ្វើការនៅផ្សារថ្មីហ្នឹង។ តើលោកស្រីស្គាល់មន្ទីរ៨៧០ដែរឬទេ?

**ឆ៖** ចាស កន្លែងគ្រួសារខ្ញុំធ្វើការនៅកន្លែងនោះឯង ខ្ញុំបានសួរគាត់ ខ្ញុំថា កន្លែងនេះឯង គេហៅកន្លែងអីដែរ? គាត់ថា នេះឯង គេហៅថា មន្ទីរ៨៧០។ ក្រសួង៨៧០ មិនមែនថា មន្ទីរទេថា ក្រសួង៨៧០។ ក៏ខ្ញុំដឹងតាមប្តីខ្ញុំនេះទៅ ហើយព្រោះដូចថា ចែកចាយអង្ករ បន្លែបង្ការអី សាច់ឈាមអី នៅលើកន្លែងនោះឯង។

[១៥:៣៤:៣១]

**ស៖** សូមអរគុណណាស់។ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី គឺឯកសារ E3/6325, ERN ជាភាសាអង់គ្លេស គឺ 01114153, ជាភាសាបារាំង គឺ 01152692, ខ្មែរ 00544168 ទៅដល់ 69 <លោកស្រីបាននិយាយថា>ប្តីរបស់លោកស្រីហ្នឹង ជាកម្មាភិបាលនៃមន្ទីរ៨៧០។ តើគាត់ជាកម្មាភិបាល ឬក៏គាត់គ្រាន់តែជាអ្នកធ្វើការនៅមន្ទីរនុ៎ងទេ? តើលោកលោកស្រីអាច

បញ្ជាក់ជូនតុលាការបានដែរឬទេ គាត់ធ្វើអ្វីទៅឲ្យចំតួតែម្តងនោះ?

**ឆ៖** បើនិយាយទៅគាត់អត់មានកម្មាភិបាលទេ គាត់ជាអ្នកកម្មករលីសែងសម្ភារៈ និងសេដ្ឋកិច្ច ទុកដាក់ទេ។

**ស៖** នៅក្នុងព័ត៌មានបន្ថែមរបស់លោកស្រី គឺឯកសារ E3/6425a, ERN ជាភាសាអង់គ្លេស គឺ01069300, ជាភាសាបារាំងគឺ 01051394, ជាភាសាខ្មែរគឺ 00581517/19។ ក្នុងនេះមានសរសេរ ថាប្តីរបស់លោកស្រីហ្នឹងជាប្រធានកងវរសេនាតូចនៅឆ្នាំ១៩៧៨។ អ៊ីចឹងលោកស្រីយល់យ៉ាងម៉េចដែរ មានសរសេរថាប្តីរបស់លោកស្រីហ្នឹងជាប្រធានកងវរសេនាតូចនេះ នៅឆ្នាំ១៩៧៨?

**ឆ៖** តែគាត់ ដែលថាកងវរសេនាតូចនោះ គាត់អង្គាល់ពីនៅឃោធាទេ។ ដល់គាត់ចូលមកនៅ ទីក្រុងភ្នំពេញនេះគាត់អត់មានតួនាទីអីទេ។ ដែលគាត់នៅវាយសមរភូមិ គាត់ជាកងវរសេនាតូច។ នេះ ជាការពិតអ៊ីចេះទេ។

[១៥:៣៧:២៥]

**ស៖** អ៊ីចឹងបើខ្ញុំមិនច្រឡំទេ គឺថាមុននឹងពេលដែលគេបញ្ជូនគាត់ឲ្យមកធ្វើការនៅផ្សារថ្មីនេះគាត់ ជាសមាជិកនៃកងវរសេនាតូចមួយ ហើយគាត់មិនមែនជាមេបញ្ជាការនៃកងវរសេនាតូចហ្នឹងទេ។ តើ លោកស្រីចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស គឺថានិយាយទៅគឺការពិតអ៊ីចេះឯង។ តែគាត់មកនៅហ្នឹងផ្សារថ្មីនេះ គាត់អត់មាន ទេ។ គាត់ដូចថាក្រោមគេទេ។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះលោកស្រីបាននិយាយថានៅពេលដែលលោកស្រីមកដល់ ភ្នំពេញ នៅអំឡុង<ពេល>ចូលឆ្នាំ<ថ្មី ក្នុងឆ្នាំ>១៩៧៨ហ្នឹង លោកស្រីធ្វើដាំបាយទឹកនៅទីហ្នឹង។ អ៊ីចឹង នៅពេលដែលលោកស្រីចូលធ្វើការនៅផ្សារថ្មីហ្នឹង តើលោកស្រីមានបានឃើញមេដឹកនាំជាន់ខ្ពស់ខ្មែរ-ក្រហមដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំបានក្នុងអំឡុងឆ្នាំ៧៨នេះ ដូចថាខែនោះឯង គឺខែគេជម្លៀសប្រជាពលរដ្ឋចេញ មកពីព្រៃវែង គឺថាខាងខេត្តបូព៌ា តែខ្ញុំមិនដឹងថាណាទេ ឮគេថាដែរ តែខ្ញុំនៅនោះអីដែរ។ ដល់ប្រជា ពលរដ្ឋមកនៅដាក់នឹងផ្សារថ្មីទៅ ពួកខ្ញុំនេះគេឲ្យដាំបាយចែកចាយធ្វើជាម្ហូបចែកពួកនោះអីទៅ។ ហើយ និងមានសម្ភារៈសម្លៀកបំពាក់ ដូចជាក្រមា សំពត់ ខោអាវនេះ ចែកទៅពួកគាត់។ ដល់ស្រាប់តែខ្ញុំឈរ ឆ្ងាយប្រហែលជា៣ម៉ែត្រ ខ្ញុំឃើញថាមេដឹកនាំជាន់ខ្ពស់គឺ តាខៀវ សំផន។ ខ្ញុំបានឃើញផ្ទាល់ទាញមក

ហុចទៅប្រជាពលរដ្ឋនៅក្នុងផ្សារថ្មីនោះឯង។ នេះខ្ញុំបានឃើញប៉ុណ្ណោះឯង។

**ស៖** តើអ្នកណាអ្នកប្រាប់លោកស្រីថា ខៀវ សំផន ហ្នឹងជាអ្នកចែកចំណីរអាហារទៅអ្នកដែលគេជម្លៀសមកហ្នឹង?

[១៥:៤០:១៤]

**ឆ៖** អ្នកណាប្រាប់? ខ្ញុំនៅនោះអីដែរ ព្រោះខ្ញុំឃើញទៅចម្លែក ខ្ញុំសួរប្ដីខ្ញុំថាពីណានេះឯង។ ក៏ប្ដីខ្ញុំប្រាប់ថា នេះឯងអង្គការ។ ខ្ញុំថាឈ្មោះអី? នេះឯងហៅថា អង្គការខៀវ សំផន។ បានខ្ញុំចំណាំជាប់ ថា នេះឯងមេដឹកនាំប្រទេស។ គាត់និយាយប្រាប់ខ្ញុំអ៊ីចេះឯង។ ហើយគាត់មកឈរនៅឯនោះមួយភ្លែតទៅប្រហែលជាប្រាំនាទី ស្រាប់បាត់គាត់មិនដឹងទៅណាទៀតទៅ។

**ស៖** តើលោកមាននៅចាំដែរឬទេថា តើខៀវ សំផន នោះមានអ្នកអមដំណើរគាត់ដែរឬទេ? ឬក៏ដូចថាមានអ្នកដឹកនាំផ្សេងទៀតដែរឬទេ ដែលមកជាមួយគាត់ហ្នឹងនៅពេលហ្នឹង?

**ឆ៖** ចាស កាលដែលខ្ញុំឃើញ គឺមានគេថានីរសារគាត់ ឃើញស្ពាយកាំភ្លើងមួយដើម ឈរពីក្រោយខ្នងគាត់។ ហើយគាត់ក៏ ឃើញទាញក្រមាមួយហុចទៅប្រជាជននេះហើយ ក៏ឃើញនីរសារម្នាក់ឈរពីក្រោយគាត់ ឃើញ។ ថានីរសារគាត់ ខ្ញុំសួរគេ។ ខ្ញុំឃើញនឹងភ្នែកខ្ញុំផ្ទាល់តែម្ដង។

**ស៖** តើលោកស្រីមានបានឃើញ ខៀវ សំផន ហ្នឹងតែម្ដងឯងពេលនៅភ្នំពេញហ្នឹង ឬក៏លោកស្រីបានឃើញគាត់នៅក្នុងឱកាសផ្សេងទៀតផងដែរ?

**ឆ៖** ចាស ខ្ញុំឃើញតែម្ដងគត់នេះឯង មិនដែលឃើញទៀតទេក្រោយមក។

**ស៖** លោកស្រីបានឆ្លើយថា ទស្សនកិច្ចរបស់ ខៀវ សំផន នៅផ្សារថ្មីនោះ គឺវាចំពេលដែលគេជម្លៀសប្រជាជនមកព្រៃវែង។ តើលោកស្រីនៅចាំកាលបរិច្ឆេទទេ គឺថានៅឆ្នាំ១៩៧៨ ហ្នឹងនៅផ្សារថ្មីហ្នឹង តើលោកស្រីអាចបញ្ជាក់បានទេ នៅក្នុងរដូវណា? កាលបរិច្ឆេទណា ថ្ងៃណាខែណាដែរ?

[១៥:៤២:៥៧]

**ឆ៖** ចាស នាងខ្ញុំមិនចាំទេ កាលបរិច្ឆេទ ប៉ុនចាំជាខែ ដូចថាពេលភ្ជុំរួច ខែណា? ពេលយើងភ្ជុំបិណ្ឌរួច។

**ស៖** តើមានរឿងអីកើតឡើងដែរ? លោកស្រីបានប្រាប់ថាលោកស្រីជាអ្នកធ្វើម្ហូបអាហារហ្នឹងសម្រាប់អ្នកដែលគេជម្លៀសហ្នឹងទាំងអស់ហ្នឹង? អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា តើមានរឿងអីកើតឡើងចំពោះអ្នកដែលគេជម្លៀសទាំងអស់ហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល -- ដើម្បីបណ្ដឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប!

អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់នៅក្នុងដំណាក់កាលនេះតែម្ដង។ ខ្ញុំពីមុនមក ខ្ញុំមិនបានអន្តរាគមន៍ ពីព្រោះលោកស្រីមេធាវីនិយាយអំពី ខៀវ សំផន ហើយនិងអំពីការជួបដោយសន្និដ្ឋានរវាងអ្នកស្រីដើមបណ្ដឹងរដ្ឋប្បវេណីនេះ ហើយនិងលោក ខៀវ សំផន។ ខ្ញុំគិតថា ឥឡូវនេះប្រហែលជាគាត់ចូលមកឈានចូលមកដល់សួរសំណួរអំពីការជម្លៀសប្រជាជនហើយ ការផ្លាស់ទីប្រជាជនហើយ ដែលវាមិនមាននៅក្នុងវិសាលភាពនៃសំណុំរឿងយើងនេះទេ។ អ៊ីចឹងខ្ញុំសុំជំទាស់ឲ្យហើយ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

អ្វីដែលខ្ញុំចាប់អារម្មណ៍នោះលោកប្រធាន គឺថាដោយថា យើងមើលឃើញថា តួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ ដោយសារគាត់បានដាំបាយដាំទឹកអីឲ្យអ្នកជម្លៀស ដែលគេជម្លៀសមកនោះ។ ខ្ញុំដឹងហើយថា ការផ្លាស់ទីប្រជាជននេះវាមិននៅក្នុងវិសាលភាពនៃសំណុំរឿងយើងនេះទេ ក៏ប៉ុន្តែ<ខ្ញុំអាចរំលងសំណួរនេះបាន បើ>លោកចៅក្រម<ទទួលស្គាល់ថាដូច្នោះ។ ខ្ញុំនឹងរំលងវា>។

**ស៖** ឥឡូវខ្ញុំសុំចូលទៅចំណុចថ្មីមួយទៀតចុះ។ លោកស្រីបាននិយាយថា <>លោកស្រីបានឃើញលោក ខៀវ សំផន ក្រោយពេលភ្នំបិណ្ឌ<ឆ្នាំ១៩៧៨ ដែលពេលនោះលោកស្រីនៅជាមួយប្ដីលោកស្រី។> តើលោកស្រីអាចពន្យល់ជូនតុលាការបានដែរឬទេថា <>មានរឿងអីកើតឡើងចំពោះប្ដីរបស់លោកស្រីដែរនៅចុងឆ្នាំ១៩៧៨ ហ្នឹង?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ប្ដីខ្ញុំ បើនិយាយទៅ ខ្ញុំមិនដឹងៗមានរឿងអីទេ។ ស្រាប់គេថា បាត់ខ្លួនទៅបណ្ដោយចាស មិនដឹងថាមានរឿង កំហុស ធ្វើនេះ ធ្វើនោះខុស ក៏អត់មានដឹងដែរ ទាំងរូបខ្ញុំ ទាំងប្ដីខ្ញុំអត់ដឹងដែរ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្ដល់បញ្ជីមួយទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណី គឺបញ្ជីអ្នកទោស E3/10454 បណ្ដឹងដើមបណ្ដឹងរដ្ឋប្បវេណីនេះ គាត់បានផ្ដល់ ប្រាប់ឈ្មោះប្ដីរបស់គាត់ពេលពីដើមសវ-នាការ។ អ៊ីចឹងខ្ញុំសួរ ចង់សួរគាត់បញ្ជាក់ថា តើគាត់ស្គាល់ឈ្មោះប្ដីគាត់នៅលើបញ្ជីនេះដែរឬអត់ គឺ

ERN <01018812>, ឯកសារ E3/10454។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** អ្នកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំផ្តល់បញ្ជីនេះឲ្យ ខ្ញុំដឹងថាលោកស្រីចេះអាន ប៉ុន្តែ<ខ្ញុំគិតថា លោកស្រី>ត្រូវការវ៉ែនតា។ <ខ្ញុំមិនដឹងថាតើលោកស្រី>មានវ៉ែនតានៅជិតហ្នឹង<ឬអត់>ទេ។ <តើ>លោកស្រី<អាចអានបានដោយមិនបាច់>ពាក់វ៉ែនតា<ទេ?>

គឺជាបញ្ជីឈ្មោះអ្នកទោស។ ពួកគាត់ត្រូវបានគេចាប់ខ្លួននៅខែធ្នូ ១៩៧៨។ សូមលោកស្រីមើលលេខរៀងទី១៤ នៃបញ្ជីហ្នឹងលោកស្រី។ ខ្ញុំសូមឲ្យលោកស្រីអានឲ្យខ្លាំង ឈ្មោះ ឈ្មោះហៅក្រៅ អាយុ ហើយនិងមុខតំណែងរបស់បុគ្គលរូបហ្នឹង ដើម្បីឲ្យដឹងថាតើឈ្មោះហ្នឹង លោកស្រីស្គាល់ឈ្មោះហ្នឹងដែរឬក៏អត់? លេខរៀងទី១៤ នៃបញ្ជីហ្នឹងលោកស្រី។

[១៥:៤៨:២៥]

**ឆ៖** ចាស លេខរៀងទី១៤។ ប្តីខ្ញុំ ខ្ញុំដឹងថា ខេង ជឺ, ខេង ជឿន តែជីតាគាត់ ឈ្មោះ គង់ ជឺ, គង់ ជឿន តែគាត់ដាក់ឈ្មោះជីតារបស់គាត់។ នេះអាយុគាត់ពីឆ្នាំ ចូលឆ្នាំ៧៨នេះ ត្រូវអាយុគាត់ដល់ ២៥ឆ្នាំហើយ។ ខ្ញុំបានប្រាកដថាជាគ្រួសារខ្ញុំហើយ នេះឯងនេះ ឈ្មោះនេះឯងនេះ។ ហើយរួមជាមួយអ្នកដែលមកជាមួយនេះ លេខរៀងទី១៣ គឺ គង់ យ៉េ ដែលខ្ញុំនៅជាមួយ ហៅ គង់ ញ៉េ -- កង ញ៉េ។ លេខរៀងទី១៥ គឺឈ្មោះ រុន គឺខ្ញុំមិនដឹងត្រកូលគាត់ទេ ប៉ុនឈ្មោះ រុន នេះ រុនច្បាស់ហើយ។ នៅជាមួយគ្នាបីនាក់ មកទាំងបីនាក់នេះឯងហើយ។ ថ្ងៃចេញមក ពេលវេលាជាមួយគ្នា។ ចាស សូមអរគុណ។

**ស៖** ខ្ញុំសូមបញ្ជាក់ជូនតុលាការហើយនិងភាគីផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គាត់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ ដែលកាលនោះ គេបានបដិសេធចោលដោយសារខ្វះភស្តុតាងបញ្ជាក់អំពីការបាត់ខ្លួនប្តីរបស់គាត់នៅមន្ទីរស-២១ ហើយដោយសារសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គាត់មានបញ្ជីថ្មី។ អ៊ីចឹងគឺយើងអាចរកឃើញឈ្មោះប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានភស្តុតាងបានគ្រប់គ្រាន់។ លោកស្រី នៅក្នុងបញ្ជីនេះ ឃើញថាប្តីរបស់លោកស្រីហ្នឹង ទំនងជាត្រូវបានសម្លាប់នៅខែធ្នូ ឆ្នាំ១៩៧៨ គឺនៅចុងឆ្នាំ១៩៧៨។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើព័ត៌មានដែលមាននៅក្នុងបញ្ជីនេះៗ វាត្រូវគ្នានឹងការចងចាំរបស់លោកស្រីដែរឬទេ? គាត់បាត់ខ្លួននៅចុងឆ្នាំ១៩៧៨ហ្នឹង ឬក៏យ៉ាង

ម៉េច?

[១៥:៥០:៥៦]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ សំណួរនេះមិនសមស្របទេ ដោយសារសំណួរសួរថា តើលោកស្រីចាំអ្វីខ្លះអំពីការសម្លាប់ប្ដីរបស់លោកស្រី? គាត់ សាក្សីគាត់មិនបានដឹងអំពីការសម្លាប់ប្ដីរបស់គាត់នេះទេ ដូច្នេះគាត់មិនចាំអ្វីទាំងអស់។ អ៊ីចឹងសំណួរសួររបៀបនេះ គឺថាមិនសមស្របទេ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

លោកប្រធាន ខ្ញុំកែសម្រួលសំណួរ។ ខ្ញុំនិយាយអំពីការបាត់ខ្លួនប្ដីរបស់គាត់។ អ៊ីចឹង ខ្ញុំចោទសំណួរផ្ដើមមួយសិន។

**ស៖** តើលោក លោកស្រី តើលោកស្រីនៅជាមួយគាត់ទេ ពេលដែលគេដែលចាប់ខ្លួនគាត់យកទៅហ្នឹង ពេលគេយកគាត់ចេញទៅ?

[១៥:៥២:០៤]

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ខ្ញុំចាំ អង្កាល់ដែលគេចាប់ខ្លួនគាត់យកទៅ គឺយប់នោះសម្រាកជាមួយគ្នារាល់តែថ្ងៃទេ។ ដល់ពេលព្រឹក វេលាព្រឹកនោះប្រហែលជាពេលវេលាហូបបាយ ម៉ោងមិនដឹងប៉ុន្មានទេ ចូលថាម៉ោងប្រាំពីរ ម៉ោងប្រាំបីមិនដឹង វាយូរហើយ តែប្ដីខ្ញុំក៏បាត់ខ្លួនទៅ គេហៅខ្ញុំនេះ ទៅប្រជុំនឹងកន្លែងដែលកន្លែងបន្ទប់ដែលខ្ញុំនៅ។ ខ្ញុំសួរថា ហៅខ្ញុំទៅណា? ថា៖ គេឲ្យទៅធ្វើស្រែម្ដង ពួកយើងនោះ។ ខ្ញុំសួរថា ចុះឯណាប្ដីខ្ញុំ? ទៅមុនបាត់ហើយ។ ដល់ពេលថាទៅមុនបាត់ហើយ ខ្ញុំនេះក៏មិនដឹងជាថាៗម៉េច បើអីវ៉ាន់នៅលើផ្ទះដំណេកជាមួយនឹងខ្ញុំនេះហើយ។ ព្រោះកូនខ្ញុំនោះ វាអាល័យលេងខាងក្រោយនេះ ខ្ញុំឃើញកូនមកលេង ខ្ញុំស្រែកហៅកូនខ្ញុំមកសួរថា អាទូច ឯណាពុកអ្អែង កូន? ថា ហ៊ីទៅជាមួយ ពូរុន, ពូញ៉ែ បាត់ហើយ ពុក ជិះឡានមួយទៅបាត់ហាយ។ បាន កូនខ្ញុំវាអាយុ៣ឆ្នាំជាងទៅហើយ ហើយបានខ្ញុំដឹង ខ្ញុំតាមដានទៅ ក៏បាត់សូន្យឈឹង ទាល់តែឥឡូវនេះ ចាស។

[១៥:៥៣:២៦]

**ស៖** តើមានរឿងអីកើតឡើងចំពោះលោកស្រី ហើយនិងកូនលោកស្រីក្រោយពេលដែលប្ដីរបស់លោកស្រីហ្នឹងត្រូវបានចាប់ខ្លួនហើយនោះ?

**ឆ៖** ពេលក្រោយដែលគេចាប់ប្ដីខ្ញុំយកទៅហើយ ខុសគ្នាប្រហែលជាថា មិនដល់មួយម៉ោងផង វាឲ្យខ្ញុំរៀបចំអីវ៉ាន់ជិះឡានឃ្លុបស ចេញទៅដែរ មកធ្វើស្រែដែរ។ ចេញមកវាលឯលិចនេះឯង វាថាមកធ្វើស្រែ ដឹងកន្លែងណាខ្ញុំមិនស្គាល់ដែរ។ មកជាមួយនឹងកូន ខ្ញុំមានគ្នាខ្លះ ប្រហែលជាបួនប្រាំនាក់ដែរ មកជាមួយគ្នា។ មក គេច្រូតស្រូវបណ្ដោយហ្នឹង ខែច្រូតស្រូវហ្នឹង។

**ស៖** តើគេមានពន្យល់ប្រាប់លោកស្រីអំពីមូលហេតុដែលថា តម្រូវឲ្យលោកស្រីចាកចេញពីភ្នំពេញដែរឬទេ?

**ឆ៖** ចាស មុននឹងគេឲ្យចាកចេញ គេប្រាប់ថាឲ្យមកធ្វើស្រែ។

**ស៖** តើគេមានបានពន្យល់អំពីមូលហេតុនៃការចាប់ខ្លួនប្ដីរបស់លោកស្រីដែរឬទេ?

**ឆ៖** ចាស អត់មានទេ។ អត់មានដឹងថាបាត់ហើយ គឺថាប្ដីនាងឯងទៅនេះ ទៅនោះអីអត់។ ខ្ញុំគ្រាន់តែរង់ចាំមួយថ្ងៃទៅមួយថ្ងៃគឺបាត់ឈឹងទៅបណ្ដោយ គ្មានដឹងថាមុខទៅណា ឬទៅណើអី អត់ដឹងសោះ។ គ្រាន់ថាគេចាប់យកមកមិនដឹងទីកន្លែងណាតែប៉ុណ្ណោះឯងទេ។

**ស៖** លោកស្រីបាននិយាយអំពីកូន<ប្រុស>របស់លោកស្រី ដែលបាននិយាយអំពីកាលៈទេសៈនៃការចាប់ ខ្លួនប្ដីរបស់លោកស្រី តើ<>លោកស្រីមានកូនផ្សេងទៀតទេ <ក្នុងរបបខ្មែរក្រហម មុនពេលបាត់ខ្លួនប្ដីលោកស្រី ឬ>ក្រោយពីពេលដែលគេចាប់ប្ដីរបស់លោកស្រីបាត់ទៅ<>?

**ឆ៖** ចាស នាងខ្ញុំដែលបែកពីប្ដីទៅ ខ្ញុំមានទម្ងន់នៅក្នុងផ្ទៃ៧ខែ ដែលប្ដីខ្ញុំគេយកទៅ ហើយគេឲ្យខ្ញុំចេញមកធ្វើស្រែនេះក៏ខ្ញុំកូនតូចផង និងមានផ្ទៃពោះ៧ខែនៅពោះទៀត។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៥:៥៦:៤៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំមានសំណួរមួយ លោកស្រីមេធាវី តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើឈ្មោះប្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងមាននៅលើបញ្ជីអ្នកទោសដែលធ្វើដោយការិយាល័យសហ

ចៅក្រមស៊ើបអង្កេតដែរឬទេ? <ខ្ញុំយល់ថា លោកស្រីយោងទៅលើឯកសារដែលបញ្ជាក់ភស្តុតាងអំពីបញ្ជីនេះ ប៉ុន្តែ>លោកស្រីអត់មានឲ្យលេខ ដែលលេខៗរៀងដែលចង្អុលបង្ហាញអំពីឈ្មោះប្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ខ្ញុំមាន ខ្ញុំកំពុងតែរក ឥឡូវខ្ញុំរកឃើញហើយ។ នៅក្នុងបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ <E3/10604> គឺលេខរៀង ១២៨៣១ – ១២៨៣១។ ហើយឈ្មោះសហការីគាត់ពីរនាក់ទៀតហ្នឹង ដែលលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងអម្បាញ់មិញនេះ ក៏មាននៅក្នុងបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតដែរ គឺនៅលេខរៀង ១០៨៣០ ឈ្មោះ យ៉េ <ដែលគាត់បាននិយាយ>។ ហើយមួយទៀតគឺលេខរៀង១០៨៣២ គាត់ហ្នឹងឈ្មោះ រុន ហើយលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានលើកឡើងពីគាត់ដែរអម្បាញ់មិញនេះ។ លោកប្រធានខ្ញុំចង់សួរសំណួរចុងក្រោយមួយ ខ្ញុំចង់ឲ្យគាត់និយាយថ្លែងពីទុក្ខវេទនារបស់គាត់។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីបានជម្រាបជូនតុលាការថាលោកស្រីត្រូវបានគេបញ្ជូនទៅឲ្យធ្វើស្រែជាមួយនឹងកូនរបស់លោកស្រី ហើយកាលនោះលោកស្រីមានផ្ទៃពោះផង ៧ខែ។ ហើយអ៊ីចឹងខ្ញុំសួរលោកស្រីថា តើលោកស្រីបានសម្រាលកូនក្នុងកាលៈទេសៈណាដែរ ក្នុងលក្ខខណ្ឌណាដែរនៅពេលនោះនុះ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ខ្ញុំដែលគេឲ្យចេញមកធ្វើស្រែហើយ ដល់ពេលមកច្រូតស្រូវបានជាកន្លះខែ គេបញ្ជូនខ្ញុំទៅមុខទៀត តែគឺគ្មានឡានគ្មានអីទេដើរៗនោះគឺខ្ញុំពផ្ទៃផង ក្បាលខ្ញុំទូលអីវ៉ាន់សម្ភារៈហូប គេក៏ទៅ ខ្ញុំក៏ទៅព្រៃប្រ៉ូច្រើន ទៅក៏រហូតទៅដល់ពោធិ៍សាត់។ ចេញពីពោធិ៍សាត់ទៀត ទៅដល់ គេហៅថាភ្នំបាដេ។ ហើយត្រឡប់ពីនោះមកវិញ គេចេះតែ *(ឮមិនច្បាស់)* ត្រឡប់ពីនោះមកវិញ ខ្ញុំកើតកូននៅ ហៅសហករណ៍មោងឫស្សី។ កូនខ្ញុំកូនស្រី កើតនៅឆ្នាំ -- ចុងឆ្នាំ៧៩មិនដឹង។ កូនខ្ញុំកើតនៅ បើនិយាយទៅថា ខែ៣ ខែផល្គុន។ ខ្ញុំមិនច្បាស់លាស់ដែរ ប៉ុនឆ្នាំមមី កូនខ្ញុំ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ សុំអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ។ សវនាសការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ច

ដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅស្អែក ថ្ងៃពុធ ទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ហើយនិងផ្តើមស្តាប់ក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែងគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់មកចូលរួមផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅថ្ងៃស្អែកទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*